សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

ROYAL UNIVERSITY OF LAW AND ECONOMICS

# សារណាបញ្ចប់ការសិក្សា

# ភស្តុតាងក្នុងរឿងរដ្ឋប្បវេណី

កម្មសិក្សាពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧


| | |
|---|---|
| តាក់តែងឡើងដោយ | សាស្ត្រាចារ្យណែនាំ |
| និសិត្សឈ្មោះ លោក ព្រំ សុខុន | លោក ញឹក វុទ្ធី |
| ព្រះតេជគុណ វី វ៉ី | |
| ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ | ឆ្នាំសិក្សា ២០១៣ |
| ជំនាន់ទី១៧ | ឆ្នាំសរសេរសារណា ២០១៧ |

# លិខិតថ្លែងអំណរគុណ

យើងខ្ញុំ **ព្រំ សុខុន** និង **រី រ៉ី** ជានិស្សិតដែលបានបញ្ចប់បរិញ្ញាប័ត្រនីតិសាស្ត្រនៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មានការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

លោកឪពុក អ្នកម្តាយដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ ថែរក្សា និងអប់រំទូន្មាន ប្រៀនប្រដៅកូនប្រកបដោយព្រហ្មវិហារធម៌ តាំងពីកូននៅតូចរហូតដល់បានចំរើនវ័យធំ និងបានបញ្ចប់ការសិក្សា។ លោកទាំងពីរបានពលីអស់កំលាំងកាយ អស់កំលាំងចិត្តដើម្បីទំនុកបំរុង ឧបត្ថម្ភគាំទ្ររូបកូន ទាំងផ្នែកស្មារតី សំភារៈ ថវិកា ដែលជាបុព្វហេតុជំរុញអោយការសិក្សារបស់កូនទទួលបានជោគជ័យ។

ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រមទាំងសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្រសេដ្ឋកិច្ចទាំងអស់ដែលបានខិតខំអស់ពីសមត្ថភាពក្នុងការរៀបចំកម្មវិធីសិក្សា បង្ហាត់បង្រៀន និងអប់រំយើងខ្ញុំចាប់តាំងពីថ្នាក់ដំបូងរហូតថ្នាក់បញ្ចប់។

សាស្ត្រចារ្យណែនាំ លោកសាស្ត្រាចារ្យ **ញ៉ឹក ខុទ្ធី** ដែលបានខិតខំអស់ពីកំលាំងកាយ កំលាំងចិត្ត និងចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការដឹកនាំស្រាវជ្រាវ ដោយបានបង្ហាញគំនិត និងផ្តល់មតិយោបល់ល្អៗដល់យើងខ្ញុំដែលជាកត្តាជំរុញ អោយសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំអាចបញ្ចប់បានប្រកបដោយជោគជ័យ។

មិត្តភក្តិយើងខ្ញុំទាំងអស់ដែលបានចំណាយពេលក្នុងការជួយរកឯកសារ និងផ្តល់ជាយោបល់ល្អដែលធ្វើអោយសារណាយើងខ្ញុំលេចចេញជារូបរាង។

ជាទីបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធិពរជ័យជូនចំពោះ លោកអ្នកមានគុណទាំងអស់អោយជួបប្រទះតែនិងសេចក្តីសុខគ្រប់ប្រការ ព្រមទាំងសំរេចបាននូវរាល់គ្រប់កិច្ចការ និងគ្រប់បំណងប្រាថ្នាទាំងអស់។

# អារម្ភកថា

ឆ្លងតាមការសិក្សានៅសាកលវិទ្យាល័យអស់រយៈពេល៣ឆ្នាំ និង១ឆមាសមក សិស្សគ្រប់រូបត្រូវបាន សាកលវិទ្យាល័យផ្តល់រយៈពេល១ឆមាស ចុងក្រោយសម្រាប់ធ្វើសារណាបញ្ចប់ និងការពារណាដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រ។ ក្នុងកំឡុងពេលធ្វើសារណានេះ យើងខ្ញុំខិតខំស្រាវជ្រាវនូវឯកសាររបស់សាស្ត្រចារ្យ ក្រម ច្បាប់ និងបទដ្ឋានគតិយុត្តនានា ដើម្បីបង្កើតសារណានេះឡើង។ ថ្វីត្បិតតែវាមានការលំបាកក្នុងការចងក្រងនូវសារណានេះឡើង ក៏យើងខ្ញុំមានមោទនភាព និង ត្រេកអរចំពោះការចងក្រង និងរៀបចំសារណានេះហើយជាស្ថាពរ។

យើងខ្ញុំសរសេរ និងចងក្រងសារណាដែលស្តីអំពី ភស្តុតាងក្នុងរដ្ឋប្បវេណី នេះ ដើម្បីបំពេញលក្ខខណ្ឌចំបងរបស់សាកលវិទ្យាល័យក្នុងការបញ្ចប់ការសិក្សាលើថ្នាក់បរិញ្ញប័ត្រ។ ជាពិសេសទៅទៀត ការចងក្រងនូវសារណានេះ គឺដើម្បីជួយដល់និស្សិតជំនាន់ក្រោយ និងអ្នកដែលត្រូវការសម្រាប់សិក្សា ប្រើប្រាស់ ជាពិសេសសម្រាប់ការស្រាវជ្រាវដែលទាក់ទងជាមួយនឹងសារណានេះ។

ដោយសារណានេះជាស្នាដៃទីមួយរបស់យើងខ្ញុំ ដូចនេះភាពខ្វះចន្លោះពិតជាមិនអាចជៀសផុតទេ ព្រោះមនុស្សគ្រប់រូបមិនអាចធ្វើអ្វីឲ្យល្អឥតខ្ចោះនោះទេ ប៉ុន្តែយើងខ្ញុំខិតខំប្រឹងប្រែងកែលំអសារណានេះអោយមានភាពប្រសើរបំផុត តាមលទ្ធភាពដែលអាចធ្វើទៅបាន។ ហេតុនេះហើយសូមមិត្តអ្នកអាន អ្នកស្រាវជ្រាវគ្រប់រូបដែលបានអាន ឬស្រាវជ្រាវសារណានេះមេត្តាខន្តីអភ័យទោសចំពោះរាល់កំហុសឆ្គង និងភាពខ្វះខាតលើចំណុចណាមួយ។ យើងខ្ញុំរង់ចាំទទួលការកែតម្រូវ និងមតិស្ថាបនាដោយក្តីរីករាយ។

ជាទីបញ្ចប់នេះ យើងខ្ញុំសូមថ្លែងអំណរគុណដល់មិត្តអ្នកអានគ្រប់រូប ហើយសូមឲ្យអ្នកទាំងអស់គ្នាជួបតែសំណាងល្អក្នុងជីវិត និងជួបនូវពុទ្ធពរទាំងឡាយ៤ ប្រការគឺៈ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១
## អត្ថន័យគ្រឹះនៃភស្តុតាង

**ផ្នែកទី១** : **អត្ថន័យនៃភស្តុតាង** ........ ៤

កថាភាគទី១: ការកំណត់និយមន័យនៃភស្តុតាង ........ ៦

កថាភាគទី២: បទដ្ឋាននៃភស្តុតាង ........ ៧

កថាភាគទី៣: សញ្ញាណនៃភស្តុតាង ........ ៨

**ផ្នែកទី២** : **ការវិវត្តន៍នៃបទដ្ឋាននៃភស្តុតាង** ........ ៩

កថាភាគទី១: ទស្សនៈវិទ្យានៃភស្តុតាង ........ ១២

កថាភាគទី២: ករណីនាំឱ្យកើតឡើងភស្តុតាង ........ ១៣

កថាភាគទី៣: ចំណាត់ថ្នាក់នៃភស្តុតាង ........ ១៤

## ជំពូកទី២
## គោលការណ៍ទូទៅនៃភស្តុតាង

**ផ្នែកទី១** : **គោលការណ៍សម្រេចសេចក្តីនៃភស្តុតាង** ........ ១៦

កថាភាគទី១: ភស្តុតាងដោះបន្ទុក និងភស្តុតាងដាក់បន្ទុក ........ ១៨

កថាភាគទី២: ភស្តុតាងជាសម្ភារ: និងភស្តុតាងក្រៅសម្ភារ: ........ ២០

កថាភាគទី៣: ភស្តុតាងតាមការបំភ្លឺរបស់សាក្សី ........ ២២

**ផ្នែកទី២**: **ការពិនិត្យភស្តុតាង** ........ ២៥

កថាភាគទី១: ការពិនិត្យភស្តុតាងដំបូង និងភស្តុតាងបន្ទាប់បន្សំ ........ ២៨

កថាភាគទី២: ការពិនិត្យភស្តុតាងប្រយោល និងភស្តុតាងផ្ទាល់ ........ ៣០

កថាភាគទី៣: ការពិនិត្យភស្តុតាងដោយសម្ងហវិធី ........ ៣៣

## ជំពូកទី៣
## ការបញ្ជាក់ភស្តុតាង


**ផ្នែកទី១: នីតិវិធីនៃការបញ្ជាក់ភស្តុតាង** ...................................................... ៣៤

កថាភាគទី១: មធ្យោបាយនៃការបង្ហាញភស្តុតាង ........................................ ៣៦

កថាភាគទី២: ដំណើរការនៃការបញ្ជាក់សក្ខីកម្ម ........................................ ៣៨

កថាភាគទី៣: ការបញ្ជាក់តាមការបំភ្លឺរបស់ដើមចោទ និងចុងចម្លើយ ..................៤០

**ផ្នែកទី២: ការបញ្ជាក់ភស្តុតាងដោយការធ្វើកោសលវិច័យ**........................ ៤១

កថាភាគទី១: ការបញ្ជាក់ភស្តុតាងតាមការធ្វើកោសលវិច័យ.......................... ៤២

កថាភាគទី២: ការបញ្ជាក់ភស្តុតាងសច្ចធារណ៍ ........................................ ៤៤

កថាភាគទី៣: ភស្តុតាងតាមសេចក្តីសន្និដ្ឋានរបស់ចៅក្រម ............................ ៤៧

**សេចក្តីសន្និដ្ឋាន**..........................................................................................

**ឯកសារយោង** ..........................................................................................

**ឧបសម្ព័ន្ធ** ..........................................................................................

# សេចក្ដីផ្ដើម

«សាងបុណ្យបានបុណ្យ សាងបាបបានបាប» នេះគឺពាក្យទំនៀម និងជាពាក្យព្រានប្រដៅរបស់ព្រះបរមគ្រូ ហើយយើងតែងតែបានឮគ្រប់ៗគ្នាតាមការសិក្សា រឺក៏តាមរយៈការស្ដាប់ព្រះសង្ឃទេសនា រឺយើងអាចឮតាមពាក្យរបស់ចាស់ៗដែលគាត់តែងតែនិយាយព្រានប្រដៅដល់កូនចៅរបស់គាត់។ នៅក្នុងន័យខាងលើព្រះបរមគ្រូព្រះអង្គចង់ប្រដៅសត្វលោកឱ្យមានកិរិយាប្រព្រឹត្តនូវអំពើល្អ ដើម្បីវៀរចាកពីអំពើទុច្ចរិតដែលនាំឱ្យមានការខូចខាត និងមានភាពវិនាសដល់អ្នកដ៏ទៃហើយវាក៏ជាហេតុដែលនាំមកនូវសេចក្ដីវិនាសដល់ខ្លួន ហើយនឹងសង្គមតែងតែមិនផ្ដល់តម្លៃលើបុគ្គលប្រភេទនោះទេ។ ព្រះបរមគ្រូព្រះអង្គបានចាត់ទុកថាមនុស្សគ្រប់រូបនៅលើផែនដីមានតម្លៃស្មើរគ្នាក្នុងការរស់នៅក្នុងសង្គមមិនថាសិទ្ធិរស់ រឺក៏កាតព្វកិច្ចដែលត្រូវបំពេញនោះទេ។ ការរស់នៅមិនត្រូវឱ្យមានការបំពានគ្នា និងគ្នាដែលនាំមកនូវអសន្តិសុខក្នុងសង្គមឡើយ។ យោងតាមទ្រឹស្ដីនេះមានន័យថាវា គឺជាច្បាប់ដែលព្រះអង្គបានបញ្ញត្ត ប៉ុន្តែក្នុងច្បាប់របស់ព្រះអង្គ ព្រះអង្គមិនបានមានពុទ្ធដីកាឬក៏ចែងពីការដាក់ទោសជាក់ស្ដែងទេ ការដាក់ទោសនោះមានដូចជា៖ ទារុណកម្ម ឃាត់ខ្លួន ឬពិន័យជាប្រាក់ជាដើម។ល។ គ្រាន់តែថាអ្នកបានសាងអំពើរបាបនឹងត្រូវចុះទៅនរក ឬទទួលបាបជារបស់ខ្លួនដែលបានសាងមកតែប៉ុណ្ណោះទាំងនេះ គឺជាច្បាប់របស់ព្រះពុទ្ធជាម្ចាស់។

ក៏ប៉ុន្តែនៅក្នុងការដោះស្រាយរឿងក្ដីនីមួយៗនៅក្នុងសង្គមបច្ចុប្បន្នវិញ យុត្តិធម៌ពិតជាមានសារៈសំខាន់ណាស់ចំពោះគូភាគី និងចំពោះចៅក្រម។ ទន្ទឹមនឹងនេះដែរ នៅពេលមានការជំនុំជំរះនៅតុលាការ គឺចៅក្រមជាអ្នកអនុវត្តនូវនីតិវិធីផ្សេងៗ ទៅតាមផ្លូវច្បាប់ហើយធ្វើការសន្និដ្ឋានដោយពឹងផ្អែកទៅលើអង្គហេតុ។ ប៉ុន្តែការសន្និការនេះ មិនមែនចៅក្រមខ្លួនឯងចេះតែសន្និដ្ឋាននោះទេ គឺចៅក្រមធ្វើការសន្និដ្ឋានដោយពឹងផ្អែកទៅលើភស្ដុតាងដែលគូភាគីបានផ្ដល់អោយខ្លួន និងភស្ដុតាងដែលខ្លួនស្វែងរក ការស្រាវជ្រាវ និងពិនិត្យយ៉ាងច្បាស់លាស់ ជាពិសេសទៅទៀតភស្ដុតាងនេះដែរក៏អាចជួយចៅក្រមក្នុងសន្មតថាមាន ឬគ្មាននូវរាល់ស្ថានភាពលំអិតជាមូលដ្ឋានណាមួយនៃអង្គហេតុជាក់ស្ដែងនៃរឿង។ ដូចនេះហើយ ភស្ដុតាងពិតជាមានសារៈសំខាន់ណាស់ ក្នុងការដោះស្រាយរឿងក្ដីដើម្បីអោយមានភាពយុត្តិធម៌ និងបញ្ជាក់ពីភាពបរិសុទ្ធរបស់ភាគី។ ភស្ដុតាងស្ថិតនៅក្នុងរឿងព្រហ្មទណ្ឌផង និងក្នុងរឿងរដ្ឋប្បវេណីផង ប៉ុន្តែ យើងលើកយកតែភស្ដុតាងក្នុងរឿងរដ្ឋប្បវេណីមកសិក្សាលំអិតប៉ុណ្ណោះ។ ការសិក្សាទៅលើភស្ដុតាងក្នុងរឿងរដ្ឋប្បវេណី គឺដើម្បីបង្ហាញប្រជាពលរដ្ឋ ជាពិសេសអ្នកសិក្សាគ្រប់រូបអោយស្គាល់ និងយល់ដឹងអោយបាន

ច្បាស់ពីភស្តុតាងដែលយើងអាចយកប្រើប្រាស់ក្នុងរឿងរដ្ឋប្បវេណី។ ភស្តុតាង វាគឺជាអង្គហេតុ រឺក៏ជាព្រឹត្តិហេតុទាំងឡាយ(*facts*)ដែលអង្គហេតុទាំងនោះត្រូវបានកំណត់ដោយច្បាប់មានន័យថាអង្គហេតុទាំងនោះស្របទៅនឹងក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ២០០៧ និងទម្រង់នីតិវិធីនានាដែលអាចបង្ហាញ ឬបដិសេធន៍ទៅលើព្រឹត្តិការណ៍នៃបទពិន័យ(*ការបំពានសិទ្ធិ*)ណាមួយ។ ដោយអង្គហេតុទាំងនោះអាចបង្ហាញពីការពិតមួយដែលនាំមកនូវការដោះបន្ទុកហើយនឹងការដាក់បន្ទុកចំពោះបុគ្គលណាម្នាក់ដែលបានប្រព្រឹត្ត ហើយបុគ្គលនោះត្រូវទទួលខុសត្រូវលើអំពើរដែលខ្លួនបានប្រព្រឹត្តិ។ ហេតុដែលបានកំណត់នូវនត្ថិភាព រឺអត្ថិភាពនៃសិទ្ធិ ដើម្បីឱ្យគូភាគីនោះទទួលយកបាន និងមានភាពយុត្តិធម៌ទៅដល់ភាគីនៃវិវាទនៅក្នុងរឿងក្តីនីមួយៗដែលបានកើតឡើង។ ព្រឹត្តិការណ៍នៅក្នុងន័យនេះគឺការទំនាក់ទំនងរវាងបុគ្គល និងបុគ្គល រឺបុគ្គល និងនីតិបុគ្គលនៅក្នុងសកម្មភាពណាមួយដែលអាចទទួលការដឹងឮជាទូទៅបាន។ ភស្តុតាង គឺជាកត្តាដ៏សំខាន់សម្រាប់ធ្វើការដោះស្រាយរាល់វិវាទដែលបានកើតមានឡើងនៅក្នុងសង្គម ដែលអ្នកច្បាប់គ្រប់រូបត្រូវតែយល់ឱ្យច្បាស់ពីវាចំណែកឯនៅក្នុងនីតិវិធីរបស់តុលាការ និងនៅក្នុងការវិនិច្ឆ័យរបស់ចៅក្រមគឺផ្អែកទៅលើភស្តុតាងដែលជាចំណុចសំខាន់ក្នុងការវិនិច្ឆ័យរកយុត្តិធម៌សម្រាប់គូវិវាទ។

តើភស្តុតាងជាអ្វី? តើគេចែកភស្តុតាងបានប៉ុន្មានប្រភេទ?

ដើម្បីទទួលបាននៅភាពលម្អិតគប្បីសិក្សាអំពីៈ អត្ថន័យគ្រឹះនៃភស្តុតាង(ជំពូកទី១) បន្ទាប់មកគឺគោលការណ៍ទូទៅនៃភស្តុតាង(ជំពូកទី២) និងចុងក្រោយ គឺជាការបញ្ជាក់ភស្តុតាង ដូចនេះសូមធ្វើការបកស្រាយនូវជំពូកនីមួយៗខាងលើនេះដូចតទៅ។

# ជំពូកទី១
# អត្ថន័យគ្រឹះនៃភស្តុតាង

## ផ្នែកទី១: អត្ថន័យនៃភស្តុតាង

អត្ថន័យនៃភស្តុតាង គឺមានសារៈប្រយោជន៍ក្នុងការយល់ដឹងទៅលើនីតិភស្តុតាងនៅក្នុងរឿងរដ្ឋប្បវេណីនេះណាស់ ពីព្រោះបើយើងមិនយល់ថាតើអ្វីជាភស្តុតាងនោះទេ គឺអាចធ្វើឱ្យយើងមានការភាន់ច្រឡំ និងគ្មានភាពច្បាស់លាស់នៅក្នុងការសម្រេចសេចក្ដីទៅលើអ្វីមួយបាននោះឡើយ។

ភស្តុតាងវាគឺជាអង្គហេតុ រឺក៏ជាព្រឹត្តិហេតុដែលបានកើតឡើងទាំងឡាយ ហើយព្រឹត្តិហេតុ ឬអង្គហេតុទាំងអស់នោះត្រូវបានកំណត់ដោយច្បាប់ ម្យ៉ាងវិញទៀតអង្គហេតុពិត គឺជាអង្គហេតុដែលបានកើតចេញពីព្រឹត្តិការណ៍នានា។ ដើម្បីយល់ឱ្យបានច្បាស់លើអត្ថន័យគ្រឹះខាងលើចាំបាច់ យើងត្រូវស្វែងយល់ពីខ្លឹមសារនៃពាក្យគន្លឹះមួយចំនួនជាមុនសិន។

«ព្រឹត្តិការណ៍» នៅក្នុងន័យនេះ គឺចង់សំដៅទៅលើសកម្មភាពទាំងឡាយដែលមានទំនាក់ទំនងរវាងគ្នាទៅវិញទៅមក ហើយទទួលស្គាល់ដោយច្បាប់នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជា។ តបតាមអត្ថន័យខាងលើនេះ កាលណាកិច្ចសន្យាបានបង្កើតឡើងហើយនុ៎ះ! ដូច្នេះនាំឱ្យកិច្ចសន្យាទាំងអស់នោះ ធ្វើឱ្យគូភាគីមានចំនងចងភ្ជាប់គ្នាទៅវិញទៅមក ស្ថិតនៅក្នុងអំឡុងពេលដែលកិច្ចសន្យាកំពុងដំណើរការរហូតដល់បញ្ចប់សកម្មភាព ហើយសកម្មភាពនោះគឺជាការបំពេញឱ្យគ្នាទៅវិញទៅមកដែលស្របតាមឆន្ទៈរបស់ពួកគេដែលបានព្រមពៀងគ្នាពីមុនមក ក្នុងករណីមានភាគីណាមួយមិនគោរពតាមកិច្ចសន្យាដែលបានព្រមព្រៀងគ្នា ឬក៏មានការបន្លំពីភាគីខាងណាមួយដែលអាចនាំឱ្យវិវាទកើតឡើង ដូច្នេះការដែលមិនគោរពតាមកិច្ចសន្យា រឺក៏ការបន្លំទាំងអស់នោះ គឺជាព្រឹត្តិការណ៍ដែលបានកើតឡើងនោះហើយ។

ព្រឹត្តិការណ៍ មិនមែនសំដៅទៅលើតែទំនាក់ទំនងក្រៅកិច្ចសន្យាតែប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងចំណុចនេះ យើងខ្ញុំសូមធ្វើការបកស្រាយខ្លះៗអំពីការទទួលខុសត្រូវមួយចំនួនរបស់រូបវន្តបុគ្គល ឬក៏នីតិបុគ្គលទទួលពិន័យដែលមិនមែនជាអំពើរបស់ខ្លួនហើយដោយការធ្វេសសប្រហែសរបស់បុគ្គលិកខ្លួន ឬក៏ជាការធ្វេសប្រហែសរបស់ខ្លួន។

ឧទាហរណ៍៖ បុគ្គលិកក្រុមហ៊ុនរបស់នីតិបុគ្គល«ក» បានបើកបរធ្វេសប្រហែសបណ្ដាលឱ្យស្ត្រីម្នាក់រងរបួស ដូច្នេះនីតិបុគ្គល«ក»គឺជាទទួលខុសត្រូវលើសំណងចំពោះស្ត្រីនោះចំពោះអំពើរបស់បុគ្គលិកខ្លួន។

«ខណៈ» គឺជាសកម្មភាពដែលបានកើតមានឡើងភ្លាមៗ ហើយសកម្មភាពនោះអាចលេចចេញនៅចំណុចអវិជ្ជមានមួយចំនួន ដែលនាំឱ្យភាគីទាំងពីរមានវិវាទនឹងគ្នា។ ករណីមានវិវាទលេចឡើងហើយនោះភស្តុតាងក៏លេចចេញតាមរយៈខណៈនោះផងដែរ។

នៅក្នុងឆ្នាំ១៩៤៩ «លោកអ៊ែដវ៉ាដមូរហ្វី» បានធ្វើការបកស្រាយទៅលើព្រឹត្តិការណ៍ផ្សេងៗនៃមហន្តរាយរបស់មនុស្សលោកដែលបានកកើតឡើងនៅលើផែនដី ជាពិសេសបកស្រាយទៅលើបច្ចេកវិទ្យាគ្រឿងម៉ាស៊ីនដូចជាការធ្លាក់យន្តហោះ។ បន្ទាប់មកលោកតែងតែធ្វើការស្រាវជ្រាវ ហើយធ្វើការផ្ទៀងផ្ទាត់រាល់ពេលមានគ្រោះមហន្តរាយចំពោះយន្តហោះម្តងៗដើម្បីរក«អង្គហេតុពិត»[1] ។ លោកកើតនៅថ្ងៃទី១១ ខែមករា ឆ្នាំ១៩១៨ ហើយបានស្លាប់នៅថ្ងៃទី១៧ ខែកក្កដា ក្នុងឆ្នាំ១៩៩០ បានឱ្យអត្ថន័យអង្គហេតុថា «មានអង្គហេតុពិតមួយដែលមានការអះអាងអំពីសកម្មភាពទាំងឡាយឱ្យកាន់តែមានភាពរឹងមាំបំផុត»។ អនុលោមតាមគំនិតនេះចង់បញ្ជាក់ថា ប្រសិនបើមានអង្គហេតុពិតមួយបានកើតឡើងហើយនឹងធ្វើឱ្យមានគេយកវាមកធ្វើជាការអះអាងនៅក្នុងរឿងវិវាទមួយជាចាំបាច់។

តើប្រភពព័ត៌មានទាំងអស់នោះ អាចនាំឱ្យមានការសន្និដ្ឋានលើនត្ថិភាព និងអត្ថិភាពនៃសិទ្ធិបានដែរឬទេ? ប៉ុន្តែផ្ទុយទៅវិញអ្នកវាយតម្លៃដូចជាស្ថាប័នតុលាការមិនមែនសុទ្ធតែជាអ្នកប្រាកដនិយមថាអង្គហេតុសុទ្ធតែជាការពិតនោះឡើយ ព្រោះថាភស្តុតាងខ្លះបានមកជាលក្ខណៈប្រយោលតែប៉ុណ្ណោះ។ ដូចជាភស្តុតាងតាមបំភ្លឺរបស់សាក្សីទាំងឡាយ ហើយទាំងអស់នេះបានបង្ហាញថាតុលាការត្រូវតែបំពេញកិច្ចការរបស់ខ្លួនឱ្យមានតម្លាភាព វាគឺជាការវាយតម្លៃដែលមានភាពច្បាស់លាស់បំផុត មិនមែនវាយតម្លៃទៅលើអ្វីដែលមិនមានភាពច្បាស់លាស់នោះឡើយ។ ប្រសិនបើចៅក្រមធ្វើការវាយតម្លៃទៅលើអង្គហេតុមួយដោយខ្វះនូវមធ្យោបាយ និងខ្វះនូវចំណេះដឹងស៊ីជម្រៅក្នុងការសិក្សាទៅលើអង្គហេតុនោះ នាំឱ្យសេចក្តីសន្និដ្ឋានរបស់ចៅក្រមស្ថិតក្នុងទ្រង់ទ្រាយកុហកដ៏ពិតប្រាកដ ហើយអ្វីៗទាំងអស់នេះគឺ

[1] ដកស្រង់ចេញពីនីតិភស្តុតាង ដោយ : អនុបណ្ឌិត អ៊ិន បូផាបោះពុម្ពនៅឆ្នាំ២០១៦ ទំព័រទី៨

ដោយសារតែចៅក្រមយកតួនាទី និងអំណាចនានាដែលខ្លួនមានតាមផ្លូវច្បាប់យកទៅធ្វើជាឧបករណ៍ដើម្បីរកប្រាក់ ហើយនឹងយកធ្វើជាលេសដើម្បីបង្គ្រប់កិច្ចតែប៉ុណ្ណោះ។

ចំពោះជំនឿទុកចិត្តលើអង្គហេតុមួយ ក្នុងពេលដែលចៅក្រមបំពេញកាតព្វកិច្ចរបស់ខ្លួនគឺគ្មានភាពច្បាស់លាស់នោះទេ ហើយជួនកាលព្រឹត្តិការណ៍នោះបានកើតឡើងរួមទាំងមានភស្តុតាងទៀតផង ដើម្បីយកមកបញ្ជាក់ឱ្យច្បាស់អំពីនត្ថិភាព និងអត្ថិភាពនៃសិទ្ធិដែលបានបង្ហាញឱ្យឃើញច្បាស់លាស់ហើយដែរ ប៉ុន្តែបែរជាសមត្ថកិច្ចតុលាការបានត្រឹមតែបកស្រាយថាអង្គហេតុនេះ ឬអង្គហេតុនោះយ៉ាងនេះ ឬយ៉ាងនោះទៅវិញ។ ការបកស្រាយទាំងនេះធ្វើឱ្យមានការភាន់ច្រឡំ ហើយនឹងលុបបំបាត់ទៅលើបំណកស្រាយរបស់មហាជនទៅវិញ។ តាមពិតទៅចៅក្រមធ្វើការបកស្រាយបែបនេះ ចៅក្រមនោះមិនបានឈរលើហេតុផលច្បាស់លាស់នោះទេ! ពោលគឺមិនឈរលើមូលដ្ឋាននៃអង្គហេតុដែលកើតមានឡើងឡើ-យ។ ប៉ុន្តែចៅក្រមបែរជាឈរលើមូលដ្ឋាននៃសិទ្ធិអំណាច ដែលខ្លួនជាអ្នកប្រកបរបរវិជ្ជាជីវៈច្បាប់កំពុងតែមាននោះទៅវិញ ហេតុដូច្នេះហើយនាំឱ្យការបកស្រាយនោះបាត់បង់នៅសេចក្តីទុកចិត្តរបស់សាធារណៈជនលើប្រព័ន្ធតុលាការ។

រីឯគូភាគីវិវាទ ត្រូវតែបង្ហាញភស្តុតាងរបស់ខ្លួនដែលអាចបញ្ជាក់អំពីសិទ្ធិរបស់ខ្លួនថាមានសិទ្ធិ រឺក៏ពុំមានសិទ្ធិចំពោះមុខចៅក្រម។ រីឯចៅក្រមវិញត្រូវមានចំណេះដឹងស៊ីជម្រៅហើយត្រូវស្វែងរកភស្តុតាងតាមមធ្យោបាយផ្សេងៗ ដែលនាំមកនូវយុត្តិធម៌ដល់គូភាគីតាមរយៈសេចក្តីសម្រេចរបស់ខ្លួន ម្យ៉ាងទៀតចៅក្រមត្រូវតែប្រកាន់ខ្ជាប់នៅសីលធម៌នៃវិជ្ជាជីវៈរបស់ខ្លួនជាប់ជានិច្ច។

ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់ទៅលើនិយមន័យខាងលើ គប្បីសិក្សាពីការកំណត់និយមន័យនៃភស្តុតាងជាមុនសិន។

### **កថាភាគទី១: ការកំណត់និយមន័យនៃភស្តុតាង**

មុនពេលចាប់ផ្តើមនិយាយអំពីនីតិភស្តុតាង គប្បីតែមានការពិភាគទៅលើគំនិតរបស់ភស្តុតាងថាជាអ្វី? ជាទូទៅយើងត្រូវសិក្សាពីភាពខុសគ្នារវាងភស្តុតាង និងនីតិភស្តុតាងជាមុនសិន។ «ភស្តុតាង»(Evidence) គឺជាពាក្យដែលចេញមកពីពាក្យ LATIN (Evidentia) មានន័យថាការបង្ហាញឱ្យឃើញច្បាស់ ឬធ្វើឱ្យមានពន្លឺច្បាស់លាស់ និងត្រឹមត្រូវដោយធ្វើឱ្យដឹង

ប្រាកដពីព្រឹត្តិហេតុណាមួយ ដែលចៅក្រមត្រូវប្រើគ្រប់មធ្យោបាយផ្សេងៗ[2]ដើម្បីស្វែងរកភ-ស្តុតាងដែលជាក់លាក់។ ហេតុដូច្នេះហើយភស្តុតាង គឺជាអ្វីៗដែលបង្ហាញពីការលេចឡើង ឬក៏បំបាត់ចោលនៃការពិតជាក់ស្តែង។ បើនិយាយពីភាគីសុចរិតគឺធ្វើយ៉ាងណាត្រូវខិតខំប្រើគ្រប់មធ្យោបាយ ដើម្បីស្វែងរកភស្តុតាងក្នុងបំណងគឺធ្វើឱ្យលេចឡើងនៅភាពច្បាស់លាស់ពីសុចរិតភាពរបស់ខ្លួន។ ចំណែកឯភាគីទុច្ចរិតត្រូវខិតខំប្រើគ្រប់មធ្យោបាយធ្វើយ៉ាងណាឱ្យភស្តុតាងនុ៎ះបាត់នូវភាពច្បាស់លាស់របស់វាទៅវិញ បើនិយាយជារួមគឺភាពបន្លំហើយយកមកបង្ហាញនៅចំពោះមុខចៅក្រម គឺក្នុងគោលបំណងចង់បំបាត់ចោលភាពស្របច្បាប់របស់ភាគីវិវាទរបស់ខ្លួន។

ទោះបីជាមានការបកស្រាយនិយមន័យដូចខាងលើក៏ដោយ នៅក្នុងលក្ខខណ្ឌសច្ចភាពនៃភស្តុតាងត្រូវបានយកមកពិចារណាយ៉ាងលម្អិតផងដែរ។ ភស្តុតាងដែលបានឃើញក្នុងការពិពណ៌នានោះមិនអាចហៅថានីតិភស្តុតាងនោះទេ។

នីតិនៃភស្តុតាង វាអាចបង្ហាញឱ្យឃើញច្បាស់ពីសច្ចភាពនៃអង្គហេតុដែលច្បាប់បានកំណត់ នៅក្នុងគោលបំណងបង្ហាញឱ្យឃើញនៅភាពច្បាស់លាស់អំពីភាពសុចរិត ហើយនឹងភាពទុច្ចរិតរបស់គូភាគី រឺបង្ហាញពីសិទ្ធិស្របទៅនឹងច្បាប់របស់បុគ្គលណាម្នាក់រវាងគូភាគីបណ្តឹងនៅចំពោះមុខចៅក្រម។

នីតិភស្តុតាង គឺជាការកំណត់ ឬបង្ហាញឱ្យឃើញភស្តុតាងជាក់ច្បាស់នៅពេលដែលមានវិវាទកើតឡើងក្នុងព្រឹត្តិហេតុមួយពិតប្រាកដ។ ដើម្បីយល់ថាភស្តុតាងណាមួយ គឺជាភ-ស្តុតាងពិត និងភស្តុតាងក្លែងគឺស្ថិតនៅលើការស៊ើបអង្កេតរបស់តុលាការ និងការសន្និដ្ឋានរបស់ចៅក្រម។

ការស៊ើបអង្កេតរបស់តុលាការដោយឆន្ទានុសិទ្ធិ រឺចៅក្រមយល់ឃើញថាវាមានភាពចាំបាច់ និងអាចកំណត់បន្ថែមថាវាជាគំរុយនៃភស្តុតាងថ្មីដែលអាចធ្វើឱ្យអង្គហេតុ ឬក៏ព្រឹត្តិហេតុនុ៎ះ! អាចបង្ហាញកាន់តែច្បាស់លាស់លើភាពសុច្ចរិតនៃភស្តុតាង នោះចៅក្រមនឹងធ្វើការស៊ើបអង្កេតរកមកបន្ថែម។

បើនិយាយពីភស្តុតាងគឺមានច្រើនប្រភេទ ហើយមានតួនាទីក្នុងការផ្តល់នូវភាពស្អាតស្អំក៏ដូចជាការផ្តល់សិទ្ធិទៅឱ្យម្ចាស់សិទ្ធិពិតប្រាកដជាពិសេសក្នុងវិវាទរដ្ឋប្បវេណី។

---

[2] law of evidence prepare by Kahasay Debesu and Andualem Eshetu ទំព័រទី២ឆ្នាំ២០០៩

ចំពោះអត្ថន័យនៃនីតិភស្តុតាង គឺវាអាចមានភាពខុសគ្នាទៅតាមគំនិតរបស់អ្នកនិពន្ធក៏ប៉ុន្តែជាគោលការណ៍ និងគោលបំណងរបស់នីតិភស្តុតាងគឺវាមានភាពដូចគ្នាមិនខុសគ្នានោះទេ។ ចំពោះភាពខុសគ្នានោះគឺគ្រាន់តែជាការពន្យល់បន្ថែមទៅលើអត្ថន័យឬការបន្ថែមព័ត៌មានខ្លះៗទៅលើនិយមន័យនៃនីតិភ្ញុតាងតែប៉ុណ្ណោះ ខណៈដែលគ្មានអ្នកនិពន្ធណាម្នាក់ដែលបានសរសេរដល់ និងមានការវិភាគឱ្យបានស៊ីជម្រៅទៅលើនីតិភស្តុតាងនេះ។

ជាការពិតណាស់នីតិភស្តុតាងក្នុងរឿងរដ្ឋប្បវេណីនេះ វាមានសារសំខាន់ណាស់ទៅលើពាក្យថាភស្តុតាង មិនមែនគ្រាន់តែទទួលបានព័ត៌មានខ្លះៗ ឬក៏ទទួលបានចម្លើយពីសំនួរហើយហៅថាភស្តុតាងពេញលេញបានទេ។ ហេតុដូចនេះហើយចៅក្រមត្រូវធ្វើការវិនិច្ឆ័យយ៉ាងលម្អិត រួមទាំងការធ្វើកោសលវិច័យគ្រប់ភស្តុតាងទាំងអស់ដើម្បីឱ្យមានការសម្រេចសេចក្តីមួយដែលមានតម្លាភាពទៅលើភាគីនីមួយៗ។

**កថាភាគទី២: បទដ្ឋាននៃភស្តុតាង**

បទដ្ឋាននៃភស្តុតាង គឺមានសារសំខាន់ណាស់សម្រាប់អ្នកសិក្សាផ្នែកច្បាប់ បទដ្ឋាននៃភស្តុតាងវាមានទំនាក់ទំនងយ៉ាងស៊ីជម្រៅទៅនឹងបណ្តុំនៃច្បាប់សារធាតុទាំងអស់ ហើយរាល់ការផ្តល់ ឬក៏ការការពារសិទ្ធិឱ្យទៅបុគ្គល រឺក៏នីតិបុគ្គលណាមួយ។ នៅក្នុងវិវាទមួយដែលបានកើតមានឡើង រាល់ការសម្រេចសេចក្តីណាមួយរបស់ចៅក្រម គឺត្រូវផ្អែកទៅលើភស្តុតាងទាំងស្រុងក្នុងការបញ្ជាក់ពីសិទ្ធិរបស់ភាគីណាមួយ។ គ្រប់បណ្តាលបទដ្ឋាននៃភស្តុតាងត្រូវបានគេបែងចែកជាពីរគឺៈ គោលការណ៍ និងសច្ចភាព។

ចំពោះគោលការណ៍វាមានទំនាក់ទំនងជាមួយទស្សនៈ ក្នុងការបង្ហាញអំពីព្រឹត្តិហេតុទៅកាន់តុលាការពីការពិតរបស់គូភាគី ឬក៏ការបញ្ជាក់ពីអនុភាពនៃសិទ្ធិ និងកាតព្វកិច្ចដែលច្បាប់បានផ្តល់ឱ្យ។ ច្បាប់បានកំណត់ពីសិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលម្នាក់ៗ និងនីតិបុគ្គលនៅក្នុងគន្លឹនីមួយៗនៃច្បាប់រដ្ឋប្បវេណីខ្មែរឆ្នាំ២០០៧។ វាពិតជាមានសារសំខាន់ណាស់នៅក្នុងគន្លឹនីមួយៗដែលវាបានកំណត់អំពីសិទ្ធិ និងកាតព្វកិច្ចមានដូចជាសិទ្ធិក្នុងការប្តឹងតវ៉ា ឬក៏បង្កើតកិច្ចសន្យាផ្សេងៗ។

ជាកាពិតណាស់ក្នុងករណីព្រឹត្តិហេតុដែលកើតមានឡើង ហើយនឹងនៅក្នុងអង្គហេតុនោះនឹងរំលេចឡើងឱ្យឃើញនូវភស្តុតាងមួយជាប្រាកដ។ ដូចនេះគោលការណ៍បទដ្ឋាននៃភស្តុតាងគឺចង់ឱ្យមានការវិនិច្ឆ័យមួយដែលមានភាពយុត្តិធម៌ចំពោះភាគីវិវាទ ហើយនឹងការ

ដោះស្រាយឱ្យមានភាពត្រឹមត្រូវចំពោះបណ្តឹងទាមទារ។ រាល់ដំណើការនៃការស៊ើបអង្កេតទាំងអស់គឺចាំបាច់ត្រូវធ្វើការកំណត់ភស្តុតាង និងធ្វើកោសលវិច័យ ដើម្បីធ្វើការវិនិច្ឆ័យឱ្យបានច្បាស់លាស់លើសិទ្ធិគូភាគីវិវាទ។ បទដ្ឋាននៃភស្តុតាង គឺជាបណ្តុំនៃវិធានទាំងឡាយដែលស្ថិតនៅក្នុងស្មារតីក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ២០០៧ ហើយនឹងក្រមនីតិវិធីរដ្ឋប្បវេណីខ្មែរឆ្នាំ២០០៦ដែលបានកំណត់ច្បាស់ពីសិទ្ធិ និងកាតព្វកិច្ច។

យោងតាមការបកស្រាយរបស់សាស្ត្រាចារ្យច្បាប់ គឺលោក«Kahsay Debesu» ដែលជាសាស្ត្រាចារ្យនៅវិទ្យាស្ថានស្រាវជ្រាវយុត្តិធម៌ ហើយនឹងប្រព័ន្ធច្បាប់នៃប្រទេសEthiopia បានបកស្រាយតាមរយៈគំនិតពួកនិស្សិតច្បាប់ថា ចំពោះភស្តុតាងគួរតែដាក់បញ្ចូលជាផ្នែកមួយក្នុងនីតិវិធីច្បាប់ ហើយគោលបំណងរបស់ពួកគេគឺប្រហាក់ប្រហែលគ្នា។

ទោះបីជាយ៉ាងណាក៏ដោយគំនិតរបស់ពួកគេ គឺស្ថិតក្នុងផ្នែកមួយរបស់នីតិភស្តុតាងដែលជាច្បាប់ចាស់របស់ចក្រភពអង់គ្លេសរួចទៅហើយ ប្រទេសអង់គ្លេសក៏បានធ្វើការអនុម័តបន្ថែម ដើម្បីឱ្យមានប្រសិទ្ធិភាពក្នុងការវិនិច្ឆ័យនៅក្នុងតុលាការ[3]។ ចំពោះបទដ្ឋាននៃភស្តុតាងដែលមានចែងនៅក្នុងផ្នែកទី១នៃក្រមនីតិវិធីរដ្ឋប្បវេណីខ្មែរឆ្នាំ២០០៦ ដែលស្ថិតនៅក្នុងជំពូកទី២បានបញ្ញត្តអំពីភស្តុតាង វាពិតជាជួយបានយ៉ាងធំធេងក្នុងការដោះស្រាយរាល់វិវាទដែលបានកើតឡើងយ៉ាងប្រសើរ ហើយអាចឆ្លើយតបទៅនឹងបណ្តឹងទាមទារ ឬក៏ការបន្លំនានាដែលមានទាក់ទងទៅនឹងការស៊ើបអង្កេតក្នុងការប្រមូលភស្តុតាង។ល។... ។

### កថាភាគទី៣: សញ្ញាណនៃភស្តុតាង

សញ្ញាណនៃភស្តុតាង គឺជាការកំណត់ពីភាពខុលគ្នាដែលតម្រូវឱ្យមានការសន្និដ្ឋានមួយនៅក្នុងព្រឹត្តិហេតុនោះថាមានពិត ឬមិនមាន។ ហេតុដូចនេះហើយភស្តុតាងត្រូវបានគេបែងចែកជាពីរគឺៈ ភស្តុតាងពិត ហើយនឹងភស្តុតាងដែលបង្កើតឡើងក្នុងគោលបំណងដើម្បីទទួលបានអ្វីមួយដោយទុច្ចរិត។

ភស្តុតាងពិត គឺជាភស្តុតាងទាំងឡាយណាដែលកើតចេញពីព្រឹត្តិហេតុ ហើយក៏ជាតម្រុយក្នុងការបង្ហាញព្រឹត្តិហេតុនោះ ដែលមាននៅក្នុងបណ្តឹងទាមទាររបស់ភាគីខាងដើមបណ្តឹង។ ម្យ៉ាងវិញទៀតភស្តុតាងនេះ គឺអាចកើតមានតាមរយៈសាក្សីក្នុងការផ្តល់សក្ខីកម្ម

[3] Law of Evidence prepared by Kahsay Debesu ll.b, lecture in 2009 page 6

នៅក្នុងនីតិវិធីនៃការសាកសួរសាក្សីដោយផ្ទាល់មាត់ ហើយសាក្សីបានបង្ហាញពីអ្វីៗដែលគេបានដឹង និងបានឮ។

នៅក្នុងការកំណត់សញ្ញាណនៃភស្តុតាងមានដូចជា៖ កិច្ចសន្យា លិខិតយថាភូត ឬក៏ឯកតភូត រូបថត ហត្ថលេខា ត្រា ហើយនឹងអ្វីៗទាំងអស់ដែលត្រូវយកមកបង្ហាញនៅចំពោះមុខចៅក្រម ដែលនាំឱ្យចៅក្រមយល់បានថាខ្លួនពិតជាម្ចាស់សិទ្ធិពិតប្រាកដមែន។

ហើយមានភស្តុតាងមួយចំនួនទៀតដូចជា៖ ខ្ចៅដៃ សក់ ឈាម សម្លាកដែលនៅលើផ្នែកណាមួយនៃរាងកាយ...។

សម្រាប់ហេតុផលទាំងអស់នេះ គឺជាសញ្ញាណនៃភស្តុតាងហើយនឹងអាចនាំឱ្យការសន្និដ្ឋានមួយរបស់ចៅក្រមគឺមានការអះអាងច្បាស់លាស់ ហើយនឹងអាចប្រាប់បានថាព្រឹត្តិហេតុនោះបានកើតឡើង ឬក៏មិនបានកើតឡើង។ សញ្ញាណនៃភស្តុតាងនេះ វាពិតជាមានការខ្វះខាតដើម្បីធ្វើការបញ្ជាក់ឱ្យបានច្បាស់អំពីនត្ថិភាពសិទ្ធិ និងអត្ថិភាពនៃសិទ្ធិរបស់ដើមបណ្តឹង និងចុងចម្លើយ។

ដូច្នេះហើយចៅក្រមត្រូវរកឱ្យឃើញនូវតម្រុយផ្សេងៗ និងអាចនាំឱ្យមានកាសម្រេចសេចក្តីដោយយុត្តិធម៌ ហេតុដូច្នេះហើយចៅក្រម និងអ្នកច្បាប់ត្រូវសិក្សាបន្ថែមទៅលើការវិវត្តន៍នៃភស្តុតាងដើម្បីទទួលបានភាពស៊ីជម្រៅនៃនីតិភស្តុតាងមួយនេះ។

### ផ្នែកទី២: ការវិវត្តន៍នៃបទដ្ឋាននៃភស្តុតាង

ការវិវត្តន៍នៃបទដ្ឋាននៃភស្តុតាង គឺជាការរកឃើញរបស់ចៅក្រម ឬក៏តាមរយៈយុត្តិសាស្ត្ររបស់តុលាការដែលពុំទាន់មានច្បាប់ចែង ហើយតុលាការបានសម្រេចសេចក្តីដោយផ្អែកទៅលើរបកគំហើញថ្មីៗនៃភស្តុតាងដើម្បីការពារចំពោះជនសុចរិត។

ដោយសារតែមានការបំពានលើសិទ្ធិ និងការមិនព្រមទទួលស្គាល់ថាបុគ្គលណាម្នាក់មានសិទ្ធិ ឬក៏ការបដិសេធចំពោះមុខតុលាការពីកំហុសរបស់ខ្លួនន៎ះ! ទើបនាំឱ្យភស្តុតាងមានការវិវត្តន៍ឡើងនឹងមានភាពច្បាស់លាស់ថានរណាគឺត្រូវបានទទួលសិទ្ធិ រឺអាចបាត់សិទ្ធិរបស់ខ្លួន។ ការដែលរកឱ្យឃើញនៅរបកគំហើញថ្មីៗនៃភស្តុតាង គឺដើម្បីកំណត់អង្គហេតុមួយឱ្យបានច្បាស់លាស់ និងពិតប្រាកដ។ ជាទូទៅអង្គហេតុនោះត្រូវតែបញ្ចេញឱ្យឃើញនៅភស្តុតាងមួយដែលស្របទៅនឹងអង្គហេតុដែលបានកើតឡើង។

ការបញ្ចេញឱ្យឃើញរបកគំហើញនុ៎ះ! គឺជាការរកឃើញតាមរយៈបុគ្គលណាម្នាក់ឬច្រើននាក់ដែលអាចស្គាល់ រឺអាចដឹងនូវអ្វីៗពីអង្គហេតុនោះបានច្បាស់លាស់(*សាក្សី*)[4]។ នៅក្នុងរឿងក្ដីរដ្ឋប្បវេណីសាក្សី គឺជាអ្នកបង្ហាញឱ្យឃើញនូវភាពសមស្របនឹងបញ្ជាក់បន្ថែមលើភស្តុតាងរបស់ដើមចោទ រឺរបស់ចុងចម្លើយដែលសាក្សីនោះមកធ្វើការបង្ហាញនៅចំពោះមុខចៅក្រមដើម្បីបញ្ជាក់បន្ថែមទៅលើភស្តុតាងរបស់គូភាគីណាមួយ។

ភស្តុតាងជាសម្ភារៈ[5] គឺជាវត្ថុហើយវត្ថុនោះអាចបង្ហាញឱ្យឃើញច្បាស់លាស់ និងភាពសមស្របនៃអង្គហេតុ ដើម្បីបង្ហាញទៅដល់ចៅក្រមក្នុងការវិនិច្ឆ័យទៅលើភាពត្រឹមត្រូវរបស់ភាគីណាមួយ។

ភស្តុតាងជាឯកសារ គឺត្រូវបានបង្ហាញតាមរយៈការស្នើសុំរបស់គូភាគីណាមួយដែលបានដាក់ពាក្យស្នើសុំទៅតុលាការ។ តុលាការនឹងបង្គាប់ឱ្យម្ចាស់ឯកសារដែលជាតតីយជនត្រូវផ្ដល់ឯកសារដែលខ្លួនមាន រឺគូភាគីណាមួយយកមកបង្ហាញឱ្យឃើញច្បាស់លាស់ពីភាពត្រឹមត្រូវនៃអង្គហេតុ។ ការបញ្ចេញភស្តុតាងទាំងឡាយដែលបង្ហាញឱ្យឃើញពីអត្ថិភាពនៃអង្គហេតុ វាគឺជាការចាំបាច់សម្រាប់ចៅក្រមធ្វើការសម្រេចសេចក្ដីដោយយុត្តិធម៌។

ផ្ទុយទៅវិញប្រសិនបើភស្តុតាង គឺជាភស្តុតាងដែលមិនអាចបញ្ជាក់បានអំពីនត្ថិភាពនៃអង្គហេតុវិញនោះ ដូច្នេះវាគឺជាឧបសគ្គក្នុងការស្វែងរកភាពត្រឹមត្រូវនៃអង្គហេតុនោះ ក្នុងករណីអង្គហេតុមួយដែលគេមិនអាចធ្វើការបញ្ជាក់ ឬក៏បង្ហាញនូវខណៈនានាដែលបានកើតមានឡើងលើអង្គហេតុណាមួយនុ៎ះទេ! ដូច្នេះអ្វីដែលបានបង្ហាញទាំងនោះមិនមែនជាកម្មវត្ថុនៃសក្ខីកម្មទេ ។

គ្រប់អង្គហេតុទាំងអស់ ប្រសិនណាគ្មានកម្មវត្ថុក្នុងការយកមកបង្ហាញបញ្ជាក់ទៅលើសក្ខីកម្មនៃអង្គហេតុនោះបានទេ! មានន័យថាវាមិនអាចវាយតម្លៃទៅលើអង្គហេតុនោះបានឡើយព្រោះវាជាអង្គហេតុប្រឌិត។

ឧទាហរណ៍៖ បុគ្គល«ក» គឺជាចាងហ្វាងនៃក្រុមហ៊ុនទឹកបរិសុទ្ធគូលែន ដែលបានចុះបញ្ជីត្រឹមត្រូវ ហើយនឹងមានការការពារនូវពាណិជ្ជនាមរបស់ខ្លួនក្នុងការធ្វើពាណិជ្ជកិច្ចលក់ទឹកបរិសុទ្ធទៅតាមច្បាប់បានកំណត់។ ដោយគាត់បានប្រកបមុខរបរនេះអស់រយៈពេល២០ឆ្នាំមកហើយ គាត់ក៏បានធ្វើការចុះបញ្ជីជាថ្មីទៅតាមកំណត់របស់ច្បាប់ដែលមានការណែនាំ

[4] មាត្រា១៣២កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦
[5] មាត្រា១៨៨កថាខណ្ឌទី១នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

ពីមន្ត្រីកាន់កាប់បញ្ជីនៅថ្ងៃ៣០ ខែមករា ឆ្នាំ២០១៦។ ស្រាប់តែពេលនោះមានបុគ្គល«ខ» បានមកប្តឹងបុគ្គល«ក»ពីបទក្លែងពាណិជ្ជនាម ពីព្រោះគាត់មានពាណិជ្ជនាមទឹកសុទ្ធឈ្មោះ ថា«អ៊ីគូលែន» ដោយសុំឱ្យតុលាការធ្វើការពិន័យទៅកាន់ចាងហ្វាងទឹកបរិសុទ្ធនោះអំពីការ ខាតបង់របស់គាត់។ តើគាត់ត្រូវមានអ្វីមកបង្ហាញដល់ចៅក្រមដើម្បីវិនិច្ឆ័យទៅតាមសំណូម ពររបស់គាត់បាន? បើគាត់ពុំបានទាំងចុះបញ្ជីពាណិជ្ជកម្មផង និងបានប្រើពាណិជ្ជនាមស្រ ដៀងនឹងពាណិជ្ជនាមរបស់លោក«ក»ទៀតនោះដូច្នេះអ្វីទាំងនេះវាគឺជារឿងប្រខិត។

ពីព្រោះថាគ្រប់វត្ថុតាងទាំងអស់ វាគឺបានផ្សាភ្ជាប់ទៅនឹងកម្មវត្ថុនៃសក្ខីកម្មដោយនៅ ក្នុងនោះមានការបញ្ជាក់បែបនេះថា តើអង្គហេតុណាមួយដែលមានការជាប់ទាក់ទងគ្នាក្នុង ការបង្ហាញសក្ខីកម្មនោះ?

ឧទាហរណ៍៖ ដូចការបង្ហាញរបស់លោក«ខ» សកម្មភាពនៃការបំភ្លឺ និងការធ្វើកោស លវិច័យទៅលើឯកសារទាំងឡាយរបស់លោក«ខ» ដែលគាត់យកមកបង្ហាញនៅចំពោះមុខ ចៅក្រមគឺគ្មានភាពប្រក្រតី ដូច្នេះភស្តុតាងដែលយកមកបង្ហាញ គឺជាភស្តុតាងក្លែងមកធ្វើ ការប្តឹងចោទទៅលើលោក«ក»។

ដើម្បីធ្វើការវិនិច្ឆ័យឱ្យប្រកបដោយភាពត្រឹមត្រូវ ដូច្នេះហើយចៅក្រមត្រូវធ្វើការពិនិ-ត្យភស្តុតាងដោយសម្ងហរិធីដើម្បីឱ្យមានភាពច្បាស់លាស់លើអង្គហេតុនីមួយៗ នៅក្នុងការ សម្រេចសេចក្តីឱ្យមានភាពយុត្តិធមិចំពោះភាគីណាដែលត្រូវគេបំពានលើសិទ្ធិ។ ក្នុងអត្ថ ន័យនេះផងដែរយើងត្រូវសិក្សាទៅលើទស្សនៈមួយចំនួន ដើម្បីទទួលបានពុទ្ធិនៅក្នុងនីតិ ភស្តុតាងនេះឱ្យកាន់តែមានភាពច្បាស់លាស់។

### កថាភាគទី១: ទស្សនៈវិទ្យានៃភស្តុតាង

អត្ថន័យនៃភស្តុតាង យើងអាចសិក្សាបានតាមបែបទស្សនៈវិជ្ជាបានតាមរយៈទស្ស-នៈរបស់សូក្រាត ខណៈដែលសូក្រាតបានធ្វើការការពារខ្លួនពីតុលាការក្រុងអាថែននៅក្នុង គ្រាដែលសូក្រាតបានតតាំងជាមួយនឹងការចោទប្រកាន់របស់ចៅក្រម។ ដែលចៅក្រមទាំង នោះបានចោទគាត់ថា ជាអ្នកដឹកនាំក្រុមយុវជនក្នុងការប៉ះបោរប្រឆាំងនឹងរបបស្តេចអាថែន ដោយអយុត្តិធម៌[6]។ ប្លាតុង គឺជាសាវ័កដ៏ខ្លាំងរបស់សូក្រាតបានរកឃើញអធិករណ៍[7]ជាសតិ

[6] សៀវភៅរៀបរៀងដោយ លោក សុខសូផាត បោះពុម្ពលើកទី៣ ១៥.១១.២០១០ជីវិតចុងក្រោយរបស់សូក្រាត ទំព័រ៧២

[7] អធិករណ៍ មានន័យ ការអះអាង

អវិប្បវាស[8] វាគឺជាមូលដ្ឋាននៃទស្សនៈចុងក្រោយរបស់សូក្រាត ដែលបាននាំឱ្យអ្នកសិក្សាអាចយល់ច្បាស់អំពីភស្តុតាងនៅក្នុងសម័យមុននោះ។

ប្លាតុងគឺជាអ្នកសរសេរបានច្បាស់លាស់អំពីអធិករណ៍ នៅក្រោយពេលដែលសូក្រាតទទួលមរណភាពដោយសារផឹកថ្នាំបំពុល។ ស្នាដៃដែលបានសរសេររបស់ប្លាតុងមានការឃើតយ៉ាវបន្តិចបន្តួច ក៏ប៉ុន្តែមានលក្ខណៈល្អិតល្អន់។ ជាងនេះទៅទៀតប្លាតុងអាចសរសេរពង្រីកបន្ថែមអំពីមនុស្សនៅក្រុងអាថែនឱ្យបានរៀនសូត្រតាមលំអានរបស់សូក្រាត និងបានយល់ដឹងអំពីអធិករណ៍នេះក្នុងការផ្តន្ទាទោសយ៉ាងអយុត្តិធម៌ចំពោះសូក្រាត។ ចំពោះស្នាដៃនេះផងដែរប្លាតុងបានសរសេរពីវិធីការពារខ្លួនរបស់សូក្រាត ដែលប្លាតុងចង់បង្ហាញពីគំនិតសីលធម៌របស់សូក្រាត គំនិតប្លាតុងចង់បញ្ជាក់ថា សូក្រាតមិនបានដឹកនាំក្រុមយុវជនដើម្បីធ្វើការប៉ះបោរប្រឆាំងនឹងស្តេចអាថែនដូចការចោទប្រកាន់នោះទេ! ហើយនឹងបានសរសេរអំពីអ្នកដែលបានគាំទ្រសូក្រាតនៅក្នុងតុលាការថែមទៀតផង។

អ្នកដែលគាំទ្រនោះ គឺជាសាក្សីក្នុងការបញ្ជាក់ពីភាពស្អាតស្អំរបស់សូក្រាត រួមទាំងសេចក្តីថ្លែងការណ៍របស់សូក្រាតផងដែរ ទាំងអស់នេះគឺចង់បញ្ជាក់ថាវាជាភស្តុតាងក្នុងការការពារខ្លួនរបស់សូក្រាតនៅចំពោះមុខតុលាការក្រុងអាថែន។

ការកំណត់ភស្តុតាងតាមទស្សនៈ គឺជាការកំណត់ដែលចេញពីប្រភពនៃទ្រឹស្តី ក្នុងរយៈកាលវេលាជាច្រើនសតវត្សមកហើយតាំងពីជំនាន់គ្រិចបូរាណមកម្លេះ។ បើយើងសិក្សាពីប្រវត្តិសាស្ត្រមួយនេះយើងដឹងថា«ជនជាតិអេហ្ស៊ីប» និង«ជនជាតិមេសូពូតាម៉ង់» ហើយជនជាតិទាំងពីរនេះមានទស្សនៈខុសគ្នាទៅលើនីតិភស្តុតាង ដែលមានការជាប់ទាក់ទងទៅនឹងករណីកិច្ចនៃភស្តុតាង ហើយនិងគោលការណ៍របស់ភស្តុតាង។

ភស្តុតាង ដែលបានបញ្ជាក់ដោយសាក្សីគឺមានមកជាច្រើនសតវត្សណាស់មកហើយដែរ ហើយក្នុងព្រឹត្តិហេតុនេះពួកគេមិនបានស្គាល់ច្បាស់ ឬយល់ច្បាស់នៅចំណុចសំខាន់របស់នីតិភស្តុតាងនោះទេ។

វត្តមាននៃករណីកិច្ចភស្តុតាងរួមទាំងគោលការណ៍នៃភស្តុតាង គឺជាលទ្ធផលនៃការបង្ហាញឱ្យឃើញច្បាស់នៃព្រឹត្តិហេតុពិតនៅក្នុងរឿងវិវាទ ទាំងនេះគឺជាការយល់ឃើញរបស់

[8] សតិអវិប្បវាស មានន័យការយល់ដឹងស៊ីជម្រៅ ឬលម្អិត

ជនជាតិអេហ្ស៊ិប ក៏ប៉ុន្តែពួកគេមិនបានចែកឱ្យបានច្បាស់លាស់ថាអ្វីជាភស្តុតាងក្នុងរឿងរដ្ឋប្បវេណី និងភស្តុតាងក្នុងរឿងព្រហ្មទណ្ឌនៅឡើយទេ[9]។

ចំណែកឯជនជាតិមេសូពូតាម៉ង់ បានយល់ផ្សេងពីជនជាតិខាងលើដោយសារតែពួកគេមានជំនឿយ៉ាងមុតមាំទៅលើសាសនារបស់ពួកគេ។ ការស្វែងយល់ពីភស្តុតាងគឺពឹងផ្អែកទាំងស្រុងតាមរយៈចិត្តវិទ្យាអនុវត្តន៍តាមជំនឿនៃសាសនារបស់គេ។

បើយើងក្រលេកមើលពីប្រវត្តិរបស់ជនជាតិ«មេសូពូតាម៉ង់» ឥទ្ធិពលនៃសាសនាគឺវាមានភាពមុតមាំក្នុងចិត្តរបស់ពួកគេ។ ដូច្នេះហើយជនជាតិនេះស្វែងរកភស្តុតាងតាមរបៀបចិត្តសាស្ត្រនៃសាសនាដែលពួកគេមានជំនឿនុ៎ះ! ។

### កថាភាគទី២: ករណីនាំឱ្យមានភស្តុតាង

ភស្តុតាងបានកើតឡើង គឺអាស្រ័យទៅលើព្រឹត្តិហេតុទាំងឡាយដែលបានកើត និងនាំឱ្យមានសកម្មភាពផ្សេងៗនៅក្នុងការទំនាក់ទំនងគតិយុត្តមានដូចជាៈ កិច្ចសន្យា ការទាមទារទទួលស្គាល់បុត្រភាព ការទាមទារស្គាល់បិតុភាព ការផ្តាច់មរតក កិច្ចសន្យាប្រទានកម្ម ការបង្កើតអាពាហ៍ពិពាហ៍ ការលុបចោលអាពាហ៍ពិពាហ៍ កិច្ចសន្យាបញ្ចាំ....។

បាតុភូតទាំងឡាយដែលបានកើតឡើងហើយនាំមកនៅវិវាទដល់គូរភាគី ហើយនឹងធ្វើឱ្យភាគីទាំងសងខាងមិនអាចធ្វើការសម្របសម្រួលគ្នាបាន វាជាហេតុនាំឱ្យភាគីនីមួយៗចង់បានផលប្រយោជន៍រៀងៗខ្លួន។ ហេតុដូចនេះហើយទើបធ្វើឱ្យភាគីទាំងពីរក្នុងរឿងវិវាទមិនអាចមានភាពចុះសម្រុងនឹងគ្នាទេ បើយោងទៅលើទស្សនៈរបស់ព្រះបរមគ្រូដោយហេតុតែបុគ្គលម្នាក់ៗមិនអាចរម្ងាប់នៅកិលេសតណ្ហារបស់ខ្លួនបាន ជាហេតុនាំឱ្យកើតមានឡើងនៅមហិច្ឆតាក្នុងចិត្ត ហើយនាំឱ្យចិត្តរបស់មនុស្សមានការហួងសៅទើបកើតជាការចង់បាននឹងមានភាពលំអៀង និងក្តីស្រលាញ់កើតមានឡើង។

ហេតុដូច្នេះហើយទើបការដោះស្រាយវិវាទតម្រូវឱ្យមានតតីយជនចូលរួម ហើយតតីយជននោះគ្មានភាពលំអៀង និងមានចំណេះដឹងខ្ពង់ខ្ពស់ផ្នែកច្បាប់ក្នុងការសម្របសម្រួលក្នុងវិវាទទាំងអស់នោះ។ យោងតាមគោលការណ៍ច្បាប់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីខ្មែរឆ្នាំ ២០០៦ ជាគោលការណ៍ក្នុងការសម្រេចសេចក្តីរបស់ចៅក្រម គឺផ្អែកទៅលើភស្តុតាងជាសំខាន់ ដូច្នេះហើយភស្តុតាងវាកើតចេញពីព្រឹត្តិហេតុ ឬអង្គហេតុដែលជាសកម្មភាពរបស់

[9] law of evidence prepared by Kahsay Debesu and Andualem Eshetu ទំព័រទី១១

គូភាគីដែលមានវិវាទ។ តែបើចំពោះចៅក្រមត្រូវមានចំណេះដឹងស៊ីជម្រៅខាងផ្នែកច្បាប់ក្នុងការបែងចែក ឬធ្វើចំណាត់ថ្នាក់នៃភស្តុតាង ដើម្បីឱ្យមានភាពច្បាស់លាស់ក្នុងការវិនិច្ឆ័យ។

### កថាភាគទី៣: ចំណាត់ថ្នាក់នៃភស្តុតាង

បើយោងតាមស្មារតីរបស់ច្បាប់គ្រប់ប្រភេទ គេត្រូវគោរពនូវគោលការណ៍សមហេតុសមផលណាមួយហើយហេតុផលទាំងអស់នោះ គឺជាភស្តុតាង រឺសក្ខីកម្មដែលជាពន្លឺនៃការវិនិច្ឆ័យដែលប្រកបដោយភាពយុត្តិធមិចំពោះគូភាគី។ ដើម្បីពង្រឹងធាតុនីត្យានុកូលភាពនៃច្បាប់ឱ្យប្រព្រឹត្តទៅដោយមានតម្លាភាពនោះ អ្នកច្បាប់តែងបានកំណត់នៅចំណាត់ថ្នាក់នៃភស្តុតាងដើម្បីឱ្យមានភាពងាយស្រួលក្នុងការយល់ដឹងទៅលើខ្លឹមសារ ឬអត្ថន័យរួមនៃភស្តុតាងចាំបាច់តម្រូវឱ្យមានការរែកញែកនូវខ្លឹមសារទាំងនោះដាក់តាមក្រុមរបស់វានីមួយៗ។

ការដាក់ខ្លឹមសារតាមក្រុមនីមួយៗរបស់វា គឺជាការបង្ហាញនូវចំណាត់ថ្នាក់ទៅលើខ្លឹមសារនៃភស្តុតាង ប៉ុន្តែវាពុំមានន័យថាចាត់ថ្នាក់នៃប្រភេទភស្តុតាងនោះទេ គឺសំដៅលើខ្លឹមសារតែប៉ុណ្ណោះ។ ចំណែកប្រភេទនៃភស្តុតាងវិញគឺសំដៅទៅលើគ្រប់មធ្យោបាយនានានៃការប្រមូលផ្តុំភស្តុតាងទាំងអស់[10] ដែលគេហៅថាប្រព័ន្ធនៃភស្តុតាង។

ការប្រមូលផ្តុំនៃភស្តុតាង គឺចង់ឱ្យមានភាពងាយស្រួលក្នុងការធ្វើសម្រេចសេចក្តីរបស់ចៅក្រមដោយពឹងផ្អែកទៅលើភស្តុតាង ដែលឈានទៅរកការសម្រេចក្តីមួយធ្វើឱ្យគូភាគីអាចទទួលយកបាន ហើយនឹងមានការអស់ចិត្ត។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក៏ភាគីដែលចាញ់នៅមានការជំទាស់ដដែល ពីព្រោះថាភាគីដែលបានចាញ់ក្តីចង់រក្សានូវកិត្តិយសរបស់គេនៅចំពោះមុខសាធារណៈជន និងគូភាគីវិវាទ ដោយសារតែភស្តុតាងមានការបែងចែកនឹងមានភាពច្បាស់លាស់ហើយនោះ ធ្វើឱ្យភាគីដែលចាញ់ក្តីទទួលយកដោយស្ងាត់ៗនៅក្នុងចិត្តរបស់គេដោយមិនប្រកែកបាន។

ដូច្នេះការចាត់ថ្នាក់នៃភស្តុតាងគឺគេទាញយកពីខ្លឹមសារ ឬក៏ពីអត្ថន័យនៃទ្រឹស្តីភស្តុតាងមានដូចជាកម្មវត្ថុនៃភស្តុតាងក្នុងការដាក់បន្ទុក និងភស្តុតាងក្នុងការដោះបន្ទុក ដើម្បីធ្វើការចំណាត់ថ្នាក់នៃភស្តុតាង។ ដូចនេះចៅក្រមត្រូវពិនិត្យមើលទៅលើឯកសារត្រៀម[11] ទាំងឡាយដែលគូភាគីវិវាទដាក់ចូលមកតុលាការ។ នៅក្នុងន័យនេះដែរមានន័យថានៅក្នុង

[10] អត្ថបទទី៣៖ ការចាត់ថ្នាក់លើទម្រង់នៃភស្តុតាងដោយ : អ៊ិន បូផា ទំព័រ៩៥

[11] មាត្រា១០១ នៃក្រមនិតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ទំព័រ៨១

នីតិវិធីត្រៀម តុលាការចាំបាច់ត្រូវពិនិត្យទៅលើឯកសាររបស់ចុងចម្លើយដែលបានដាក់ចូលតុលាការលើដំបូងហៅថា«ឯកសារចម្លើយ»[12] គឺចង់បញ្ជាក់អំពីអំណាចរបស់តុលាការដែលបង្គាប់ឱ្យភាគីដាក់នៅឯកសារត្រៀមទាំងឯកសាររបស់ចុងចម្លើយ ហើយនឹងឯកសារត្រៀមរបស់ដើមចោទ។

ឯកសារត្រៀម គឺជាបញ្ជាក់ពីចំនុចដែលទាមទារ និងការការពាររួមទាំងការតទល់គ្នារវាងគូភាគីផងដែរ ហើយវាក៏ជាឯកសារដ៏សំខាន់សម្រាប់ធ្វើការដោះស្រាយបណ្ដឹងឱ្យមានភាពឆាប់រហ័សដែលតុលាការបានធ្វើការបែងចែក និងការដាក់ចំណាត់ថ្នាក់ដោយផ្អែកនៅលើឯកសារទាំងអស់នេះដើម្បីធ្វើការរៀបចំនៅចំនុចដែលមានវិវាទ ហើយនឹងចំណុចដែលគ្មានវិវាទដែលអាចឈានទៅរកការសម្រេចសេចក្ដីមួយដ៏យុត្តិធម៌បំផុត។

នៅក្នុងរឿងវិវាទមួយ ដើមចោទត្រូវតែមានការបង្ហាញនូវភស្តុតាងដាក់បន្ទុកទៅលើចុងចម្លើយអំពីការរំលោភមកលើសិទ្ធិរបស់ខ្លួនដែលមាន។ ក្នុងករណីការបង្ហាញភស្តុតាងរបស់ដើមចោទ ប្រសិនបើមានការខ្វះខាតនូវចំណុចណាមួយក្នុងការដាក់បន្ទុក ដើមចោទអាចធ្វើការស្នើសុំដីការសម្រេចរបស់តុលាការ។ ហើយតុលាការនឹងបង្គាប់ឱ្យតតីយជនផ្ដល់ឯកសារតាមពាក្យស្នើរសុំរបស់ខ្លួនដែលមានហេតុផលត្រឹមត្រូវ។

ពាក្យស្នើសុំដីកាបង្គាប់ គឺត្រូវធ្វើឡើងដោយអនុលោមទៅតាមច្បាប់ និងបញ្ជាក់ឱ្យបានច្បាស់លាស់នូវចំណុចនីមួយៗមានដូចតទៅ៖ ពាក្យស្នើសុំត្រូវធ្វើជាលាយល័ក្ខអក្សរដែលមានចំណងជើង ខ្លឹមសារនៃឯកសារ ឈ្មោះម្ចាស់ឯកសារ និងអង្គហេតុដែលត្រូវបញ្ជាក់បំភ្លឺ។ ភាគីម្ខាងទៀតអាចមានយោបល់លើពាក្យស្នើសុំបាន ហើយត្រូវធ្វើជាលាយល័ក្ខអក្សរស្ដីពីយោបល់របស់ខ្លួនទៅតុលាការ[13]ដូចបានរៀបរាប់ខាងលើនេះស្រាប់ នៅក្នុងករណីនេះដែរ ប្រសិនជាតុលាការយល់ឃើញថាត្រឹមត្រូវហើយនោះ ហើយវាជាមូលដ្ឋានគ្រឹះនៃការបង្ហាញឱ្យឃើញអំពីនត្ថិភាព និងអត្ថិភាពនៃសិទ្ធិភាគី។ តុលាការត្រូវចេញដីកាបង្គាប់នេះដើម្បីទទួលបានឯកសារបន្ថែមដែលជាចំណុចសំខាន់នៃភស្តុតាង ឬជាមូលដ្ឋានគ្រឹះនៃភស្តុតាង ។

[12] មាត្រា១៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ទំព័រ៦៦

[13] មាត្រា១៥១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ទំព័រ ៦១

# ជំពូកទី២
# គោលការណ៍ទូទៅនៃភស្តុតាង

## ផ្នែកទី១: គោលការណ៍សម្រេចសេចក្ដីនៃភស្តុតាង

យោងតាមគោលការណ៍នៃវិទ្យាសាស្ត្រច្បាប់ គេបានត្រូវបែងចែកភស្តុតាងជាប្រព័ន្ធ ដើម្បីធ្វើការវិនិច្ឆ័យឱ្យបានច្បាស់លាស់ទៅលើអង្គហេតុនីមួយៗ។ នៅក្នុងរឿងក្ដីរដ្ឋប្បវេណី ចៅក្រមត្រូវបែងចែកភស្តុតាងជាប្រព័ន្ធ ដើម្បីស្វែងរកនូវដំណោះស្រាយដោយយុត្តិធម៌ទៅដល់គូរភាគី។

ក្នុងគោលបំណង គឺចង់ឱ្យគូភាគីអស់ចិត្តហើយនឹងព្រមទទួលយកលទ្ធផលតាមការសម្រេចរបស់ចៅក្រមក្នុងរឿងក្ដីរដ្ឋប្បវេណី។ ពីព្រោះថាគ្រប់អង្គហេតុទាំងអស់សុទ្ធតែមានការពាក់ព័ន្ធទៅនឹងរឿងវិវាទដែលកើតឡើងណាមួយជាប្រាកដ ព្រោះថាអង្គហេតុទាំងនោះវាអាចបញ្ជាក់ពីខ្លឹមសារនៃវិវាទ ហើយនឹងអាចចង្អុលបង្ហាញឱ្យឃើញនូវភស្តុតាង ឬក៏កម្មវត្ថុបញ្ជាក់អំពីសក្ខីកម្មដែលត្រូវយកមកធ្វើការពិនិត្យពីភាពត្រឹមត្រូវ ហើយនឹងភាពមិនត្រឹមត្រូវរបស់វា។ ដោយសារតែការលេចចេញនូវកម្មវត្ថុនៃភស្តុតាងនេះហើយ ទើបកម្មវត្ថុនៃសក្ខីកម្មមានភាពខុសៗគ្នាជាច្រើននៅលើអង្គហេតុ តាមរយៈការធ្វើនីតិវិធីត្រៀមទាញហេតុផលដោយផ្ទាល់មាត់ រឺក៏ឯកសារត្រៀម ឬអាចហៅថាឯកសារចម្លើយរបស់គូភាគីវិវាទនាំឱ្យមានការលេចឡើងនៅភស្តុតាង និងកម្មវត្ថុសក្ខីកម្មជាច្រើន។ ដោយសារតែមានការបញ្ជាក់ពីសក្ខីកម្មខុសៗគ្នាចំពោះអង្គហេតុនេះហើយ ទើបឱ្យចៅក្រមត្រូវតែមានជំនាញធ្វើការបែងចែកប្រព័ន្ធភស្តុតាង ឬប្រភេទនៃភស្តុតាង។

ឧទាហរណ៍៖ មានម្ចាស់ដីមួយកន្លែងដែលគាត់មានដីនៅខេត្តសៀមរាបម្ចាស់ដីនេះមានឈ្មោះថាលោក«ដា»។ គាត់ក៏កើតមានវិវាទជាមួយគូរភាគីរបស់គាត់ឈ្មោះ«ធី» ហើយឈ្មោះ«ធី»នេះបានអះអាងថា ដីនេះជារបស់គាត់ដែលទិញពីឈ្មោះ«សុរិយា»ក្នុងឆ្នាំ២០១២មកម្លេះ។ ហេតុដូច្នេះភាគីវិវាទត្រូវបានតម្រូវឱ្យមានការដាក់នៅភស្តុតាងដែលមានការពាក់ព័ន្ធទាំងឡាយ ដោយយោងតាមក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ក្នុងផ្នែកទី២(ឯកសារត្រៀម) និងផ្នែកទី៣ (នីតិវិធីត្រៀមទាញហេតុផល) នៅក្នុងផ្នែកទី២ និងផ្នែកទី៣នេះនាំឱ្យមានការលេចឡើងនៅភស្តុតាងជាច្រើន និងមានការអះអាងខុសៗគ្នា មានដូចជាសាក្សី និងឯកសារផ្សេងៗនៅក្នុងឯកសារទាំងនោះមានលេចចេញ ហត្ថលេខា ត្រា និងឈ្មោះអ្នកដែលបានចុះហត្ថលេខា និងការបោះត្រាជាដើម។ សញ្ញាណទាំងអស់វាជាភស្តុតាងដែល

នាំឱ្យចៅក្រមកំណត់បានពីភាពស្របច្បាប់របស់ភាគីណាមួយ និងអ្នកដែលអាចផ្តល់សក្ខីកម្មបានតាមរយៈឯកសារដែលបានដាក់ដោយគូភាគីវិវាទ។

ម្យ៉ាងវិញទៀត ភស្តុតាងទាំងនេះនឹងបង្ហាញឱ្យបានឃើញពីនត្ថិភាព និងអត្ថិភាពនៃសិទ្ធិដែលមានការពាក់ព័ន្ធទៅនឹងអង្គហេតុខាងលើ។ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីបើយើងនិយាយអំពី សាក្សី កិច្ចសន្យាផ្សេងៗ លិខិតយថាភូត និងការបំភ្លឺរបស់គូរភាគីទាំងអស់នេះគឺជាភស្តុតាង ហើយវាជាប្រភពព័ត៌មាននានាដែលអាចផ្តល់ឱ្យចៅក្រមបានដឹងទៅលើកម្មវត្ថុនៃអង្គហេតុនោះដែរ។

ជាការពិតប្រភេទនៃភស្តុតាង គឺជាមធ្យោបាយមួយសម្រាប់រុករកឱ្យឃើញនូវការពិតទៅលើអង្គហេតុក្នុងរឿងក្តីនានា ក៏ប៉ុន្តែក្នុងរឿងរដ្ឋប្បវេណីការរុករកភស្តុតាង គឺមិនមែនធ្វើការចាប់បង្ខំឱ្យគូភាគីបង្ហាញភស្តុតាងនោះទេ។ ផ្ទុយមកវិញគូភាគីត្រូវបង្ហាញដោយខ្លួនឯងនូវសេចក្តីសំអាងដោយផ្អែកលើភស្តុតាង ហើយភស្តុតាងនោះនឹងបញ្ជាក់អំពីសិទ្ធិរបស់ខ្លួនដែលមាននៅលើកម្មវត្ថុនៃវិវាទនោះ។

យោងតាមមូលដ្ឋាននៃគោលការណ៍ការសម្រេចសេចក្តីនៃភស្តុតាង ទើបក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់អំពីទម្រង់នៃភស្តុតាងឡើងនៅក្នុង«ជំពូកទី៣» ដែលចែងពីខ្លឹមសារលើការដកសិទ្ធិពីភាគីទុច្ចរិតហើយនឹងការផ្តល់សិទ្ធិស្របច្បាប់ចំពោះភាគីសុចរិតវិញ ដូច្នេះចៅក្រមត្រូវពិនិត្យមើលទៅលើភស្តុតាងដាក់បន្ទុក និងដោះបន្ទុកមុននឹងធ្វើការសម្រេច។

### កថាភាគទី១: ភស្តុតាងដោះបន្ទុក និងភស្តុតាងដាក់បន្ទុក

យោងតាមគោលការណ៍នៃភស្តុតាងដោះបន្ទុក គឺជាភារកិច្ចរបស់បុគ្គលដែលជាចុងចម្លើយក្នុងការស្វែងរកនៅភាពស្អាតស្អំរបស់ខ្លួនមកបង្ហាញនៅចំពោះមុខតុលាការ។ គំនិតនេះចង់បញ្ជាក់ថាក្នុងករណីរូបវន្តបុគ្គល ឬនីតិបុគ្គលជាចុងចម្លើយដែលគេបានប្តឹង ហើយពាក្យបណ្តឹងដែលបញ្ជូនមកដល់ខ្លួនតាមរយៈតុលាការ ដូច្នេះចុងចម្លើយត្រូវត្រៀមឯកសារផ្សេងៗដែលអាចបញ្ជាក់ពីសិទ្ធិរបស់ខ្លួនទៅលើអ្វីដែលដើមបណ្តឹងទាមទារ។

នៅក្នុងឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការលើកដំបូង ត្រូវមានសរសេរអំពីការឆ្លើយតបចំពោះខ្លឹមសារនៃសាលដីកាដែលដើមចោទបានសរសេរទាមទារ។

ហើយនៅក្នុងពាក្យបណ្តឹង និងការទទួលស្គាល់ ឬមិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹងដោយចុងចម្លើយ ដូច្នេះចុងចម្លើយនឹងតវ៉ាចំពោះអង្គហេតុ

ដែលបានសរសេរនៅក្នុងពាក្យបណ្តឹងដែលបានប្តឹងខ្លួន[14]។ ការឆ្លើយតបនេះ គឺជាឯកសារចម្លើយរបស់ចុងចម្លើយ និងលិខិតដែលពាក់ព័ន្ធហើយអាចបង្ហាញពីភាពស្អាតស្អំរបស់ខ្លួន ហើយក៏អាចយកមកធ្វើជាភស្តុតាងនៅចំពោះមុខតុលាការដែរ។

យោងតាមស្មារតីច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា បុគ្គលគ្រប់រូបមានសិទ្ធិស្មើគ្នានៅចំពោះមុខច្បាប់[15]។ ហើយច្បាប់ គឺជាអាវុធក៏ដូចជាខែលការពារលើការរំលោភណាមួយពីសំណាក់បុគ្គលដ៏ទៃ ឬក៏ការចោទដោយបំពានពីរដ្ឋអំណាចដែរ[16]។ ជនគ្រប់រូបដែលស្ថិតក្នុងសមាសភាពជាចុងចម្លើយក្នុងបណ្តឹងរដ្ឋប្បវេណី គឺត្រូវធ្វើយ៉ាងណាស្វែងរកនូវភស្តុតាងក្នុងការដោះបន្ទុក។ ភស្តុតាងដោះបន្ទុក គឺជាភស្តុតាងទាំងឡាយណាដែលអាចច្រានចោលការចោទរបស់ដើមបណ្តឹងតាមការបង្ហាញនៅភស្តុតាងផ្ទុយរបស់ចុងចម្លើយ គេអាចនិយាយបានថា វាគឺជាភស្តុតាងដែលកំណត់នូវខណៈនានាប្រកបដោយស្ថានសម្រាលក្នុងការការពារការចោទប្រកាន់របស់ដើមចោទមកលើចុងចម្លើយ។

ការបែងចែកភស្តុតាងក្នុងការដាក់បន្ទុក ហើយនឹងដោះបន្ទុកវាមានលក្ខណៈខុសគ្នាត្រង់ថាគ្រប់ភស្តុតាងទាំងអស់មានលក្ខណៈខុសគ្នា គេចង់បញ្ជាក់ថាភស្តុតាងនោះមានចរិ-កលក្ខណៈខុសគ្នា[17] ក៏ប៉ុន្តែវាមានព្រំដែនកំណត់ច្បាស់លាស់ព្រោះភស្តុតាងជាច្រើននាំមកនូវលក្ខណៈពីរៈ គឺលក្ខណៈដាក់បន្ទុក និងលក្ខណៈដោះបន្ទុកក្នុងពេលតែមួយ។

ឧទាហរណ៍ៈ តាមការបំភ្លឺរបស់ដើមចោទ អាចបង្ហាញឱ្យឃើញពីចរិតលក្ខណៈដាក់បន្ទុក និងការបំភ្លឺរបស់ចុងចម្លើយបង្ហាញឱ្យឃើញពីចរិតលក្ខណៈដោះបន្ទុកទៅវិញ។ ប៉ុន្តែសុំចងចាំថា ភស្តុតាងតាមការបំភ្លឺរបស់ភាគីនោះមិនអាចជាមូលដ្ឋានគ្រប់គ្រាន់ក្នុងការដាក់បន្ទុក រឺក៏ជាមូលដ្ឋានសម្រាប់ការដោះបន្ទុកនោះទេ ដូចនេះហើយបានជាគេធ្វើការបែងចែកភស្តុតាងដាក់បន្ទុក និងដោះបន្ទុកនោះឱ្យមានភាពច្បាស់លាស់របស់វា។ ក្នុងករណីចាំបាច់ចៅក្រមនឹងធ្វើការស៊ើបសួរបន្ថែមនៅក្រៅតុលាការ ក្នុងករណីសាក្សីគ្មានករណីកិច្ចចូលខ្លួនទៅតុលាការ ឬក៏មានមូលហេតុត្រឹមត្រូវដែលមិនអាចចូលខ្លួនទៅតុលាការបាន[18]។

[14]មាត្រា១០១ នៃក្រមនីតិវិធីរដ្ឋប្បវេណីខ្មែរឆ្នាំ២០០៦ កថាខណ្ឌទី៣ ទំព័រ៩១

[15] មាត្រា៣៨កថាខណ្ឌទី៩ ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

[16] ខ្លឹមសាររបស់លោកសាស្ត្រាចារ្យ ឆឹង ស៊ីនៀង នៅក្នុងនីតិសិទ្ធិមនុស្ស

[17] ជាលក្ខណៈសម្បត្តិនៃភស្តុតាង រឺតម្លៃនៃភស្តុតាងដកស្រង់ចេញពីនីតិភស្តុតាង របស់លោកសាស្ត្រាចារ្យអ៊ិន បូផា

[18] មាត្រា១៣៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីខ្មែរឆ្នាំ២០០៦ ទំព័រ៥៣

ជាគោលការណ៍ ការពិនិត្យភស្តុតាងត្រូវធ្វើជាសាធារណៈនៅក្នុងតុលាការ ប៉ុន្តែក្នុងមាត្រា១៣៦នៃក្រមនីតិវិធីរដ្ឋប្បវេណីខ្មែរកថាខណ្ឌទី១បញ្ជាក់ថា តុលាការធ្វើការសាកសួរសាក្សីនៅក្រៅតុលាការបានក្នុងករណីដែលសាក្សីនោះមានជំងឺ ឬក៏ជរាមិនអាចចូលរួមក្នុងអង្គសវនាការបាន ពីព្រោះថាសេចក្ដីថ្លែងការណ៍របស់សាក្សី គឺជាមូលដ្ឋានគ្រឹះមួយនៃភស្តុតាងដែលអាចនាំឱ្យតុលាការធ្វើការសម្រេចសេចក្ដីដោយយុត្តិធម៌បាន បើយោងតាមគោលការណ៍តុលាការសម្រេចសេចក្ដីដោយផ្អែកទៅតាមភស្តុតាងដែលមាន។

ក្នុងករណីដែលចុងចម្លើយយល់ឃើញថា ភស្តុតាងដែលបង្ហាញដោយដើមចោទនៅចំពោះមុខតុលាការមិនទាន់មានភាពច្បាស់លាស់ទេ។ ក្នុងករណីនេះចុងចម្លើយអាចស្នើសុំដីកាបង្គាប់របស់តុលាការតាមពាក្យសុំដើម្បីផ្ដល់ទៅឱ្យម្ចាស់ឯកសារនោះ[19] ដើម្បីយកមកធ្វើការបង្ហាញជាភស្តុតាងបន្ថែមដើម្បីទទួលបានភាពយុត្តិធម៌ដល់ខ្លួន។ ក្នុងករណីតុលាការយល់ឃើញថាត្រឹមត្រូវ ដូច្នេះតុលាការត្រូវបង្គាប់ឱ្យផ្ដល់ឯកសារចូលមកតុលាការដើម្បីធ្វើការពិនិត្យ ហើយចៅក្រមយល់ឃើញថាការស្នើសុំរបស់ភាគី គឺជាភស្តុតាងចាំបាច់នៅក្នុងការដោះបន្ទុក ឬដាក់បន្ទុក។

### កថាភាគទី២: ភស្តុតាងជាសម្ភារៈ និងភស្តុតាងក្រៅសម្ភារៈ

ភស្តុតាងជាសម្ភារៈ គឺជាសម្ភារៈទាំងឡាយណាដែលអាចបំរើជាវត្ថុតាងបាន ហើយនឹងមានចំណងចងភ្ជាប់ទៅតាមរឿងក្ដីនីមួយៗ និងអាចនាំមកឱ្យឃើញនូវធាតុពិតបានកើតឡើងសមស្របទៅតាមការកំណត់របស់ច្បាប់។ ភស្តុតាងជាសម្ភារៈ គឺជាប្រភពនៃការផ្ដល់ព័ត៌មានអំពីអង្គហេតុនោះ ភស្តុតាងជាសម្ភារៈអាចកំណត់បានអំពីនត្ថិភាព និងអត្ថភាពនៃសិទ្ធិរបស់បុគ្គលម្នាក់ៗ ហើយភស្តុតាងជាសម្ភារៈវាក៏អាចជាការដោះសារ ឬបញ្ជាក់ពីការដាក់បន្ទុក និងដោះបន្ទុកនៅលើអង្គហេតុមួយបាន។

ភស្តុតាងទាំងនេះ តម្រូវឱ្យភាគីវិវាទធ្វើការស្វែងរកដើម្បីយកមកបញ្ជាក់នៅចំពោះមុខចៅក្រម ទន្ទឹមនឹងនេះដែរគូភាគីអាចធ្វើការស្នើសុំតុលាការត្រួតពិនិត្យលើសមាសធាតុនៃភស្តុតាងបាន។ ពីព្រោះថាភាគីណាក៏អាចសុំឱ្យតុលាការបញ្ជាក់ឱ្យបានច្បាស់លាស់អំពីភស្តុតាងរបស់ភាគីម្ខាងទៀតដែលមានទំនាក់ទំនងទៅនឹងអង្គហេតុ[20]។

---

[19] មាត្រា១៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណីខ្មែរ២០០៦ កថាខណ្ឌទី១ ទំព័រ៦២

[20] មាត្រា១២៥នៃក្រមនីតិវិធីរដ្ឋប្បវេណីខ្មែរ២០០៦

សម្ភារៈដែលចាត់ចូរជាភស្តុតាងមានដូចជាវត្ថុដែលមានការពាក់ព័ន្ធជាមួយ និងអង្គហេតុដែលអាចយកមកបញ្ជាក់ពីការពិតនៃអង្គហេតុនោះបាន ភស្តុតាងទាំងនោះរួមមានៈ កិច្ចសន្យា លិខិតយថាភូត... ។

ឧទាហរណ៍៖ លោកវណ្ណាបានបង្កើតកិច្ចសន្យាទិញលក់ ជាមួយលោកពិសិទ្ធអំពីការទិញលក់ផ្ទះមួយកន្លែងនៅខេត្តបាត់ដំបង ដោយលោកវណ្ណាជាភាគីអ្នកទិញ រីឯលោកពិសិទ្ធជាភាគីអ្នកលក់ ក្រោយពីភាគីទាំងពីរបានត្រូវគ្នាលើសំណើ និងស្ទីការលោកវណ្ណាក៏បានក្លាយម្ចាស់អចលនវត្ថុនៅខេត្តបាត់ដំបងដោយស្របច្បាប់។ ប៉ុន្តែដោយលោកវណ្ណាទទួលបានការអនុញ្ញាតពីសហរដ្ឋអាមេរិកឱ្យទៅរស់នៅទីនោះ។ បន្ទាប់មកលោកវណ្ណាក៏បានផ្ញើផ្ទះនោះនឹងបងជីដូនមួយ ដើម្បីជួយថែរក្សាជំនួសអស់រយៈពេលដប់ឆ្នាំបងជីដូនមួយរបស់គាត់បានធ្វើលទ្ធកម្មទៅលើផ្ទះនោះ ហើយក៏ទទួលបានប័ណ្ណកម្មសិទ្ធិនៅលើអចលនទ្រព្យនោះ។ បន្ទាប់ពីដប់ឆ្នាំដែលបានទៅរស់នៅសហរដ្ឋ លោកវណ្ណាក៏វិលមកលេងស្រុកខ្មែរវិញហើយបានឈានទៅបាត់ដំបងដើម្បីលក់ផ្ទះនោះ ដើម្បីយកប្រាក់សម្រាប់បង់ថ្លៃសាលាកូនដែលកំពុងសិក្សារនៅសហរដ្ឋអាមេរិក។ នៅគ្រានោះវិវាទក៏បានកើតឡើងរវាងលោកវណ្ណា និងបងជីដូនមួយរបស់ខ្លួន តើភាគីវិវាទត្រូវបង្ហាញភស្តុតាងអ្វីខ្លះក្នុងការអះអាងសិទ្ធិរបស់ខ្លួននៅចំពោះមុខតុលាការ? វាគឺជាការពិតណាស់នៅក្នុងរឿងក្តីរដ្ឋប្បវេណីគូភាគីត្រូវស្វែងរកភស្តុតាង ដើម្បីមកបង្ហាញតុលាការក្នុងការបញ្ជាក់ពីសិទ្ធិស្របច្បាប់របស់ខ្លួន។

នៅក្នុងករណីខាងលើនេះ ភស្តុតាងជាសម្ភារៈចង់បញ្ជាក់ថាវាជាភស្តុតាងដែលមានដូចជា ឯកសារ ឬលិខិតយថាភូត ក៏ដូចជាកិច្ចសន្យាទិញលក់ និងលិខតផ្សេងដែលមានការពាក់ព័ន្ធធ្វើជាភស្តុតាងក្នុងតុលាការ។ ក្នុងករណីនេះចៅក្រមត្រូវពិនិត្យឱ្យបានលម្អិតថាលិខិតយថាភូត ឬក៏ឯកសារណាដែលជាភស្តុតាងពិត ឬក៏ជាភស្តុតាងក្លែងបន្លំ។

ការសន្និដ្ឋានរបស់តុលាការក៏ជាភស្តុតាងជាសម្ភារៈផងដែរ អំពីអង្គហេតុនានា(*ហេតុការណ៍*)ដោយអនុលោមតាមទៅតាមភស្តុតាងដែលបានលេចឡើង។ នៅក្នុងន័យនេះដែរចង់បញ្ជាក់ថា រាល់ភស្តុតាងដែលតុលាការកំពុងសិក្សាគឺសុទ្ធតែកើតចេញពីអង្គហេតុទាំងអស់ក្នុងអតីតកាល ភស្តុតាងទាំងនោះជាគុណវុឌ្ឍន៍គតិយុត្តិទៅលើអង្គហេតុមួយនីមួយៗ គឺមានន័យថា គឺជាការវាយតម្លៃទៅលើអង្គហេតុនានាដោយអង្គហេតុនោះត្រូវបានកំណត់ពីអំពើដែលបានប្រព្រឹត្ត(*ចំនុចវិវាទសំខាន់*) ហើយនឹងអំពើទាំងនោះមានចែងក្នុងច្បាប់សារធាតុ(*ក្រមរដ្ឋប្បវេណី២០០៧*)នៃព្រះរាជាណាចក្រកម្ពុជា។ ហេតុដូច្នេះហើយនៅក្នុងនីតិវិធី

រដ្ឋប្បវេណីភាគីត្រូវផ្តល់ឯកសារពាក់ព័ន្ធដែលសាមីភាគីមាន ឬក៏ដាក់ពាក្យសុំទៅតុលាការដើម្បីបង្គាប់ឱ្យម្ចាស់ឯកសារផ្តល់ឯកសារឱ្យតុលាការធ្វើការវិនិច្ឆ័យ និងផ្ទៀងផ្ទាត់ជាមួយភស្តុតាងផ្សេងៗទៀតដែលមាន ក្នុងបំណងទទួលបានសេចក្តីសន្និដ្ឋានរបស់តុលាការទៅនឹងអត្ថិភាពនៃភស្តុតាងដែលមាន ហើយនឹងការវាយតម្លៃនៃភស្តុតាងដែលពាក់ព័ន្ធទៅនឹងអង្គហេតុនោះ។ ក្នុងករណីនេះចៅក្រមអាចធ្វើការពិនិត្យភស្តុតាងតាមសម្ភារវិធី ហើយការប្រមូលភស្តុតាងទាំងនេះវាមានទំនាក់ទំនងគ្នាទៅវិញទៅមកដែលមិនកាត់ផ្តាច់បាន គឺមានន័យថាវាត្រូវបំពេញឱ្យគ្នាទៅវិញទៅមកជាចាំបាច់។

នៅត្រង់ចំណុចខាងលើនេះចង់បញ្ជាក់ថា ក្នុងករណីភស្តុតាងមួយអាចមានតម្លៃលុះត្រាតែភស្តុតាងមួយនោះ គឺជាភស្តុតាងដែលត្រូវបានឆ្លុះបញ្ចាំងអំពីអត្ថិភាព និងនត្ថិភាពនៃសិទ្ធិរបស់ភាគីណាមួយ។ ប្រសិនបើភស្តុតាងដែលបានបង្ហាញឆ្លុះបញ្ចាំងច្បាស់លាស់ គឺវានាំឱ្យមានភាពងាយស្រួលក្នុងការសម្រេចចិត្តរបស់តុលាការដ៏ត្រឹមត្រូវមួយ ។

ភស្តុតាងក្រៅសម្ភារៈ គឺជាភស្តុតាងទាំងឡាយណាមិនមែនជាវត្ថុ ឬមិនមែនជាទ្រព្យដែលអាចលក់បាន ហើយភស្តុតាងក្រៅសម្ភារៈអាចបង្ហាញឱ្យច្បាស់ អំពីអត្តសញ្ញាណពិតប្រាកដរបស់បុគ្គលណាម្នាក់នៅក្នុងរឿងក្តីនីមួយៗ។

ភស្តុតាងក្រៅសម្ភារៈមានដូចជា៖ ខ្មៅដៃ សម្លាក រឺក៏ស្នាមខ្មៅ ឈាម ហើយអ្វីៗទាំងអស់នេះ គឺអាចយកមកធ្វើជាភស្តុតាងក្នុងការបញ្ជាក់នៅចំពោះមុខចៅក្រម ដើម្បីធ្វើការទាមទារសិទ្ធិរបស់ខ្លួន និងកាតព្វកិច្ចដែលត្រូវបំពេញឱ្យខ្លួនបាន។

ឧទាហរណ៍៖ ក្នុងករណីអាពាហ៍ពិពាហ៍មួយត្រូវបានបំបែកលំនៅសង្វាសមុនពេលដែលគូភាគីធ្វើការលែងលះគ្នា ហើយក្រោយមកភាគីម្ខាងមានទម្ងន់ហើយបានប្រសូតបានបុត្រមួយ ក្នុងករណីដែលកំពុងតែមានវិវាទភាគីម្ខាងទៀតអាចបដិសេធ ឬក៏ទាមទារយកកូនមកធ្វើការថែរក្សាបានតាមការបង្ហាញភស្តុតាងក្រៅសម្ភារៈ។ ហើយនៅក្នុងករណីនេះដែលប្រសិនបើភាគីម្ខាងទៀតចង់បាន ឬមិនចង់បានភាគីនោះត្រូវតែបង្ហាញភស្តុតាងដើម្បីធ្វើការបញ្ជាក់ថាខ្លួនគឺជាឪពុក រឺក៏មិនមែនជាឪពុករបស់ក្មេងនោះ ដើម្បីធ្វើការបញ្ជាក់ឱ្យមានភាពច្បាស់លាស់នោះ ភាគីម្ខាងត្រូវធ្វើកោលសវិច័យតាមរយៈឈាមរបស់ខ្លួន និងឈាមរបស់កូននោះដោយអ្នកជំនាញ។

**កថាភាគទី៣: ភស្តុតាងតាមបំភ្លឺរបស់សាក្សី**

សាក្សី គឺជាតតីយជនដែលតុលាការបង្គាប់ឱ្យធ្វើការបំភ្លឺនៅអ្វីដែលបានដឹង ហើយអ្វីដែលបានដឹង គឺជាអង្គហេតុដែលបានកើតនឹងយកមកបង្ហាញនៅមុខចៅក្រម។ ការបំភ្លឺអង្គហេតុនោះជាព័ត៌មានសំខាន់ ហើយព័ត៌មាននោះគឺមានតាមការធ្វើសេចក្ដីរាយការណ៍របស់សាក្សីនូវចំណុចធំៗមួយចំនួនដើម្បីយកមកធ្វើជាភស្តុតាង។ ប៉ុន្តែការសួរសាក្សីត្រូវធ្វើឡើងដោយគោរពតាមគោលការណ៍ច្បាប់ ដូច្នេះសាក្សីត្រូវបានសាកសួរអំពីអង្គហេតុដែលបានកើតឡើងរវាងគូរភាគីវិវាទតាមអ្វីដែលខ្លួនបានដឹង និងបានឃើញតែប៉ុណ្ណោះ ក៏ប៉ុន្តែការសាកសួរត្រូវបានកម្រិតលើសំណួរ។ ចំពោះសំណួរបើអាចធ្វើបានត្រូវធ្វើដាច់ដោយឡែកពីគ្នា វានឹងនាំឱ្យមានភាពច្បាស់លាស់មួយ។ ការកំណត់ដែលមិនអាចឱ្យធ្វើការសាកសួរបានគឺមានសំណួរមួយចំនួនដូចខាងក្រោមនេះ៖

_ សំណួរដែលប្រមាថមើលងាយ ឬធ្វើឱ្យច្របូកច្របល់ដល់សាក្សី។

_ សំណួរនាំមុខ។

_ សំណួរច្រំដែល។

_ សំណួរដែលគ្មានទំនាក់ទំនងនឹងចំណុចវិវាទ។

_ សំណួរដែលទាមទារឱ្យថ្លែងយោបល់របស់សាក្សីផ្ទាល់ខ្លួន។

_ សំណួរដែលទាមទារឱ្យថ្លែងនូវយោបល់អំពីអង្គហេតុដែលសាក្សីពុំបានជួប ប្រទះផ្ទាល់[21] មានន័យថារាល់សំណួរដែលនាំឱ្យសាក្សីមានការភាន់ច្រឡំ និងច្របូកច្របល់នៅក្នុងចិត្តក្នុងការស្រាយបំភ្លឺការពិត រឺក៏នាំឱ្យមានការវង្វេងក្នុងការបំភ្លឺទៅលើអង្គហេតុដែលជាប្រយោជន៍របស់ភាគីវិវាទម្ខាងទៀតនោះ ដូច្នេះហើយសំណួរនោះត្រូវបានហាមឃាត់មិនឱ្យសួរឡើយនៅក្នុងសវនាការ។

សំណួរនាំមុខ គឺជាសំណួរដែលមិនមានការពាក់ព័ន្ធជាមួយនឹងអង្គហេតុ ហើយការសួរនោះគឺធ្វើឡើងដោយឱ្យសាក្សីឆ្លើយមាន ឬមិនមានតែប៉ុណ្ណោះ ដូច្នេះសំណួរនេះវាជាសំណួរបិទដែលផ្ទុយពីអង្គហេតុពិត និងជាសំណួរដែលនាំឱ្យមានសម្ពាធខាងផ្លូវចិត្តរបស់សាក្សី និងនាំសាក្សីឆ្លើយនៅចម្លើយដែលមេធាវីចង់បាន(មេធាវី នៃភាគីម្ខាង)។

សំណួរច្រំដែល គឺជាសំណួរដែលសួរហើយមានសភាពដ៏ដែលៗ ដែលនាំឱ្យសាក្សីមានការភាន់ច្រឡំហើយធ្វើការឆ្លើយតាមអ្វីដែលខ្លួនចង់បាន និងនាំឱ្យបាត់ប្រយោជន៍របស់

[21] មាត្រា១៣៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

ភាគីម្ខាងនៃវិវាទ។ នៅក្នុងន័យនេះដែរចង់បញ្ជាក់ថា មេធាវីខាងភាគីម្ខាងនៃភាគីវិវាទមិនអាចសួរសំណួរច្រំដែលទៅសាក្សីនៃភាគីម្ខាងទៀតបានទេ ព្រោះមេធាវីមានជំនាញក្នុងការសួរដើម្បីឱ្យសាក្សីភ្លេចខ្លួនហើយឆ្លើយនូវអ្វីដែលមេធាវីចង់បាន។

សំណួរដែលមិនទាក់ទងទៅនឹងចំណុចវិវាទគឺចង់ចញ្ជាក់ឱ្យឃើញថា មេធាវីខាងនៃភាគីម្ខាងមិនត្រូវសួរនូវសំណួរណាដែលធ្វើឱ្យសាក្សីភាន់ច្រឡំ ហើយអ្វីដែលមេធាវីបានសួរនោះមិនមានការពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានកើតមានឡើង។ ដូច្នេះសំណួរនោះនាំឱ្យសាក្សីអាចឆ្លើយដោយមិនដឹងខ្លួនហើយមានការភាន់ច្រឡំទៅនឹងអង្គហេតុពិត និងនាំឱ្យខាតប្រយោជន៍របស់ភាគីម្ខាងដែលមានសិទ្ធិស្របច្បាប់។

សំណួរដែលមេធាវីបានសួរទៅកាន់សាក្សី ហើយនិងទាមទារឱ្យថ្លែងយោបល់ផ្ទាល់ខ្លួនរបស់សាក្សីនោះក៏ត្រូវបានហាមឃាត់ផងដែរ។ ព្រោះថាការដែលសួរជាសំណួរដែលនាំសាក្សីថ្លែងពីអារម្មណ៍របស់ខ្លួនដូច្នេះ វាគឺជាសំណួរដែលមានការប៉ះទង្គិចទៅដល់អារម្មណ៍របស់សាក្សី និងនាំសាក្សីអាចថ្លែងព័ត៌មានមិនពិតទៅកាន់តុលាការដោយមនោសញ្ចេតនារបស់ខ្លួន។

សំណួរដែលមេធាវីសួរហើយទាមទារឱ្យថ្លែងយោបល់អំពីអង្គហេតុ ក្នុងករណីសាក្សីពុំបានជួបប្រទះផ្ទាល់ត្រូវបានហាមឃាត់ផងដែរ។ ចង់បញ្ជាក់ថាគឺជាសំណួរដែលមិនមានទាក់ទងទៅនឹងរឿងវិវាទពិតប្រាកដ ហើយសាក្សីមិនបានប្រទះនៅហេតុការណ៍នោះឡើយ ហេតុនេះមិនអាចមានការទាមទារសាក្សីថ្លែងយោបល់ពីអង្គហេតុដែលមិនមែនជាអង្គហេតុពិតបានឡើយ។

នៅក្នុងរឿងក្តីរដ្ឋប្បវេណីសាក្សីត្រូវបានតុលាការធ្វើការបង្គាប់ឱ្យចូលខ្លួន ដើម្បីបំភ្លឺនៅចំពោះមុខចៅក្រម។ ក្នុងករណីដែលច្បាប់បានបញ្ញត្ត អំពីការសាកសួរសាក្សីនៅក្រៅប្រព័ន្ធតុលាការ ដូច្នេះតុលាការអាចធ្វើការសាកសួរទៅសាក្សីបាន ឬក៏តុលាការអាចបង្គាប់ឱ្យនាំខ្លួនសាក្សីណាម្នាក់ ដែលបានបដិសេធក្នុងការចូលខ្លួនមកបំភ្លឺនៅចំពោះមុខតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ[22]។ ប្រសិនណាសាក្សីមិនព្រមចូលហើយគ្មានមូលហេតុត្រឹមត្រូវនោះតុលាការអាចបញ្ជានគរបាលយុត្តិធមិឱ្យធ្វើការនាំខ្លួនសាក្សីនោះ។

[22] មាត្រា១៣២កថាខ័ណ្ឌ២នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

សាក្សីត្រូវនិយាយអ្វីដែលជាពិតប្រាកដដែលខ្លួនបានដឹង ហើយនឹងបានឃើញជាក់ស្តែង ម្យ៉ាងទៀតតុលាការអាចធ្វើការសាកសួរសាក្សីនៅក្រៅតុលាការបាន[23]។ ក្នុងករណីដែលសាក្សីមានមូលហេតុត្រឹមត្រូវផ្តល់ជូនទៅតុលាការ។ ហេតុដូច្នេះតុលាការអាចធ្វើការសាកសួរសាក្សីខាងក្រៅតុលាការបាន ហើយរាល់ការចំណាយគឺបន្ទុករបស់ភាគីដែលមានប្រយោជន៍ក្នុងរឿងវិវាទ។ ការស្នើសុំសាកសួរសាក្សីត្រូវធ្វើឡើងដោយភាគីវិវាទហើយត្រូវមានការកំណត់ច្បាស់លាស់ទៅលើសាក្សី និងត្រូវភ្ជាប់នូវឯកសារដែលពាក់ព័ន្ធនៅក្នុងវិវាទនោះ។ ការកោះហៅសាក្សីត្រូវធ្វើឡើងក្នុងរយៈពេល២សប្តាហ៍មុនថ្ងៃសាកសួរ ហើយដីការកោះត្រូវសរសេរឱ្យបានច្បាស់លាស់នៅអាសយដ្ឋាន នាម មុខរបរបស់សាក្សីរួមទាំងកាលបរិច្ឆេទឱ្យបានច្បាស់លាស់ និងទីកន្លែងដែលសាក្សីត្រូវចូលខ្លួន[24]។ ក្នុងករណីសាក្សីធ្វើការបំភ្លឺដោយមានការបំភ័ន្តដូច្នេះទណ្ឌកម្មនឹងត្រូវកើតមានឡើងចំពោះសាក្សី ប៉ុន្តែផ្ទុយមកវិញប្រសិនបើតុលាការយល់ឃើញថា សាក្សីមិនអាចនឹងផ្តល់ចំលើយបានគ្រប់គ្រាន់នៅចំពោះមុខតុលាការ ដោយសារតែអ្នកសង្កេតការណ៍ណាម្នាក់ តុលាការអាចធ្វើការបង្គាប់ឱ្យអ្នកសង្កេតការណ៍នោះចេញទៅក្រៅសវនាការ។ នៅពេលដែលសាក្សីធ្វើការឆ្លើយបំភ្លឺនៅក្នុងអង្គសវនាការ នៅមុនពេលចាប់ផ្តើមសាក្សីត្រូវធ្វើការស្បថទៅតាមជំនឿរបស់ខ្លួន[25] ហើយត្រូវឆ្លើយនូវអ្វីដែលជាការពិតមិនកុហកឬលម្អៀង រឺក៏បំភ្លើសអ្វីទាំងអស់។ ក្នុងនាមជាសាក្សីត្រូវបំពេញទៅតាមកាតព្វកិច្ចរបស់ខ្លួនដែលជាសាក្សីដូចមានចែងក្នុងច្បាប់[26]។

ការសាកសួរសាក្សី គឺជានីតិវិធីដើម្បីប្រមូលឬក៏ទទួលបាននៅធនធាននៃភស្តុតាងដើម្បីរកឱ្យបាននូវភាពច្បាស់សាល់មួយ ដើម្បីពិចារណាលើការសម្រេចសេចក្តីមួយដោយយុត្តធម៌។

### ផ្នែកទី២: ការពិនិត្យភស្តុតាង

គ្រប់ភស្តុតាងទាំងអស់ដែលអាចយកមកជាមូលដ្ឋានគ្រឹះ ក្នុងការត្រួតពិនិត្យបាននៅក្នុងតុលាការលុះត្រាតែភស្តុតាងនោះត្រូវបានត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់បំផុត។ ថាតើមាន«ភាពត្រឹមត្រូវ រឺមិនត្រឹមត្រូវ»គ្រប់ចំណុចនីមួយៗ។ ដើម្បីពិនិត្យភស្តុតាងនានាយើង

[23] មាត្រា១៣៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦
[24] មាត្រា១៣៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីខ្មែរ២០០៦
[25] មាត្រា១៣៧នៃក្រមនីតិវិធីរដ្ឋប្បវេណី២០០៦
[26] មាត្រា១៣២ ដល់មាត្រា១៣៩នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

ត្រូវពិនិត្យនូវចំណុចមួយចំនួនមានដូចជា៖ ការវិភាគទៅលើភស្តុតាងតាមរយៈការសាកសួរសាក្សីនៅក្រៅតុលាការ[27] ដើម្បីទទួលបានភាពលម្អិតទៅលើអង្គហេតុក្នុងគោលបំណងគឺឱ្យលេចចេញភាពច្បាស់លាស់មួយ។ នៅក្នុងខណៈដែលបណ្តាលឱ្យកើតមានឡើងលើអង្គហេតុ ព្រមទាំងញ៉ាំងឱ្យមានការវិនិច្ឆ័យអំពីភាពជឿទុកចិត្តនានា។ ការរកឃើញនូវភស្តុតាងថ្មីៗ នាំឱ្យមានការគាំទ្រដល់ភស្តុតាងមុនៗបានវាគឺជាចំណុចសំខាន់ក្នុងការវិនិច្ឆ័យ ដើម្បីធ្វើការកំណត់នូវភាពច្បាស់លាស់មួយ។

ភាពត្រឹមត្រូវនៃភស្តុតាង គឺត្រូវធ្វើការពិនិត្យទៅលើអត្ថិភាព ឬក៏នត្ថិភាពនៃភស្តុតាងទាំងអស់ដែលនៅក្នុងសំណុំរឿងទាំងមូល។ បើយោងតាមការសិក្សាបែបនេះយើងលើកជាឧទាហរណ៍ថា៖ ប្រសិនបើសាក្សីបានបង្ហាញ(*បំភ្លឺ*)ថា គាត់បានឃើញអង្គហេតុ ឬព្រឹត្តិហេតុណាមួយនោះសាក្សីនោះត្រូវបានសាកសួរយ៉ាងលម្អិតស្តីពីអង្គហេតុនោះ គោលដៅនៃការសាកសួរនេះ គឺដើម្បីឱ្យមានការលេចចេញច្បាស់លាស់នៅខ្លឹមសារទាំងឡាយ។ ចំពោះខ្លឹមសាដែលអាចលេចចេញបានទាំងនោះ គឺអាចញ៉ាំងឱ្យមានមូលដ្ឋាននៅក្នុងការវិនិច្ឆ័យរបស់ចៅក្រមបានទៅលើភាពត្រឹមត្រូវ ហើយនឹងភាពមិនត្រឹមត្រូវរបស់ភស្តុតាងនានាតាមរយៈការបំភ្លឺរបស់សាក្សី ឬក៏តាមការបង្ហាញរបស់សាក្សីអំពីភាពជឿទុកចិត្តទៅលើភស្តុតាងទាំងនោះ។

ម្យ៉ាងទៀតដើម្បីឱ្យមានជំនឿ ហើយនឹងទុកចិត្តទៅលើអង្គហេតុមួយបាន ចៅក្រមត្រូវសាកសួរសាក្សីទៅលើខណៈរួមទាំងព្រឹត្តិការណ៍នានាឱ្យបានច្បាស់លាស់ ថាតើសាក្សីបានឃើញគូភាគីចុះកិច្ចសន្យាជាមួយគ្នានៅពេលណា? នៅឯណា? ហើយកម្មវត្ថុនៃកិច្ចសន្យានោះសាក្សីបានយល់ដែរ ឬទេ? ។ ការរកឃើញភស្តុតាងថ្មីនានា គឺជាការបង្ហាញនូវការគាំទ្រភស្តុតាងមួយចំនួន ឬក៏បង្ហាញនូវភាពផ្ទុយគ្នាទៅភស្តុតាងមួយទៀត។ សកម្មភាពនេះបង្ហាញពីការផ្ទៀងផ្ទាត់ទៅលើភស្តុតាងដែលមានស្រាប់ ជាមួយនឹងភស្តុតាងដែលបានរកឃើញថ្មី។ គ្រប់ភស្តុតាងនៅក្នុងសំណុំរឿងត្រូវមានការផ្ទៀងផ្ទាត់ និងប្រៀបធៀបជាមួយនឹងភស្តុតាងនានាផ្សេងទៀតគោលបំណងគឺដើម្បីរកភាពត្រឹមត្រូវទៅឱ្យភស្តុតាង។ ហើយភស្តុតាងដែលបានដាក់បង្ហាញនៅក្នុងរឿងក្តីនីមួយៗ ដើម្បីរកឱ្យឃើញនៅនត្ថិភាពនៃសិទ្ធិ

[27] មាត្រា១៣៦នៃក្រមនីតិវិធីរដ្ឋប្បវេណី២០០៦

និងអត្ថិភាពនៃសិទ្ធិរបស់គូវិវាទក្នុងរឿងក្តីរដ្ឋប្បវេណី គឺជាចំណុចសំខាន់ដែលភាគីវិវាទចង់បាន។

ជាគោលការណ៍ច្បាប់ តុលាការអាចទទួលស្គាល់អង្គហេតុមួយ ឬក៏អង្គហេតុច្រើនគឺអាស្រ័យទៅលើភស្តុតាង។ ភស្តុតាងកើតចេញពីព្រឹត្តិហេតុ ឬក៏ពីអង្គហេតុដែលអង្គហេតុទាំងនោះបានបញ្ញត្តនៅក្នុងច្បាប់សារធាតុ និងនៅក្នុងទម្រង់នីតិវិធីរដ្ឋប្បវេណីដើម្បីបង្ហាញពីនត្ថិភាព និងអត្ថិភាពនៃសិទ្ធិដែលត្រូវបានច្បាប់ទទួលស្គាល់។ ភស្តុតាងវាចាំបាច់ចំពោះបុគ្គល ឬក៏នីតិបុគ្គលនៅក្នុងវិវាទត្រូវយកវាទៅបង្ហាញពីការដាក់បន្ទុក និងដោះបន្ទុកដើម្បីបញ្ជាក់ពីសិទ្ធិដែលខ្លួនមានទៅលើកម្មវត្ថុនៃបណ្តឹងទាមទារនោះ។ ចំពោះសេចក្តីសម្រេចរបស់តុលាការចាំបាច់ត្រូវមានការគិតគូរយ៉ាងល្អិតល្អន់ និងប្រកបដោយភាពរឹងមាំបំផុតទៅលើភស្តុតាងហើយវាជាមធ្យោបាយដ៏រឹងមាំក្នុងការអះអាងរបស់តុលាការលើគូភាគី។

ភស្តុតាងទាំងឡាយដែលអាចជឿទុកចិត្តបាន គឺវានាំឱ្យតុលាការធ្វើការសម្រេចសេចក្តីដោយមានភាពយុត្តិធម៌។ តែផ្ទុយមកវិញបើភស្តុតាងមិននាំឱ្យមានភាពជឿទុកចិត្តបានដូច្នេះតុលាការអាចធ្វើការសម្រេចសេចក្តីដោយគ្មានភាពយុត្តិធម៌ទៅដល់គូភាគី។ នៅក្នុងន័យនេះចង់បញ្ជាក់ថា តុលាការមិនអាចធ្វើអ្វីតាមទំនើងចិត្តរបស់ពួកគេបានទេ តុលាការត្រូវវិនិច្ឆ័យអ្វីទៅតាមភស្តុតាងដែលមាន និងធ្វើការបែងចែកភស្តុតាងឱ្យបានច្បាស់លាស់។

ក្នុងករណីដែលតុលាការធ្វើការសម្រេចសេចក្តី ដោយបំពានទៅលើកាតព្វកិច្ចខ្លួនវាគឺជាចរិតនៃការចាប់បង្ខំឱ្យមានការបាត់បង់សិទ្ធិ មិនតែប៉ុណ្ណោះបានឆ្លុះបញ្ចាំងពីគំនិតរបស់បុគ្គលនុ៎ះ! ជាបុគ្គលដែលមានភាពអាត្មានិយម ដោយខ្វះនូវឧត្តមគតិក្នុងការពិចារណារកហេតុផល ហើយនឹងជាបុគ្គលធ្វើការខុសទៅឧបនិស្ស័យខ្លួនដែរនេះបើយោងតាមទស្សនៈរបស់លោកប្លាតុង[28] ។

ឧទាហរណ៍៖ មានករណីទិញលក់អចនទ្រព្យរវាងលោកA និងលោកBដោយមានសាក្សីបានដឹងពីការទិញលក់នេះហើយសាក្សីនោះគឺលោកC ដោយហេតុគាត់ជាអ្នកជិតខាងនៃម្ចាស់ដីនោះ។ ក្រោយមកលោកA និងលោកBក៏មានវិវាទនិងគ្នាដោយសារវត្ថុតាងមិនទានមានភាពច្បាស់លាស់ លោកAបានទៅពឹងលោកCមកជួយស្រាយបំភ្លឺនូវរឿងនេះឱ្យបានច្បាស់លាស់ថាដីនេះជាកម្មសិទ្ធិរបស់លោកមែន។ ដូចនេះសាក្សីត្រូវផ្តល់ព័ត៌មានអ្វី

[28] សៀវភៅ ប្រវត្តិគំនិតនយោបាយ របស់លោកបណ្ឌិត អ៊ុន សកក្កដា ឆ្នាំ២០១៥ទំព័រ ៦៥

ដែលគាត់បានដឹងឱ្យបានល្អិតល្អន់ដែលមានការពាក់ព័ន្ធនឹងដីវិវាទនោះ ក្នុងការធ្វើសេចក្តីវិនិច្ឆ័យអំពីភាពច្បាស់លាស់ទៅលើវត្ថុតាងដែលបានផ្តល់ពីមុនមកនោះដោយចៅក្រម។

ការរកឃើញភស្តុតាងថ្មីនេះ គឺជាតម្រុយមួយហើយនឹងកាន់តែច្បាស់ដែលអាចជួយគាំទ្រដល់ភស្តុតាងចាស់ ឬក៏មានភាពផ្ទុយទៅនឹងភស្តុតាងចាស់ក៏មាន។ ភស្តុតាងថ្មីអាចរកឃើញដោយសមត្ថកិច្ចជំនាញ គូរវិវាទ ឬក៏អាចជាសាក្សីថ្មីដែលទើបបង្ហាញខ្លួនដោយហេតុផ្សេងៗវាសុទ្ធសឹងតែអាចជួយដល់ភស្តុតាងចាស់ និងមានភាពរឹងមាំ។

ឧទាហរណ៍៖ ក្នុងសំណុំរឿងដីធ្លីដែលមានការប្តឹងផ្តល់ និងមានការដោះស្រាយជាយូរណាស់ហើយ ដែលរឿងនេះមិនទាន់ចប់នៅឡើយ ជាចៃដន្យអនិច្ចជនខ្មែរអាមេរិកកាំងដែលបានចេញពីស្រុកខ្មែរទៅរស់សហរដ្ឋអាមេរិកអស់រយៈពេលដប់ឆ្នាំមកហើយ គាប់ជួនពេលនោះគាត់បានត្រឡប់មកលេងកំសាន្តមាតុប្រទេសវិញ។ ហើយគាត់គឺជាអតីតម្ចាស់ដីដែលកំពុងមានវិវាទនោះ។ ដោយដឹងពីដំណឹងនេះសមត្ថកិច្ចជំនាញបានធ្វើការស្រាវជ្រាវដឹងថាគាត់ គឺជាអតីតម្ចាស់ដីកំពុងមានវិវាទក៏ស្នើរសុំឱ្យគាត់ជួយធ្វើជាសាក្សីបំភ្លឺព័ត៌បន្ថែមអ្វីដែលគាត់បានដឹង និងស្នើសុំគាត់ផ្តល់ជាឯកសារទិញលក់ដែលមានការពាកព័ន្ធកន្លងមកដើម្បីគាំទ្រដល់ភស្តុតាងចាស់។

## កថាភាគទី១: ការពិនិត្យភស្តុតាងដំបូង និងភស្តុតាងបន្ទាប់បន្សំ

ភស្តុតាងដំបូង វាគឺជាភស្តុតាងទាំងឡាយណាដែលមានប្រភពចេញមកពីអង្គហេតុណាមួយ។ ភស្តុតាងនេះមានដូចជាឯកសារដើមនានា រឺការបំភ្លឺរបស់សាក្សីដែលមានការពាក់ព័ន្ធក្នុងរឿងក្តីរដ្ឋប្បវេណីជាដើម ដែលត្រូវយកមកបង្ហាញចំពោះមុខតុលាការ ហើយតុលាការធ្វើការរៀបចំតាមនីតិវិធីច្បាប់។ តុលាការត្រូវកំណត់កាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ និងធ្វើការកោះហៅគូរភាគីមកចូលរួម[29]។ មានន័យថាអ្វីៗដែលបានមកពីការបង្ហាញរបស់គូរភាគីវិវាទ ក្នុងដំណាក់កាលត្រៀមទាញហេតុផលដោយផ្ទាល់មាត់នោះ គឺអាចយកមកធ្វើបន្ទាល់បាននៅចំពោះមុខតុលាការ នៅក្នុងករណីនេះដែរដើម្បីដោះស្រាយឱ្យត្រឹមត្រូវ និងរហ័សទៅលើចំណាត់ការនៅក្នុងរឿងក្តីរដ្ឋប្បវេណី ចៅក្រមត្រូវធ្វើឱ្យការពិនិត្យភស្តុតាងដែលអាចប្រព្រឹត្តទៅជាបន្ទាន់បាន។ ក្នុងដំណាក់កាលទាញហេតុផលផ្ទាល់មាត់ដំបូងនឹងរៀបចំនៅចំណុចវិវាទ និងចំណុចគ្មានវិវាទ និងភស្តុតាងដើម្បីធ្វើជា

[29] មាត្រា១១៣នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

អំណះអំណាងក្នុងការសម្រេចសេចក្ដី ហើយការដែលសាកសួរទៅលើសាក្សី ឬសាមីភាគី បើអាចធ្វើបានត្រូវតែធ្វើដោយសម្ងាហវិធី។

ឯកសារដែលបម្រុង ដែលប្រើនៅក្នុងការសាកសួរសាក្សីជាអាទិ៍ ត្រូវដាក់ជូននៅក្នុងអំឡុងពេលដែលសមរម្យមុនពេលចាប់ផ្ដើមធ្វើការសាកសួរសាក្សី ក៏ប៉ុន្តែឯកសារដែលនឹងប្រើជាភស្តុតាងដើម្បីយកធ្វើការប្រដែង លើជំនឿនៅក្នុងសេចក្ដីថ្លែងការណ៍របស់សាក្សីជាអាទិ៍[30]ត្រូវធ្វើការពិនិត្យភស្តុតាងភ្លាមៗ នៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់ បន្ទាប់ពីការបញ្ចប់នីតិវិធីត្រៀមទាញហេតុផលដោយផ្ទាល់មាត់ ហើយបានកំណត់ពីចំណុចវិវាទ រឺក៏ការរៀបចំនៅចំណុចវិវាទនៅពេលធ្វើការទាញហេតុដោយផ្ទាល់មាត់ និងក្រោយពេលនីតិវិធីត្រៀមដើម្បីទាញហេតុផលនោះ។ ចំណុចទាំងនេះ គឺជាគន្លឹះដើម្បីឱ្យបណ្ដឹងមានភាពឆាប់រហ័សនឹងត្រឹមត្រូវ។ ក្នុងករណីពិសេសនោះការសាកសួរទៅលើសាក្សីដែលជាសកម្មភាពសំខាន់បំផុតក្នុងការពិនិត្យភស្តុតាង និងត្រូវធ្វើជាសម្ងាហវិធី។ ដូច្នេះហើយភស្តុតាងជាឯកសារ ត្រូវបានចៅក្រមសាកសួរលម្អិតលើសាក្សីក្នុងគោលបំណងរកឱ្យឃើញពីភាពច្បាស់លាស់ថាភស្តុតាងនេះត្រឹមត្រូវ រឺក៏មិនត្រឹមត្រូវ។ ក៏ប៉ុន្តែប្រសិនបើភស្តុតាងដែលមានភាពច្បាស់លាស់ស្រាប់ គឺគេអាចយកធ្វើការបដិសេធនូវចម្លើយសាក្សីរបស់ភាគីណាមួយ និងអាចបញ្ជាក់បានថាសាក្សីនោះមិនគួរឱ្យទុកចិត្ត។ ច្បាប់ទទួលស្គាល់ការដាក់ភស្តុតាងនេះនៅក្នុងពេលដែលសួរសាក្សី ឬក៏ក្រោយពេលសាកសួរក៏បាន។

រីឯភស្តុតាងបន្ទាប់បន្សំ គឺជាភស្តុតាងដែលពុំមែនជាប្រភពដំបូងបំផុតនោះទេ ក្នុងការផ្ដល់ព័ត៌មានផ្សេងៗ ឬក្នុងការបម្រើឱ្យការសម្រេចសេចក្ដីចំពោះអង្គហេតុនោះបានទេ។ ភស្តុតាងដែលចេញពីបន្ទុកព័ត៌មាន ឬដែលចេញពីប្រភពផ្សេងៗដូចជាៈ ឯកសារចម្លង ការបំភ្លឺរបស់សាក្សីពីខាងក្រៅដែលមិនទាន់ច្បាស់ពីហេតុដែលបានកើតជាដើម។

ក្នុងករណីដែលតុលាការយល់ថា គឺជាការចាំបាច់ក្នុងការសាកសួរសាក្សី ដោយមិនចាំបាច់ឱ្យចូលមកបំភ្លឺនៅក្នុងតុលាការ ឬក៏ពុំអាចមកនៅពោះមុខតុលាការដោយមានហេតុផលសមរម្យណាមួយ[31]។ តុលាការយកភស្តុតាងបន្ទាប់បន្សំទាំងឡាយដែលបានមកពីការសាកសួរពីសាក្សី ឬក៏ឯកសារផ្សេងៗដែលអាចផ្ដល់នូវព័ត៌មានទាក់ទងទៅនឹងវិវាទ ហើយអាចជាមធ្យោបាយសម្រាប់ធ្វើការផ្ទៀងផ្ទាត់ជាមួយភស្តុតាងដំបូងបំផុតបាន ថាតើការផ្ដល់

[30] មាត្រា១២៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[31] មាត្រា១៣៦នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

ភស្តុតាងទាំងអស់ដែលទទួលបាននោះវាមានភាពត្រឹមត្រូវកម្រិតណា ហើយភស្តុតាងនេះអាចជួយរកភាពត្រឹមត្រូវបានកម្រិតណា។ រីឯភស្តុតាងពីខាងក្រៅដែលអាចជួយបំពេញបន្ថែមបានច្បាស់លាស់ក្នុងដំណាក់កាលផ្តល់សក្ខីកម្ម ហើយនឹងភស្តុតាងផ្សេងៗដែលមានភាពច្បាស់លាស់ជាង ចៅក្រមនឹងអាចធ្វើការសម្រេចសេចក្តីមួយ ដោយជួយដល់ភាគីដែលមានប្រយោជន៍ទទួលបានសិទ្ធិពីការរំលោភបំពានរបស់ភាគីម្ខាងទៀតមកវិញ។ នៅក្នុងន័យនេះតុលាការត្រូវធ្វើការវិភាគទៅលើ គ្រប់ភស្តុតាងទាំងអស់តាមមធ្យោបាយ និងជំនាញរបស់ខ្លួនក្នុងការកំណត់ពីលក្ខណៈនៃភស្តុតាងមួយណាមានភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវ។ ហើយជាពិសេស ភស្តុតាងដែលជាឯកសារត្រូវកំណត់ថាឯកសារនោះជាឯកសារផ្លូវការដែលចេញដោយស្ថាប័នមានសមត្ថកិច្ច និងត្រូវបានទទួលស្គាល់ដោយច្បាប់ និងជាភស្តុតាងដែលអាចបដិសេធរាល់ចម្លើយរបស់សាក្សី។

### កថាភាគទី២: ការពិនិត្យប្រយោល និងភស្តុតាងផ្ទាល់

ភស្តុតាងប្រយោល គឺជាផ្នែកមួយដែលទាញចេញពីភស្តុតាងគ្រឹះ និងបានមកពីនីតិវិធីត្រៀមទាញហេតុផល[32]។ ចៅក្រមត្រូវរៀបចំរាល់សេចក្តីអះអាងរបស់ភាគីដែលបានបំភ្លឺគ្រប់ចំណុចវិវាទដែលគូភាគីមិនយល់ស្របនឹងគ្នា ហើយនឹងរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនោះ ដើម្បីធ្វើការពិចារណានៅក្នុងនីតិវិធីទាញហេតុផលដោយផលដោយផ្ទាល់មាត់ឱ្យបានល្អិតល្អន់។ មានន័យថាក្នុងនីតិវិធីនេះតុលាការត្រូវស្វែងរកភស្តុតាង និងចំណុចវិវាទរបស់គូភាគីហើយអ្វីៗដែលតុលាការបានកំណត់រួច វាគឺជាមូលដ្ឋានគ្រឹះសម្រាប់ធ្វើការវិនិច្ឆ័យនៅក្នុងដំណាក់កាលជំនុំជម្រះ ហេតុដូច្នេះហើយចៅក្រមត្រូវមានចំណេះដឹងពិតប្រាកដក្នុងការកំណត់ពីចំណុចវិវាទរបស់គូរភាគី និងធ្វើពិចារណាឱ្យបានច្បាស់លាស់ពីចំណុចនីមួយៗ និងផ្នែកសំខាន់ៗដែលអាចចង្អុលបង្ហាញពីលក្ខណៈនត្ថិភាព ឬអត្ថិភាពនៃសិទ្ធិរបស់គូរភាគីនីមួយៗបាន។ ដើម្បីកំណត់ពីចរិកលក្ខណៈនៃវិវាទបាន ចៅក្រមត្រូវប្រើប្រាស់នៅកម្រិតនៃការយល់ដឹងខ្ពស់ទៅលើវិស័យវិជ្ជាជីវៈច្បាប់ ឯភស្តុតាងប្រយោលនេះវាជាចំណុចចាប់ផ្តើមមួយ ដែលអាចឆ្លុះបញ្ចាំងពីភាពច្បាស់លាស់នៃនត្ថិភាព រីក៏អត្ថិភាពនៃសិទ្ធិរបស់គូរភាគី ចំពោះគោលបំណងចំបងរបស់ភស្តុតាងប្រយោលនេះអាចធ្វើឱ្យប្រសើរឡើងនូវការកំណត់ច្បាស់លាស់មួយ និងត្រូវបានលាតត្រដាងកាន់តែច្បាស់អំពីសិទ្ធិ ដូច្នេះ

[32] មាត្រា១០៣ ក្រមនីតិវិធីរដ្ឋប្បវេណីខ្មែរឆ្នាំ២០០៦

ចៅក្រមត្រូវធ្វើការស៊ើបរកភស្តុតាងមួយដែលច្បាស់លាស់ ហើយវាគឺជាភស្តុតាងគ្រឹះដែលអាចនាំមកនូវការវិនិច្ឆ័យដោយយុត្តិធម៌។

បន្ទាប់ពីមានការទាញហេតុផលផ្ទាល់មាត់ ហើយនឹងការបង្គាប់ឱ្យភាគីដាក់ឯកសារត្រៀម[33]រួចរាល់ហើយ។ ឯកសារទាំងឡាយដែលបានដាក់ដោយគូរភាគី វាគឺជាភស្តុតាងមួយ ដែលមានកត់ត្រានូវសិទ្ធិ និងកាតព្វកិច្ចដែលគូរភាគីបានព្រមព្រៀងគ្នាមុនមានវិវាទ ឬក៏ឯកសារដែលបានចេញដោយអាជ្ញាធរមានសមត្ថកិច្ចនឹងអាចយកមកធ្វើការអះអាង ឬយកមកតតាំងចំពោះតតីយជនបាននៅមុខតុលាការបាន។ ឧទាហរណ៍ ៖ លោកដេវិត និងលោកវិជ្ជាបានបង្កើតកិច្ចសន្យាខ្ចីបរិភោគនៅទី១២ ធ្នូ ឆ្នាំ២០១៥ ដោយសន្យាថានឹងប្រគល់ជូនវិញនៅថ្ងៃខែដដែល ក្នុងឆ្នាំ២០១៦ ប៉ុន្តែដល់ថ្ងៃដែលបានកំណត់ លោកវិជ្ជាមិនសងមកលោកដេវិតវិញនោះទេ ហេតុនេះហើយលោកដេវិតត្រូវយកកិច្ចសន្យាទៅធ្វើការអះអាងនៅចំពោះមុខតុលាការដើម្បីបញ្ជាក់ពីសិទ្ធិរបស់ខ្លួន ក៏ដូចជាកាតព្វកិច្ចភាគីត្រូវបំពេញ។

ឧទាហរណ៍៖ លោកខា បានបង្កើតកិច្ចសន្យាទិញលក់អចលនទ្រព្យជាមួយលោកហេង ដោយលោកខាមានដីមួយកន្លែងនៅខេត្តបាត់ដំបង ក្រោយពីមានការព្រមព្រៀងគ្នារួចហើ អ្នកទាំងពីរទៅធ្វើការចុះបញ្ជីដើម្បីផ្ទេរកម្មសិទ្ធិឱ្យស្របទៅនឹងច្បាប់ ក្រោយពីលោកហេងក្លាយជាកម្មសិទ្ធិលើអចលនទ្រព្យ ស្រាប់តែពីឆ្នាំក្រោយមានតតីយជនមកអះអាងថាដីនេះជារបស់ខ្លួន។ នៅក្នុងឧទាហរណ៍នេះ ចៅក្រមត្រូវមានជំនាញក្នុងការពិនិត្យឯកសារឱ្យបានច្បាស់លាស់ មានន័យថាចៅក្រមពិនិត្យទៅលើ អាស័យដ្ឋាន របស់អ្នកបង្កើតកិច្ចសន្យាដើម្បីស្វែងសាក្សី ហត្ថលេខា ការបោះត្រា និងធាតុផ្សំជាផ្លូវការទៅលើឯកសារដែលចេញដោយស្ថាប័នមានសមត្ថកិច្ច និងបានទទួលស្គាល់ថាឯកសារនេះស្របច្បាប់។ ហេតុដូច្នេះចៅក្រមត្រូវមានចំណេះដឹងពិសេសសម្រាប់ធ្វើការវិភាគ ហើយនឹងអាចនាំឱ្យមានការកំណត់ច្បាស់លាស់ពីភាពត្រឹមត្រូវនៃឯកសារ ឬមិនត្រឹមត្រូវនៃឯកសារ បញ្ហានេះគឺជាកិច្ចការរបស់ចៅក្រម ដើម្បីស្វែងរកភស្តុតាងគ្រឹះក្នុងការវិនិច្ឆ័យដោយយុត្តិធម៌សម្រាប់ជូនទៅភាគីសុច្ចរិត។

យោងតាមបទបញ្ញត្តនៃក្រមនីតិវិធីរដ្ឋប្បវេណី បុគ្គលទាំងអស់មានទាំងរូបវន្តបុគ្គល ឬនីតិបុគ្គលតម្រូវឱ្យបង្ហាញភស្តុតាងបញ្ជាក់ពីភាពស្អាតស្អំសម្រាប់ខ្លួន ហើយការស្វះស្វែង

[33] មាត្រា១០១ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណីខ្មែរឆ្នាំ២០០៦

រកភស្តុតាងអាចប្រើបានគ្រប់មធ្យោបាយ ក៏ប៉ុន្តែមធ្យោបាយទាំងនោះត្រូវតែមានភាពត្រឹមត្រូវ ហើយនឹងភាពស្របច្បាប់។ ល្គឹកណាការស្វែងរកបានអ្វីដែលចង់រកនោះបានហើយភាគីអាចយកមកបង្ហាញពីភាពត្រឹមត្រូវរបស់ខ្លួនបាន។ វាគឺជាភស្តុតាងសម្រាប់ធ្វើអះអាងនៅចំពោះមុខចៅក្រមដើម្បីបញ្ជាក់ពីនត្ថិភាព និងអត្ថិភាពនៃសិទ្ធិដែលខ្លួនដែលមាន រីក៏ភស្តុតាងទាំងឡាយណា ដែលអាចនាំឱ្យចុងចម្លើយទទួលស្គាល់ថាខ្លួនថាបានប្រព្រឹត្តយ៉ាងពិតប្រាកដមែន ហើយនឹងមានទំនាក់ទំនងជាមួយភស្តុតាងទាំងនោះ វាជាភស្តុតាងដែលឈរលើមូលដ្ឋាននៃចំណុចដែលមានវិវាទនឹងនាំឱ្យភាគីម្ខាងបាត់សិទ្ធិ ដោយកំហុសរបស់ភាគីណាមួយដែលច្បាប់បានបញ្ញត្តិ អំពីការបាត់បង់សិទ្ធិដោយការបំពានរបស់បុគ្គលណាម្នាក់។

ឧទាហរណ៍ ៖ លោកស៊ីបានមកចាំដីចំការឱ្យលោកអេ ដោយលោកអេតែងផ្តល់ប្រាក់ខែទៅលោកស៊ីជារៀងរាល់ខែ ដប់ប្រាំឆ្នាំក្រោយលោកស៊ីបានធ្វើលទ្ធកម្មលើដីលោកអេពេលនោះវិវាទបានកើតឡើងរវាងលោកអេ និងលោកស៊ី។ ក្នុងករណីបុគ្គលណាជាអ្នកប្តឹងត្រូវស្វែងរកភស្តុតាង ដើម្បីធ្វើការបញ្ជាក់នៅចំពោះមុខតុលាការ ក្នុងការការពារសិទ្ធិ ឬទទួលសិទ្ធិនោះមកវិញ។ ក្នុងករណីនេះគូរភាគីត្រូវដាក់ឯកសារត្រៀមតាមការបង្គាប់របស់តុលាការ ហើយនៅក្នុងឯកសារត្រៀមត្រូវមានសរសេរអំពីមធ្យោបាយតទល់ ឬការពារខ្លួន និងសេចក្តីថ្លែងការណ៍ ចំពោះមធ្យោបាយតទល់ ឬការពារខ្លួនរបស់ភាគីម្ខាងទៀត[34]។ មានន័យថា ឯកសារត្រៀមដែលដាក់ទៅតុលាការលើកដំបូង វាគឺជាឯកសារចម្លើយរបស់ដើមចោទ ហើយឯកសារនេះត្រូវសរសេរពីអង្គហេតុឱ្យបានច្បាស់លាស់ ហើយនឹងការទាមទាររបស់ខ្លួនលើចំណុចវិវាទ។ គូភាគីត្រូវភ្ជាប់មកជាមួយលិខិតផ្សេងៗសម្រាប់យកមកបញ្ជាក់អំពីសិទ្ធិរបស់ខ្លួនដែលមាននៅលើវត្ថុវិវាទនោះផងដែរ ហើយវាជាលក្ខខណ្ឌតទល់ជាមួយភាគីម្ខាងទៀត ក្នុងការបញ្ជាក់ពីភាពស្របច្បាប់របស់ខ្លួន ដែលត្រូវបានរំលោភបំពានពីភាគីម្ខាង ដើម្បីយកមកបង្ហាញនៅចំពោះមុខចៅក្រម ហើយអ្វីដែលបានបង្ហាញរបស់ដើមបណ្តឹង វាគឺជាភស្តុតាងគ្រឹះសម្រាប់ធ្វើការដាក់បន្ទុកទៅលើចុងចម្លើយ មានន័យថាឯកសារទាំងឡាយដែលដើមបណ្តឹងបានដាក់ចូលទៅតុលាការដើម្បីទាមទារ គឺជាការដាក់បន្ទុកទៅដល់ចុងចម្លើយ ដើម្បីធ្វើការឆ្លើយតបនៅចំពោះមុខតុលាការ ហើយចុងចម្លើយត្រូវយកភស្តុតាងផ្ទុយមកបង្ហាញពីសិទ្ធិស្រប់ច្បាប់ហើយដែលច្បាប់បានទទួលស្គាល់នៅសិទ្ធិនោះ។

[34] មាត្រា១០១ ក្រមនីតិវិធីរដ្ឋប្បវេណីខ្មែរឆ្នាំ២០០៦កថាខណ្ឌទី២

ភស្តុតាងផ្ទាល់ គឺជាភស្តុតាងដែលកំណត់បាននូវអង្គហេតុថាជាអង្គហេតុពិត និងជាភស្តុតាងអាចកំណត់នូវអំពើអនីត្យានុកូលណាមួយរបស់ភាគីម្ខាង។ ភស្តុតាងផ្ទាល់ចង្អុលបង្ហាញច្បាស់ពីកំហុសរបស់ភាគីក្នុងរឿងក្តីវិវាទ ហើយនាំឱ្យចៅក្រមកំណត់បាននៅចំណុចវិវាទ និងអ្នកដែលបានប្រព្រឹត្ត(*អ្នកដែលបានរំលោភសិទ្ធិបុគ្គលដ៏ទៃ*)។ ភស្តុតាងផ្ទាល់នេះវាជាភស្តុតាងដែលមានភាពចាំបាច់ក្នុងការវិនិច្ឆ័យរបស់ចៅក្រមដោយយុត្តិធម៌ ហើយភាគីវិវាទមានភាគីម្ខាងមិនអាចតវ៉ាបាន ព្រោះវាជាអំពើរបស់ខ្លួនដែលបានរំលោភបំពានលើភាគីម្ខាងទៀតតាមរយៈការបង្ហាញភស្តុតាងផ្ទាល់ វាក៏ជាភស្តុតាងដែលមានការពាក់ព័ន្ធនានាជាមួយអំពើរបស់ចុងចម្លើយ ឬដើមចោទ។

កាបែងចែកភស្តុតាងផ្ទាល់ ហើយនឹងភស្តុតាងប្រយោលនេះ គឺវាបានធ្វើឱ្យយើងយល់កាន់តែច្បាស់នៅអង្គហេតុទាំងមូលតាមរយៈនីតិវិធីត្រៀម វាគឺជាការសួរដោយផ្ទាល់មាត់ហើយតាមរយៈនៃការសួរនេះ ដែលចៅក្រមអាចញែកបាននូវចំណុចវិវាទ និងចំណុចដែលគ្មានវិវាទបាន។ ជាទូទៅភស្តុតាងប្រយោល គឺជាខ្លឹមសារនៃអង្គហេតុដែលបង្ហាញឱ្យឃើញសក្ខីកម្ម ហើយក៏ជាទម្រង់នៃភស្តុតាងប្រយោលដែរ ប៉ុន្តែភស្តុតាងនេះវាអាចធ្វើការឆ្លើយតបទៅនឹងអង្គហេតុរណប គឺវាមិនមែនជាអង្គហេតុគ្រឹះនោះទេហើយអង្គហេតុរណបនេះ វាគឺជាជំនួយដែលអាចឱ្យភស្តុតាងផ្ទាល់មានភាពកាន់តែរឹងមាំងបាន ដើម្បីធ្វើការវិនិច្ឆ័យទៅលើរឿងក្តីបានយ៉ាងប្រសើរហើយច្បាស់លាស់។

### កថាភាគទី៣: ការពិនិត្យភស្តុតាងដោយសម្ភារវិធី

របកគំហើញ(*ភស្តុតាង*)ទាំងឡាយ ដែលតុលាការចាត់ទុកជាភស្តុតាងនៅដំណាក់កាលទាញហេតុផលក្នុងអង្គសេក្តី វាគឺជាកិច្ចការរបស់តុលាការ[35] ដែលបានកំណត់ដោយច្បាប់។ ដូច្នេះហើយបានជាតុលាការអាចសួរដេញដោលដោយផ្ទាល់មាត់ទៅលើភស្តុតាងដែលគូរភាគីដាក់ឱ្យតុលាការពិនិត្យនៅក្នុងដំណាក់កាលទាញហេតុផលនោះ យើងអាចពិនិត្យតាមមាត្រានានានៃក្រមនីតិរដ្ឋប្បវេណីខ្មែរ ដែលបានបញ្ញត្តិជាក់លាក់ក្នុងដំណាក់កាលនីមួយៗ។ ដូច្នេះតុលាការអាចធ្វើការពិនិត្យភស្តុតាងដែលជាបន្ទាន់នៅក្នុងដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់ដំបូង បន្ទាប់ពីបញ្ចប់ការរៀបចំចំណុចវិវាទ ហើយនឹងភស្តុតាងរួច។ នៅក្នុងន័យនេះប្រសិនបើតុលាការយល់ឃើញថាចាំបាច់នោះតុលាការអាច

[35] មាត្រា១២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

ប្រើឆន្ទានុសិទ្ធិរបស់ខ្លួនធ្វើការពិនិត្យភស្តុតាងជាបន្ទាន់បាន។ ប៉ុន្តែនៅចំណុចនេះដែរវាជាបញ្ហាដ៏ស្មុគស្មាញ ហើយបានតម្រូវឱ្យតុលាការរុករកឱ្យឃើញច្បាស់លាស់អំពីប្រភពនានានៃព័ត៌មានទាំងនោះវាពិតប្រាកកម្រិតណា នៅក្នុងនោះមានទាំងការសួរទៅលើសាក្សី ឬក៏សាម៉ីភាគីហើយក៏អាចធ្វើតាមនីតិវិធីសម្ភាវិធី ហើយឯកសារទាំងអស់ដែលបម្រុងនឹងប្រើនៅក្នុងការសួរសាក្សីត្រូវដាក់ជូននៅក្នុងអំឡុងពេលដែលសមរម្យមួយ រឺក៏នៅមុនពេលចាប់ផ្តើមធ្វើការសាកសួរទៅលើសាក្សីនោះ ប៉ុន្តែមានការលើកលែងលើឯកសារដែលនឹងប្រើជាភស្តុតាង ដើម្បីប្រជែងលើភាពជំនឿនៃសេចក្តីថ្លែងការណ៍របស់សាក្សីគេហៅថាសម្ភាវិធីនៃការប្រមូលភស្តុតាង ឬអាចហៅបានថារបកគំហើញ ហើយរបកគំហើញទាំងនោះ ត្រូវបានរកឃើញពីការប្រមូលភស្តុតាងនានា ដូចមានបញ្ញត្តក្នុងក្រមនីតិវិធីរដ្ឋប្បវេណីខ្មែរស្រាប់។

នៅក្នុងនីតិវិធីរដ្ឋប្បវេណីនៃប្រទេសកម្ពុជា ក៏បានកំណត់អំពីការរុករកនូវខណៈនានាដែលជាធាតុផ្សំនៃអង្គហេតុដែលនាំឱ្យកើតមានឡើងក្នុងដំណាកកាលនីតិវិធីត្រៀម។ ការស្នើរសុំចៅក្រមធ្វើការអង្កេតឱ្យបានច្បាស់លាស់នូវខណៈនានានោះ គេមានមធ្យោបាយពីរដើម្បីអង្កេតពីជំហាននៃការផ្តល់សក្ខីកម្ម គឺ«មធ្យោបាយបឋម និងមធ្យោបាយនៃការស៊ើបសួរ» ។

ការស៊ើបអង្កេតបឋម គឺតម្រូវក្នុងការប្រមូលភស្តុតាងទាំងឡាយ ដើម្បីបញ្ជូនទៅឱ្យចៅក្រមដើម្បីធ្វើការត្រួតពិនិត្យ រឺក៏អាចមានការពិនិត្យលើភស្តុតាងដែលត្រូវធ្វើភ្លាមៗបាន[36] ហើយភស្តុតាងទាំងនោះធូនល្មមក្នុងការសម្រេចសេចក្តីបាន ឬមួយត្រូវតម្រូវមានភស្តុតាងបន្ថែមទៀត។

មធ្យោបាយនៃការស៊ើបសួរ គឺជាការបង្ហាញដោយផ្ទាល់មាត់របស់ដើមបណ្តឹង និងចុងចម្លើយ ដែលគូភាគីត្រូវសរសេរនៅសារណាក្នុងការដាក់បន្ទុក និងការដោះបន្ទុករបស់ខ្លួន និងការស្តាប់ចំលើយរបស់សាក្សី ឬការសារភាពនៅចំពោះមុខតុលាការរបស់ភាគីណាមួយ រឺអង្គហេតុដែលតុលាការយល់ឃើញថាជាក់ស្តែង តុលាការពុំចាំបាច់ទទួលស្គាល់អង្គហេតុនោះដោយផ្អែកលើភស្តុតាងទេ[37]។ តុលាការអាចធ្វើការពិនិត្យភស្តុតាងតាមការស្នើ

[36] មាត្រា១៣១នៃក្រមនីតិវិធីរដ្ឋប្បវេណីខ្មែរ២០០៦
[37] មាត្រា១២៣នៃក្រមនីតិវិធីរដ្ឋប្បវេណីខ្មែរ២០០៦

សុំរបស់ភាគី ហើយភាគីដែលបានស្នើសុំ ត្រូវកំណត់ឱ្យបានជាក់លាក់នៃអង្គហេតុ ហើយនឹងបញ្ជាក់ឱ្យច្បាស់លាស់ពីអត្តសញ្ញាណរបស់តតីយជននោះ។

# ជំពូកទី៣

# ការបញ្ជាក់ភស្តុតាង

## ផ្នែកទី១: នីតិវិធីនៃការបញ្ជាក់ភស្តុតាង

ចំពោះទម្រង់នីតិវិធីនៃការបញ្ជាក់ភស្តុតាង គឺជាមធ្យោបាយក្នុងការទទួលយកភស្តុតាងត្រឹមត្រូវតាមច្បាប់ ដូចមានចែងក្នុងជំពូកទី៣«ការពិនិត្យភស្តុតាង» «ការទទួលយកភស្តុតាង» «ការពិនិត្យភស្តុតាងដោយសម្ភារិធី» ដែលមានការលេចឡើងនូវការទាញហេតុផលដោយផ្ទាល់មាត់ទាំងអស់នេះមានក្នុង«ការបញ្ជាក់ភស្តុតាង»។

«នត្ថិភាព និងអត្ថិភាពនៃសិទ្ធិ» នៅក្នុងន័យនេះយើងខ្ញុំបានធ្វើការបកស្រាយខាងលើខ្លះៗដែរហើយ មានន័យថាពេលព្រឹត្តិការណ៍បានកើតឡើងនោះ នាំឱ្យមានការបង្ហាញឱ្យឃើញពីសិទ្ធិរបស់រូបវន្តបុគ្គល ឬក៏នីតិបុគ្គលដែលមានក្នុងកិច្ចសន្យា ឬនៅក្នុងលិខិតគតិយុត្តណាមួយ។ ក្នុងចំណុចនេះចៅក្រមត្រូវព្យាយាមគ្រប់មធ្យោបាយ ដើម្បីរកប្រភពនៃអង្គហេតុពិតសិនទើបចៅក្រមអាចធ្វើការផ្ទៀងផ្ទាត់ភស្តុតាងទាំងអស់ ហើយនឹងធ្វើការវិនិច្ឆ័យឱ្យមានភាពយុត្តិធម៌ដល់ម្ចាស់សិទ្ធិដែលបានទាមទារសិទ្ធិមកវិញ។

ហេតុដូច្នេះហើយ ដើម្បីដោះស្រាយឱ្យបានត្រឹមត្រូវទៅលើចំណាត់ការក្នុងរឿងរដ្ឋប្បវេណី ចៅក្រម ឬក៏ស្ថាប័នតុលាការត្រូវពឹងផ្អែកទាំងស្រុងទៅលើភស្តុតាងនានា។ គ្រប់ភស្តុតាងដែលកើតចេញពីព្រឹត្តិការណ៍ណាមួយនៅក្នុងរឿងវិវាទ ភស្តុតាងដែលប្រមូលបានតាមនីតិវិធីដែលបានកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី វាគឺជាវិធានជាក់លាក់ដែលអាចហៅបានថា«មធ្យោបាយបញ្ជាក់ភស្តុតាង»។ មធ្យោបាយនានាដែលនាំឱ្យគេយល់បាននូវខ្លឹមសារទាំងឡាយនៅក្នុងអង្គហេតុ និងខ្លឹមសារនៃព្រឹត្តិការណ៍ហើយមធ្យោបាយទាំងនោះ នាំឱ្យចៅក្រមធ្វើការសម្រេចសេចក្តីមួយប្រកបដោយភាពត្រឹមត្រូវ និងមានតម្លាភាពលើរឿងក្តី

មធ្យោបាយទាំងនេះអាចហៅបានតាមទ្រឹស្តីថាការបញ្ជាក់ភស្តុតាង។ ការបង្ហាញភស្តុតាងទាំងឡាយត្រូវធ្វើឡើងតាមអត្ថិភាពនៃអង្គហេតុ ដោយការបង្ហាញភស្តុតាងនោះត្រូវគោរពឱ្យបានហ្មត់ចត់តាមលំហូរនៃក្រមនីតិវិធីរដ្ឋប្បវេណី។

កម្មវត្ថុនៃការបញ្ជាក់ភស្តុតាង គឺជានីតិវិធីក្នុងការបង្ហាញនូវសកម្មភាពរបស់ភាគីម្ខាងដែលបានបំពានទៅលើសិទ្ធិរបស់ភាគីម្ខាងទៀត ហើយក៏ជានីតិវិធីដែលបានកំណត់នៅក្នុងនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ក្នុងជំពូកទី៣។

នៅក្នុងរឿងរដ្ឋប្បវេណីការបញ្ជាក់ភស្តុតាង គឺត្រូវធ្វើឡើងដោយគូវិវាទក្នុងការស្វែងរកភស្តុតាងមកបញ្ជាក់នៅចំពោះមុខតុលាការ ដើម្បីទទួលបាននូវសិទ្ធិពីការបំពាននោះមកវិញ។ នៅក្នុងការបញ្ជាក់នូវភស្តុតាងរបស់គូភាគីនេះដែរ ភាគីនីមួយៗត្រូវប្រមូលឯកសារទាំងឡាយដែលមានការពាក់ព័ន្ធ ហើយខ្លួនយល់ថាមានប្រយោជន៍សម្រាប់ខ្លួនយកមកធ្វើការបញ្ជាក់នៅចំពោះមុខចៅក្រម ក៏ប៉ុន្តែគូភាគីត្រូវមានភាពស្មោះត្រង់ក្នុងការធ្វើបណ្ដឹង[38] ដូច្នេះគូភាគីមិនអាចផ្ដល់ភស្តុតាងខ្លែង ឬក៏សក្ខីកម្មខ្លែងក្លាយបាននោះទេ ទាំងអស់នេះគេអាចហៅបានថាដំណើរការនៃសក្ខីកម្ម។

### កថាភាគទី១: មធ្យោបាយនៃការបង្ហាញភស្តុតាង

រាល់មធ្យោបាយក្នុងការបង្ហាញអង្គហេតុ រឺការបង្ហាញហេតុការណ៍ទាំងឡាយ ដែលអង្គហេតុទាំងនោះបានបង្កើតឱ្យមានវិវាទ។ ដូច្នេះដើម្បីធ្វើការដោះស្រាយឱ្យបានត្រឹមត្រូវលើរឿងក្ដីរដ្ឋប្បវេណី គឺត្រូវតែពឹងផ្អែកទាំងស្រុងនៅលើ«*ភស្តុតាង*»នានា។ មធ្យោយនានាដែលស្តែងចេញជាភស្តុតាងតាមរយៈអង្គហេតុ ត្រូវសម្រេចឱ្យត្រឹមត្រូវតាមរយៈការបង្ហាញភស្តុតាង ឬការបង្ហាញសក្ខីកម្ម។

គ្រប់វត្ថុតាងវាត្រូវតែផ្សាភ្ជាប់ជាមួយនឹងកម្មវត្ថុនៃការបង្ហាញសក្ខីកម្ម ដោយក្នុងនោះវាសម្គាល់យ៉ាងច្បាស់នូវកម្មវត្ថុដែលនាំឱ្យមានវិវាទ។ ឧទាហរណ៍៖ លោកវិចិត្របានបង្កើតកិច្ចសន្យាខ្ចីបរិភោគជាមួយលោកតារា ហើយក្នុងកិច្ចសន្យាបានចែងពីការយល់ព្រមទទួលស្គាល់នូវកម្មវត្ថុនៃកិច្ចសន្យាមួយចំនួនមានដូចជា៖ មានការប្រាក់៣%ក្នុងមួយខែ មានការពិន័យក្នុងករណីមានការយឺតយ៉ាវនៃការសង ហើយយល់ព្រមលក់ផ្ទះសងបើមិនមានលុយ

[38] មាត្រា៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

សម្រាប់សង ។ល។ នៅក្នុងចំណុចទាំងអស់ខាងលើ វាពិតជាមានចំណុចវិវាទ និងចំណុចដែលមិនមានវិវាទបង្ហាញឡើងឱ្យឃើញ ដូច្នេះហើយគូរភាគីត្រូវបង្ហាញភស្តុតាងរៀងៗខ្លួនដើម្បីធ្វើការដាក់បន្ទុក ឬក៏ដោះបន្ទុក។

ការដោះស្រាយសំណុំរឿងរដ្ឋប្បវេណី គឺដាច់ខាតត្រូវបែងចែកឱ្យបានច្បាស់លាស់នៅចំណុចវិវាទ និងចំណុចមិនមានវិវាទតាមរយៈការបង្ហាញភស្តុតាង និងការបំភ្លឺរបស់គូភាគីវិវាទ។

អត្ថន័យលើកម្មវត្ថុនៃការបង្ហាញភស្តុតាង គឺជាការកំណត់ ឬក៏ការបែងចែកជាផ្នែកៗនូវចំណុចវិវាទ ហើយនឹងចំណុចមិនមានវិវាទ ទាំងអស់នេះគេអាចហៅថា ភាពទាក់ទិននៃភស្តុតាងដែលនាំចៅក្រមធ្វើការដាក់ចំនាត់ថ្នាក់ទៅលើភស្តុតាងដាច់ដោយឡែកពីគ្នា ដើម្បីទទួលបានការវិនិច្ឆ័យមួយដ៏យុត្តិធម៌សម្រាប់គូភាគីវិវាទ។

តុលាការត្រូវអនុវត្តន៍ឱ្យបានត្រឹមត្រូវលើការសម្រេចសេចក្តី ក្នុងន័យនេះចង់បញ្ជាក់ថារាល់សកម្មភាពដែលប្រព្រឹត្តដោយបុគ្គលណាម្នាក់ បុគ្គលនោះត្រូវតែទទួលខុសត្រូវលើអំពើរបស់ខ្លួន ប៉ុន្តែក្នុងករណីរឿងក្តីរដ្ឋប្បវេណីវិញ គឺថាអ្នកទទួលមរតកគឺជាអ្នកបំពេញកាតព្វកិច្ចជំនួសមតកជនវិញ។ នៅក្នុងរឿងក្តីរដ្ឋប្បវេណី មានអង្គហេតុមួយចំនួនដែលអ្នកបំពេញកាតព្វកិច្ចនោះ មិនមែនជាបុគ្គលដែលបានព្រឹត្តនៅសកម្មភាព(*ការបង្កើតកិច្ចសន្យា*) ដូចមានចែងក្នុងច្បាប់សារធាតុ[39] មានន័យសន្តតិជនត្រូវទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចទាំងអស់ ក្នុងពេលដែលសន្តតិជនស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មរតកជនចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្ម[40]។

ក្នុងករណីនេះចាំបាច់ត្រូវបានផ្សារភ្ជាប់គ្នាទៅវិញទៅមក ដែលមិនអាចខ្វះបានព្រោះថាការសិក្សាវាយតម្លៃទៅលើអំពើត្រូវមានភាពស៊ីសង្វាក់គ្នាជាមួយភស្តុតាង និងវិវាទនោះផងដែរ ប៉ុន្តែអ្នកដែលមានវិវាទនោះ! បានបាត់បង់ជីវិត្តដោយបន្សល់ទុកកាតព្វកិច្ចរបស់ខ្លួនឱ្យសន្តតិជន ហើយសន្តតិជននោះ គឺជាអ្នកបំពេញកាតព្វកិច្ចជំនួសខ្លួនដោយអានុភាពនៃសន្តតិកម្មដែលបានកើតមានឡើង។

ឧទាហរណ៍៖ លោកDបានផ្ទេរមរតកខុនដូរ មួយកន្លែងនៅឯក្រុងព្រះសីហានុ ទៅឱ្យកូនរបស់គាត់ គឺលោកEដែលខុនមានតម្លៃមួយលានដុល្លា។ ក្រោយពីលោកDបានទទួល

---

[39] អ្នកទទួលមរតក (ដែលមរតកជនមានជាប់កាតព្វមិនទាន់បំពេញចប់)

[40] មាត្រា១១៤៧កថាខណ្ឌទី១នៃក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ២០០៧

មរណៈភាព លោកFបានយកកិច្ចសន្យាដែលលោកDបានជំពាក់ប្រាក់គាត់ពីតម្លៃសាងសង់ខុនដូរ ដែលមានចំនួនទឹកប្រាក់ម្ភៃម៉ឺនដុល្លា ដូច្នេះលោកEគាត់ត្រូវរកវិធីដោះស្រាយដើម្បីសងសំណងទៅឱ្យលោកFក្នុងនាមជាទាយាទ។ ប៉ុន្តែក្នុងករណីលោកEមិនចង់សង ឬក៏មានចេតនាមិនសងទៅលោកF។ លោកFត្រូវដាក់ពាក្យប្តឹងដើម្បីឱ្យកូនបំណុលខ្លួន ដែលជាទាយាទបំពេញកាតព្វកិច្ចជំនួសមតកជន ដោយយកអំណាចតុលាការមកអនុវត្ត ដូចនេះហើយ ដើមចោទត្រូវយកភស្តុតាងដែលមានការពាក់ព័ន្ធ និងស្វែងរកភស្តុតាងផ្សេងៗដើម្បីផ្តល់ឱ្យតុលាការធ្វើការពិនិត្យ និងវិនិច្ឆ័យតាមការទាមទាររបស់ខ្លួន ប៉ុន្តែការវិនិច្ឆ័យណាមួយដែលនាំឱ្យអ្នកចាញ់ក្តីមានការឈឺចាប់នោះ ដូច្នេះមានន័យថាសេចក្តីសម្រេចបែបនោះវាបញ្ជាក់ពីសញ្ញាណនៃចំនុចអវិជ្ជមានចំពោះការពិចារណារបស់ចៅក្រម។

តែបើសេចក្តីសម្រេចធ្វើឱ្យអ្នកដែលត្រូវឈ្នះក្តីបាត់បង់នូវសេចក្តីសង្ឃឹម ចៅក្រមជានិម្មិតរូបនៃអយុត្តិធម៌ក្នុងសង្គម មានន័យថាតម្លៃរបស់ភាពត្រឹមត្រូវនៃភស្តុតាង ធ្វើឱ្យសេចក្តីសម្រេចរបស់តុលាការម្ចាប់បាននូវគ្រប់ចំនុចវិវាទនៃរឿងក្តី បើទោះជាចាញ់ក្តីបង្ហាញនូវអប្បកិរិយាមិនទទួលយកក៏ដោយ ក៏ក្នុងចិត្តរបស់គេទទួលស្គាល់ដោយស្ងប់ស្ងៀមរួចស្រេចទៅហើយចំពោះសេចក្តីសម្រេចបែបនោះ។ ជាទូទៅយើងឃើញថា អ្នកចាញ់ក្តីតែងតែសម្តែងចេញមកក្រៅនូវឥរិយាបថមិនសមគួរ ក៏ប៉ុន្តែឥរិយាបថបែបនេះវាគ្រាន់តែជាឥរិយាបថដើម្បីការពារសេចក្តីថ្លៃថ្នូរបស់ខ្លួនគេនៅចំពោះមុខសាធារណៈជនប៉ុណ្ណោះ។ ចំណែកអ្នកឈ្នះវិញតែងតែមានគំនិតថាទោះជាមិនបានសំណងដោយមិនទាន់សម និងតាមតម្រូវការរបស់គេក៏ដោយ តែចំពោះភស្តុតាងដែលគេបង្ហាញទៅតុលាការនាំឱ្យគេបានទទួលសិទ្ធិពីការបំពានរបស់គូភាគីវិវាទរបស់គេមកវិញដែរ ហើយអ្នកនោះបានទទួលយកក្នុងចិត្តរបស់គេរួចទៅហើយនូវសេចក្តីសម្រេចត្រឹមត្រូវរបស់តុលាការ មានន័យថាចៅក្រមបានការអនុវត្តត្រឹមត្រូវក្នុងការសម្រេចសេចក្តីតាមភស្តុតាងដែលមាន។

**កថាភាគទី២: ដំណើរការនៃសក្ខីកម្ម**

កម្មវត្ថុនៃសក្ខីកម្ម វាគឺជានីតិវិធីក្នុងការបង្ហាញភស្តុតាងរបស់គូភាគី ទៅតាមនីតិវិធីដែលច្បាប់បានកំណត់។ ចំពោះការបង្ហាញភស្តុតាងអាចនឹងមានការបន្សល់ទុកនូវខ្លឹមសារមិនអាចខ្វះខាតបានឡើយ ហើយតាមរយៈសភាវៈ និងខណៈនានាដែលនាំឱ្យវិវាទមួយ

បានបង្កើតឡើងហើយ វាអាចបង្ហាញឱ្យឃើញភស្តុតាងមានដូចជា៖ វត្ថុ សាក្សី ឯកសារដែលពាក់ព័ន្ធទាំងឡាយ...។

ដំណើរការនៃសក្ខីកម្ម គឺជាមធ្យោបាយដើម្បីធ្វើការបញ្ជាក់ភស្តុតាង ដែលត្រូវបានកំណត់ដោយច្បាប់ និងមានភាពជាក់លាក់អំពីភាពត្រឹមត្រូវនៃអង្គហេតុ។ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីក្នុងជំពូកទី៣បានកំណត់ខ្លឹមសារជាច្រើន បើសិក្សានៅក្នុងជំពូកនេះមានដូចជា៖ «ការពិនិត្យភស្តុតាង» «ការទទួលយកភស្តុតាង» «ការសាកសួរសាក្សី» «ការសាកសួរភាគី» និង«ការធ្វើកោសលវិច័យ» ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីគេបានកំណត់ថា តុលាការទទួលស្គាល់អង្គហេតុផ្អែកលើភស្តុតាងជាមូលដ្ឋាន[41]។ ជាទូទៅនៅក្នុងរឿងក្តីរដ្ឋប្បវេណីមធ្យោបាយក្នុងការប្រមូលភស្តុតាងគឺកើតចេញពីដើមចោទ មានន័យថាដើមចោទ«*ដើមបណ្តឹង*»ក្នុងរឿងក្តីរដ្ឋប្បវេណីត្រូវប្រមូលភស្តុតាងដែលខ្លួនឯងមានទ ដើម្បីធ្វើការបង្ហាញទៅចៅក្រម និងធ្វើឱ្យចៅក្រមជឿជាក់ក្នុងការធ្វើសេចក្តីវិនិច្ឆ័យមួយ ដែលអាចផ្តល់ឱ្យគូភាគីដោយយុត្តិធម៌គឺអាស្រ័យទៅលើភស្តុតាងដែលមាននោះ។ ភស្តុតាងចាំបាច់ត្រូវតែបញ្ចេញឱ្យឃើញនៅអង្គហេតុពិតប្រាកដមួយ ជាទូទៅអង្គហេតុនោះមានការចាំបាច់ត្រូវតែបញ្ចេញឱ្យឃើញនូវខ្លឹមសារដែលជាភស្តុតាង ហើយនឹងភាពសមស្របមួយទៅនឹងអត្ថិភាពនៃសិទ្ធិរបស់ភាគីណាមួយនៅក្នុងវិវាទនោះ។ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ក្នុងករណីដែលពុំមានភាពច្បាស់លាស់ទេតុលាការអាចធ្វើការសាកសួរសាក្សីបាន ដើម្បីបញ្ជាក់បន្ថែមទៅលើភស្តុតាង និងនាំឱ្យមានភាពរឹងមាំក្នុងការធ្វើសេចក្តីសម្រេចដោយយុត្តិធម៌មួយរបស់ចៅក្រមទៅកាន់គូភាគី។

ភស្តុតាងជាវត្ថុ គឺសំដៅលើឯកសារនៅក្នុងវិវាទ នៅក្នុងន័យនេះយើងអាចសិក្សាលើវិវាទកម្មសិទ្ធិបញ្ញាដែលភាគីត្រូវស្វែងរកវត្ថុក្លែង ឬស្រដៀងគ្នា ហើយទាំងអស់នេះគឺសំដៅលើតក្កកម្ម រឺក៏ពាណិជ្ជនាម និងម៉ាកដែលបានចុះបញ្ជីនៅការិយាល័យចុះបញ្ជីរបស់ក្រសួងពាណិជ្ជកម្ម ដែលត្រូវយកមកឱ្យតុលាការធ្វើកោលសវិច័យទៅលើវត្ថុនោះ ដើម្បីរុករកឱ្យឃើញនូវប្រភពព័ត៌មានពិតដែលអាចយកមកបង្ហាញបានថាវាជាភស្តុតាងជាក់លាក់។ គឺជាការពិតណាស់! ដោយសារតែកម្មវត្ថុនៃការបញ្ជាក់សក្ខីកម្មទៅលើភស្តុតាងនីមួយៗ ហើយនឹងការប្រើប្រាស់មធ្យោបាយដោយឡែកៗពីគ្នា គឺវាអាស្រ័យទៅលើអំពើរបស់ចុងចំលើយ

[41] មាត្រា១២៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីខ្មែរឆ្នាំ២០០៦

ទើបក្រមនីតិវិធីរដ្ឋប្បវេណីខ្មែរបានកំណត់អំពីការសើបសួរ និងការពិនិត្យភស្តុតាងដោយគោរពតាមបញ្ញត្តិមួយចំនួនដូចមានក្នុងមាត្រា៖ ១៣២. ១២៧. ១៤៣.....។ ពីព្រោះខណៈនានាចំពោះការប្រព្រឹត្តរបស់ចុងចំលើយ រឺក៏ដើមចោទមិនដូចគ្នាទេដូចជាឧទាហរណ៍ខាងលើដែលមានស្រាប់។

ចំពោះអត្ថន័យនៃការបញ្ជាក់សក្ខីកម្មនេះ ក៏ឆ្លើយតបទៅនឹងការផ្ទៀងផ្ទាត់ និងវាយតម្លៃទៅលើប្រភេទនៃភស្តុតាងផងដែរ ប៉ុន្តែក្នុងករណីចៅក្រម ឬអ្នកធ្វើកោសលវិច័យមានការយល់ដឹងទាបទៅលើកម្មវត្ថុនៃការបញ្ជាក់សក្ខីកម្ម នោះអត្ថន័យនៃការបញ្ជាក់សក្ខីកម្មនឹងក្លាយជាភាពងងឹតចំពោះសេចក្តីសម្រេចរបស់តុលាការ។ ចំពោះការយល់ដឹងដែលមានកំរិតទាបបែបនេះ វានាំឱ្យកើតមានគុណវិបត្តិធ្ងន់ធ្ងរចំពោះការវាយតម្លៃទៅលើប្រភេទនៃភស្តុតាងនានាផងដែរ។ ចំពោះខ្លឹមសារនៃការបញ្ជាក់សក្ខីកម្មវាបានចងភ្ជាប់សមត្ថភាពរបស់ចៅក្រមដោយយោងតាមស្មារតីនៃច្បាប់ ដូច្នេះចៅក្រមត្រូវស្វែងរកឱ្យឃើញនូវរបកគំហើញនៃភស្តុតាងដោយមានសមត្ថភាពខ្ពស់គ្រប់គ្រាន់ មានន័យថាដំណើរការសក្ខីកម្ម គឺត្រូវរកឱ្យឃើញនូវកំហុសដែលពឹងផ្អែកលើវិធាន ដែលត្រូវយកមកប្រៀបធៀបដោយផ្តោតទៅនឹងខណៈនានារបស់បុគ្គលតាមរយៈព្រឹត្តិការណ៍ដែលកើតឡើងនោះ ក្នុងស្ថានភាពប្រក្រតីភាព ហើយនឹងព្រឹត្តិការណ៍ដែលកើតមានឡើងក្នុងស្ថានភាពមិនប្រក្រតីភាព ហើយអំពើទាំងនេះមានបំណងធ្វើឱ្យបាត់បង់សិទ្ធិរបស់បុគ្គលណាម្នាក់លើទ្រព្យរបស់បុគ្គលនោះ។

## កថាភាគទី៣: ភស្តុតាងតាមការបំភ្លឺរបស់ដើមចោទ និងចុងចម្លើយ

យោងតាមក្រមនីតិវិធីរដ្ឋប្បវេណីខ្មែរ ដើមចោទត្រូវបំភ្លឺនៅចំពោះមុខចៅក្រមពីអង្គហេតុដែលខ្លួនបានប្តឹងទៅលើចុងចម្លើយ។ ហើយតាមរយៈការបំភ្លឺនេះដែរ វាគឺជាប្រភេទនៃភស្តុតាងមួយដ៏មានសារៈប្រយោជន៍ក្នុងការកំណត់បាននូវចំណុចវិវាទ និងចំណុចដែលគ្មានវិវាទដើម្បីកំណត់នីតិវិធីបន្ត។ ហេតុដូចនេះហើយបានជាគេធ្វើការបែងចែកឱ្យដាច់ពីគ្នានូវការបំភ្លឺរបស់ដើមចោទ និងតាមការបំភ្លឺរបស់ចុងចម្លើយ ក៏ដូចតាមការបំភ្លឺរបស់សាក្សីដើម្បីងាយស្រួលក្នុងការកំណត់នូវចំណុចវិវាទនានាដែលទាក់ទងនឹងអង្គហេតុ។ ការបំភ្លឺរបស់ដើមចោទត្រូវគោរពតាមគោលការណ៍ច្បាប់ដែលបានកំណត់រួច ដូច្នេះដើមចោទត្រូវទៅបំភ្លឺនៅចំពោះមុខចៅក្រមលើបណ្តឹងរបស់ខ្លួន ដែលត្រូវអនុវត្តន៍តាមនីតិវិធីទាញហេតុផលផ្ទាល់មាត់ ប៉ុន្តែក្នុងករណីនេះ ត្រូវមានការសម្រេចពីចៅក្រមដោយឆន្ទានុសិទ្ធិ រឺក៏មាន

ដីកាសម្រេចថាត្រូវមាននីតិវិធីលើការទាញហេតុផលផ្ទាល់មាត់ រឺក៏មិនចាំបាច់មានការទាញហេតុផលដោយផ្ទាល់មាត់នៅចំណុចណាមួយ[42]។ ការទាញហេតុផលផ្ទាល់មាត់ត្រូវកំណត់កាលបរិច្ឆេទទៅលើការបង្ហាញខ្លួននៅចំពោះមុខតុលាការ[43] ជាការពិតការទាញហេតុផលផ្ទាល់មាត់នេះដែរត្រូវធ្វើឡើងសាធារណៈដោយគ្មានការបង្ខិតបង្ខំអ្វីទាំងអស់ តែបើសិននាំឱ្យខូចខាតសណ្តាប់ធ្នាប់សង្គមនោះច្បាប់មិនអនុញ្ញាតិឡើយ។

ម្យ៉ាងទៀតគូភាគីនៃវិវាទត្រូវស្វែងរកភស្តុតាងជាសម្ភារៈសច្ចភាព ដែលអាចបង្ហាញនៅចំពោះមុខចៅក្រមដើម្បីទទួលបានយុត្តិធម៌។ ដូច្នេះត្រូវស្វែងយល់ពី«សម្ភារៈសច្ចភាពនៃភស្តុតាង» តាមន័យភស្តុតាងជាសម្ភារៈសច្ចភាពក្នុងអត្ថន័យទស្សនៈគឺ៖ ការយល់ដឹងពីសច្ចភាពនៃភស្តុតាងជាសម្ភារៈ គឺដូចគ្នានិងន័យ«*យថាភាព*» ឬក៏អាចនិយាយបានថាភាពពិតនៃខណៈ(*អំពើដែលបានកើតឡើង*)។ ជាធម្មតាសច្ចភាពនៃភស្តុតាងបានបម្រើដល់ការសម្រេចសេចក្តីមួយរបស់ចៅក្រមប្រកបដោយហេតុផលច្បាស់លាស់បំផុត ហើយមានការពឹងផ្អែកលើភស្តុតាងទាំងស្រុង។ ការធ្វើសេចក្តីសម្រេចដោយផ្អែកតាមភស្តុតាង វាគឺជាទស្សនវិជ្ជាមួយដែលប្រកបដោយភាពសុក្រឹត្យ ហើយនឹងសច្ចធម៌របស់មនុស្សនៅក្នុងសង្គម។ យោងតាមទស្សនវិជ្ជារបស់លោក «អារីស្តូត» បានឱ្យនិយមន័យ យុត្តិធម៌ដោយផ្អែកទៅលើកត្តាពីរ គឺកត្តាស្មេរភាព និងកត្តាក្រមសីលធម៌ បើនិយាយពីកត្តាក្រមសីលធម៌គេតែងតែឃើញមាននៅជាមួយអ្នកដែលមានប្រកបរបរវិជ្ជាជីវៈមានដូចជា៖ ចៅក្រម មេធាវី ព្រះរាជអាជ្ញា ... ។

ដែលក្រមសីលធម៌នេះមានសារៈសំខាន់បំផុតចំពោះអ្នកប្រកបវិជ្ជាជីវៈ តែបើកាលណាអ្នកប្រកបវិជ្ជាជីវៈបាត់បង់ក្រមសីលធម៌នឹងនាំឱ្យមានភាពអយុត្តិធម៌ក្នុងសង្គម ហើយសង្គមនឹងកើតមានឡើងនៅចលាចលតាមរយៈពួកអ្នកទាំងនោះ។ ហេតុដូច្នេះហើយបានជាចៅក្រមត្រូវធ្វើការសម្រេចសេចក្តីនៅក្នុងរឿងក្តីនីមួយៗ គឺត្រូវគោរពគោលការណ៍សច្ចភាពនៃភស្តុតាង ដើម្បីរក្សាបាននូវស្ថិរភាពនៅក្នុងសង្គម និងចៀសវៀងការបំពានសិទ្ធិពីជនទុច្ចរិតទាំងអស់នោះ ហើយនឹងអ្វីៗទាំងអស់ដែលបានកើតឡើង គឺបានបញ្ជាក់ពីកត្តានៃក្រមសីលធម៌របស់ចៅក្រមក្នុងការសម្រេចសេចក្តី។

[42] មាត្រា១១៤នៃក្រមនីតិវិធីរដ្ឋប្បវេណីខ្មែរ២០០៦

[43] មាត្រា១១៥នៃក្រមនីតិវិធីរដ្ឋប្បវេណីខ្មែរ២០០៦

ដោយផ្អែកតាមបំណកស្រាយខាងលើ យោងតាមទស្សនវិជ្ជាសច្ចភាពនៃភស្តុតាងនេះហើយ ទើបក្រមរដ្ឋប្បវេណីបានបញ្ញត្តិក្នុងគោលការណ៍ជាមូលដ្ឋានដែលបានចែងថាៈ ក្រមនេះកំណត់អំពីគោលការណ៍នៃការធានាសេចក្ដីថ្លៃថ្នូររបស់បុគ្គល និងភាពស្មើគ្នារបស់បុរស់ នារី និងទ្រព្យសម្បត្តិដែលត្រូវបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ[44]។

**ផ្នែកទី២: ការបញ្ជាក់ភស្តុតាងដោយការធ្វើកោសលវិច័យ**

នៅក្នុងផ្នែកនេះ យើងពិភាក្សាទៅលើការបញ្ជាក់ភស្តុតាង ដែលតុលាការអាចទទួលយកបាននៅក្នុងការសម្រេចសេចក្ដី។ នៅក្នុងន័យនេះយើងផ្ដោតទៅលើពាក្យថា«កោសលវិច័យ» គឺជាការពិនិត្យទៅលើវត្ថុតាងដោយអ្នកជំនាញ ក្នុងការបញ្ជាក់ប្រាប់ទៅតុលាការអំពីភាពច្បាស់លាស់នៅក្នុងព្រឹត្តិហេតុមួយដែលអាចទុកចិត្តបាន។

គ្រប់ភស្តុតាងទាំងអស់ គឺត្រូវបានឆ្លងកាត់ការធ្វើកោសលវិច័យពីអ្នកជំនាញ ដើម្បីបញ្ជាក់ពីភាពច្បាស់លាស់របស់វាក៏ដូចជាទំនាក់ទំនងរវៀងសកម្មភាពគូភាគី និងអង្គហេតុដែលតុលាការអាចទទួលយកមកធ្វើការសម្រេចសេចក្ដីបានដោយយុត្តិធម៌។

ប៉ុន្តែមានភស្តុតាងមួយចំនួន គឺច្បាប់បានកំណត់ជារួចស្រេចហើយ ការកំណត់របស់ច្បាប់នេះ គឺជាការជួយសម្រួលទៅឱ្យភាគីម្ខាងដែលខ្វះសមត្ថភាព។

ឧទាហរណ៍ៈ ទារកដែលបានប្រសូតពីផ្ទៃម្ដាយនៅក្នុងពេលដែលគូរសហាព័ទ្ធបានផ្ដាច់លំនៅសង្វាសនឹងគ្នា ក្នុងករណីនេះតុលាការសន្មត់ថា ទារកនោះជាកូនរបស់គូភាគីរហូតដល់មានភស្តុតាងផ្ទុយមកបញ្ជាក់។

**កថាភាគទី១: ភស្តុតាងតាមការធ្វើកោសលវិច័យ**

កោសលវិច័យ គឺជាការពិនិត្យភស្តុតាងដែលតុលាការបានកំណត់ឱ្យមានអ្នកជំនាញខាងផ្នែកកោលសវិច័យ មានន័យថាដែលមានចំណេះវិជ្ជា និងបទពិសោធន៍ពិសេសឱ្យធ្វើរបាយការណ៍អំពីវិធានតាមបទពិសោធន៍ដែលខ្លួនមាន។

ម្យ៉ាងទៀតការធ្វើកោសលវិច័យនេះដែរ គឺត្រូវគោរពតាមគោលការណ៍ស្នើសុំរបស់គូភាគី ហើយតុលាការអាចធ្វើការបង្គាប់ឱ្យធ្វើកោសល្យវិច័យបានទៅតាមការស្នើសុំរបស់

[44] មាត្រា២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជា

ភាគីវិវាទនោះ[45]។ ភាគីដែលបានធ្វើការស្នើសុំ ត្រូវភ្ជាប់ឯកសារដែលអាចកំណត់អំពីអ្វីដែលខ្លួនគិតថាជាភស្តុតាងថ្មីដែលនាំឱ្យមានភាពច្បាស់លាស់ ក្នុងការវិនិច្ឆ័យរកយុត្តិធម៌សម្រាប់ខ្លួន។ ក្នុងករណីមានមូលហេតុដែលពុំអាចធ្វើការចៀសវាងបាន ឯកសារទាំងអស់អាចដាក់ក្នុងអំឡុងពេលដែលតុលាការបានកំណត់ ក្នុងករណីនេះតុលាការត្រូវសួរយោបល់របស់គូភាគីម្ខាងទៀត អំពីការស្នើសុំឱ្យធ្វើកោសលវិច័យ ហើយតុលាការត្រូវកំណត់ចំណុចដែលត្រូវធ្វើកោសលវិច័យដោយយោងលើឯកសារដែលបានដាក់ឱ្យ និងយកធ្វើការពិចារណា។

ម្យ៉ាងទៀតតុលាការ ត្រូវផ្ញើឯកសារស្តីពីចំណុចដែលត្រូវធ្វើកោសលវិច័យនោះទៅឱ្យអ្នកជំនាញខាងធ្វើកោសលវិច័យដែលត្រូវចាត់តាំងដោយតុលាការ នៅក្នុងន័យនេះចង់បញ្ជាក់ថា តុលាការប្រើឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងករណីចៅក្រមបានយល់ឃើញថាមានការចាំបាច់ហើយមានមូលហេតុត្រឹមត្រូវ។ នៅក្នុងករណីនេះប្រសិនបើការធ្វើកោលវិច័យនោះមានសាច់ញាតិខ្លួនពាក់ព័ន្ធនោះ ក្នុងករណីនេះអ្នកដែលត្រូវធ្វើកោលសវិច័យមិនត្រូវបានអនុញ្ញាត្តទេ ព្រោះថាអាចនាំឱ្យមានការបាត់បង់តម្រុយនៃវត្ថុតាងដែលមានការពាក់ព័ន្ធនៅក្នុងវិវាទដែលកំពុងកើតឡើង។

ការធ្វើកោសលវិច័យ គឺជាវត្ថុតាងដែលមានជាប់ពាក់ព័ន្ធទៅនឹងអង្គហេតុ ហើយអ្នកដែលអាចធ្វើកោលសវិច័យបាន គឺជាបុគ្គលដែលមានជំនាញច្បាស់លាស់ និងវិជ្ជាជីវៈត្រឹមត្រូវ។ អ្នកដែលធ្វើកោលវិច័យ អាចបញ្ចេញយោលបល់ដោយផ្ទាល់មាត់ ឬក៏ជាលាយលក្ខ-អក្សរទៅកាន់តុលាការបាននៅក្នុងករណីចាំបាច់ ដោយសារអ្នកដែលធ្វើកោលសវិច័យ ត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងសវនាការតាមការស្នើសុំរបស់ភាគីវិវាទដែរ។

ឧទាហរណ៍៖ ក្នុងករណីមានវិវាទរឿងដីធ្លី ភាគីសងខាងមានឯកសារដែលអាចបញ្ជាក់ថាខ្លួនជាម្ចាស់កម្មសិទ្ធិនៅលើដីនោះរៀងៗខ្លួន ប៉ុន្តែក្នុងចំណោមប័ណ្ណកម្មនោះមានប័ណ្ណមួយគឺជាប័ណ្ណក្លែងក្លាយ ដោយសារមានលក្ខណៈដូចគ្នាពេកដែលមិនអាចធ្វើការបែងចែកបានថាតើមួយណាពិត ហើយនឹងមួយណាមិនពិត ដូច្នេះហើយដោយមានការស្នើសុំពីភាគីឱ្យតុលាការបញ្ជូនអ្នកមានជំនាញ ហើយនឹងមានបទពិសោធន៍ឱ្យមកធ្វើកោលសវិច័យលើឯកសារដែលជាប័ណ្ណកម្មសិទ្ធិដីនោះ ដើម្បីបញ្ជាក់ពីភាពពិតប្រាកដរបស់ឯកសារ និងជាផលប្រយោជន៍របស់សុច្ចរិត។ ដូច្នេះចំណុចសំខាន់របស់ឯកសារមាន៖ ហត្ថលេខា ការ

[45] មាត្រា១៩៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីខ្មែរ២០០៦

បោះត្រា និងការចុះលេខក្នុងបញ្ជីដែលជាចំណុចត្រូវយកមកធ្វើកោលសវិច័យពីភាពខុសគ្នាទៅលើចំណុចនីមួយៗ ដូច្នេះការបំភ្លឺរបស់អ្នកជំនាញ គឺជាការផ្តល់ព័ត៌មានទាំងឡាយទៅលើចំណុចនីមួយៗដែលជាគន្លឹះសំខាន់ និងការបញ្ជាក់ពីភាពពិតប្រាកដរបស់ឯកសាររួមទាំងការធ្វើសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញ ដើម្បីធ្វើការចង្អុលបង្ហាញពីភាពជាក់លាក់មួយឱ្យទៅតុលាការក្នុងការធ្វើសេចក្តីសម្រេចមួយដោយយុត្តិធម៌។ ប៉ុន្តែតុលាការក៏ត្រូវមានយល់ដឹងពីការចង្អុលបង្ហាញចំពោះការបំភ្លឺរបស់អ្នកជំនាញ និងអត្ថន័យនៃសេចក្តីសន្និដ្ឋានមិនតែប៉ុណ្ណោះតុលាការត្រូវយល់ដឹងពីសញ្ញាណគ្រឹះសំខាន់ៗ ហើយនឹងការវាយតម្លៃមួយរបស់អ្នកជំនាញគ្រប់សេចក្តីសន្និដ្ឋានទាំងអស់។ ភារៈដែលបានកើតឡើង គឺថាវាគ្មានភាពច្បាស់លាស់ជាងប្រភេទនៃភស្តុតាងបាននោះទេ ម្យ៉ាងសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញក៏ស្ថិតក្នុងាការផ្ទាងផ្ទាត់ និងវាយតម្លៃជាចាំបាច់ដូចនឹងវិធានដ៏ទៃទៀតដែរ។ ដោយសារតែមូលហេតុដូច្នេះហើយ ទើបបានជាតុលាការមានសិទ្ធិតាមដានរាល់ដំណើរការធ្វើកោសលវិច័យតាមរយៈរបាយការណ៍របស់អ្នកជំនាញ[46]។

ការធ្វើកោសលវិច័យនោះ អាចបណ្តាលឱ្យអ្នកជំនាញផ្ទាល់ខ្លួន ឬសហព័ទ្ធ ឬញាតិឯទៀតរបស់ខ្លួនអាចទទួលរងនូវការចោទប្រកាន់អំពីបទអាជ្ញាបាន និងត្រូវទទួលការផ្តន្ទាទោសផង[47]។ នៅក្នុងចំណុចនេះចង់បញ្ជាក់ថា ជនទាំងឡាយដែលជាអ្នកជំនាញនោះ មិនត្រូវបានអនុញ្ញាតទេ ក្នុងករណីរឿងវិវាទដែលមានការពាក់ព័ន្ធជាមួយសហព័ទ្ធ ឬក៏ក្រុមសាច់សាលោហិតរបស់ខ្លួន ច្បាប់មិនអនុញ្ញាតឱ្យអ្នកជំនាញនោះធ្វើកោលសវិច័យសបានទេ។ ដោយសារកត្តាទាំងនេះទាំងហើយ ទើបមានការចាត់អ្នកជំនាញខាងធ្វើកោសលវិច័-យតាមរយៈការកំណត់របស់តុលាការ ពីព្រោះកាលណាអ្នកជំនាញមានសាច់ញាតិ ឬសហព័ទ្ធមានជាប់ទាក់ទងនឹងវិវាទនាំឱ្យការធ្វើកោសលវិច័យបាត់បង់សច្ចភាពនៃភស្តុតាង។

ក្នុងករណីនេះ ប្រសិនបើភាគីបានដឹងពីហេតុដែលនាំមានការបាត់បង់សច្ចភាពនៃភស្តុតាង ភាគីអាចប្តឹងផាត់ចោលការធ្វើកោសលវិច័យនេះបាន បើទោះបីជាអ្នកជំនាញនោះបានធ្វើសេចក្តីសន្និដ្ឋានហើយក៏ដោយ[48]។ ក្នុងន័យនេះដែរ ចង់បញ្ជាក់ថាទោះជាការជ្រើសតាំងដោយតុលាការក៏ដោយ ប្រសិនបើភាគីយល់ឃើញថាការធ្វើកោសលវិច័យនោះ

[46] នីតិភស្តុតាង រៀបរៀងដោយ លោកសាស្ត្រាចារ្យ អ៊ិន បូផា ឆ្នាំ២០១៦ បោះពុម្ពលើកទី២ ទំព័រ៣៣២

[47] មាត្រា១៩៤ កថាខណ្ឌទី៣ ក្រមនីតិវិធីរដ្ឋប្បវេណីខ្មែរ ឆ្នាំ២០០៦

[48] មាត្រា១៩៥ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណីខ្មែរ ឆ្នាំ២០០៦

មានការរារាំងពីសច្ចភាពនៃភស្តុតាង គឺភាគីអាចប្តឹងផាត់ចោលបានបើមានមូលហេតុដែលអាចបញ្ជាក់ថាអ្នកដែលបានធ្វើកោសលវិច័យនេះ មានជាប់ពាក់ព័ន្ធទៅនឹងភាគីម្ខាងទៀត នាំឱ្យការធ្វើកោសលវិច័យនេះមិនតម្លាភាព ហើយនឹងអាចបាត់តម្រុយនៃភស្តុតាង។

## កថាភាគទី២: ការបញ្ជាក់ភស្តុតាងសច្ចធារណ៍

សច្ចធារណ៍នៃភស្តុតាង គឺជាភស្តុតាងដែលត្រូវបានសន្មតដោយច្បាប់ ក៏ប៉ុន្តែមិនមានន័យថាភស្តុតាងទាំងនោះ វាមានអនុភាពក្នុងការបំបាត់ចោលរាល់ភស្តុតាងដែលបានបង្ហាញនៅចំពោះមុខតុលាការ ឬនៅពេលដែលមានភស្តុតាងថ្មីមកបញ្ជាក់នោះទេ។

សច្ចធារណ៍នៃភស្តុតាង គឺជាភស្តុតាងមួយដែលអាចយកមកអះអាងនៅចំពោះមុខតុលាការពីសិទ្ធិស្របច្បាប់របស់ខ្លួនក្នុងរឿងវិវាទបាន។ ល្គឹកណាដែលមានសច្ចធារណ៍នៃភស្តុតាងហើយ ដូច្នេះរាល់ភស្តុតាងបន្ទាប់បន្សំ ឬរបាយការណ៍របស់សាក្សីដែលនៅពុំមានការបង្ហាញឱ្យច្បាស់លាស់ទៅលើអង្គហេតុ មានន័យថាភស្តុតាងដែលភាគីម្ខាងបានបង្ហាញគឺមិនទាន់គ្រប់គ្រាន់ទេ។

ដូច្នេះភស្តុតាងនោះមិនមានអានុភាពនៅចំពោះមុខតុលាការបានទេ ក្នុងករណីដែលមានភាគីម្ខាងទៀតជាភាគីមានប្រយោជន៍ទៅលើសច្ចធារណ៍នៃភស្តុតាង ភាគីនោះត្រូវតែលើកយកភស្តុតាងដែលមានមកបញ្ជាក់នៅចំពោះមុខតុលាការ។

ភស្តុតាងសច្ចធារណ៍ មិនអាចមានអនុភាពលើភស្តុតាងទាំងអស់នោះទេ ប្រសិនបើមានភស្តុតាងផ្ទុយដែលអាចយកបញ្ជាក់បានច្បាស់ពីព្រឹត្តិហេតុបានច្បាស់លាស់ ហើយនឹងមានហេតុផលពេញលេញដែលហួសពីការសង្ស័យ ភស្តុតាងផ្ទុយនឹងនាំឱ្យបាត់អនុភាពនៃសច្ចធារណ៍នៃភស្តុតាងបាន។ ពេលនោះតុលាការនឹងធ្វើសេចក្តីសម្រេចទៅតាមទម្ងន់នៃភស្តុតាងដែលមាននុ៎ះ! ។

ឧទាហរណ៍៖ លោក វិជ្ជា និងលោកស្រី ដា គឺជាស្វាមី និងភរិយា អ្នកទាំងពីរបានរស់នៅផ្តាច់នីតិសង្វាសបណ្តោះអាសន្ន ក្នុងអំឡុងពេលនោះដែលលោកស្រីដា គាត់មានផ្ទៃពោះហើយបានបង្កើតកូនប្រុសម្នាក់។ ឥឡូវវិវាទបានកើតឡើងចំពោះអ្នកពីរ ក្នុងបណ្តឹងទាមទារឱ្យទទួលស្គាល់បិតុភាព ឬក៏បុត្រភាព។

កូនដែលបានកើតក្នុងអំឡុងពេលផ្អាកនីតិសង្វាសរវាងអ្នកទាំងពីរ ត្រូវបានសន្មតថាគឺជាកូនរបស់លោកវិជ្ជា ហើយគាត់អាចរកភស្តុតាងផ្ទុយមកជំនួសសច្ចធារណ៍នៃភស្តុតាងនេះក្នុងករណីដែលគាត់មិនព្រមទទួលកូននោះ។

តើការសន្និដ្ឋានរបស់ចៅក្រម គឺជាសច្ចធារណ៍នៃភស្តុតាងដែរឬទេ? យោងតាមប្រព័ន្ធច្បាប់COMMON LAW បាននិយាយអំពីយុត្តិសាស្ត្រតុលាការ គឺជាសេចក្តីសម្រេចដែលយកជាផ្លូវការណ៍បានដ៏រាបណាពុំទាន់មានច្បាប់ចែង ហើយយុត្តិសាស្ត្រនោះគេចាត់ទុកជាច្បាប់ដើម្បីយកមកអនុវត្តន៍បន្តបន្ទាប់ទៀត ក្នុងករណីដែលមានព្រឹត្តិហេតុដូចគ្នាបានកើតឡើងនៅពេលក្រោយៗទៀត។

ដូច្នេះយុត្តិសាស្ត្ររបស់តុលាការមិនមែនជាសច្ចធារន៍នៃភស្តុតាងនោះទេ ប៉ុន្តែវាគឺការសន្និដ្ឋានរបស់ចៅក្រមដោយហេតុសមរម្យមួយដែលច្បាប់ពុំទានមានច្បាប់ចែង ដើម្បីការពារប្រយោជន៍របស់បុគ្គលសុច្ចរិត រាល់ការសន្និដ្ឋានរបស់ចៅក្រមគឺមិនត្រូវឱ្យមានការខូចខាតប្រយោជន៍បុគ្គល ឬក៏មានការប៉ះពាល់ទៅដល់សណ្តាប់ធ្នាប់ និងសន្តិសុខ ក៏ដូចជាទំនៀមទំលាប់ល្អក្នុងសង្គមឡើយ ពីព្រោះគោលការណ៍ច្បាប់គឺជាការការពារសណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងសង្គម រីឯគោលបំណងរបស់ច្បាប់ គឺជាការបង្ការ ការការពារ និងការកែប្រែបុគ្គលម្នាក់ឱ្យក្លាយមកជាពលរដ្ឋល្អក្នុងសង្គមវិញ។ ក្នុងករណីនេះមានមតិមួយចំនួនបានចាត់ទុកថាយុត្តិសាស្ត្ររបស់តុលាការ គឺជាសច្ចធារណ៍នៃភស្តុតាង ហើយសច្ចធារណ៍គឺជាការសន្និដ្ឋានរបស់ចៅក្រមដែលចៅក្រមបានបង្កើតឡើងមកដោយខ្លួនឯង។

តើហេតុអ្វីបានជាត្រូវការសច្ចធារណ៍ភស្តុតាង?

សច្ចធារណ៍នៃភស្តុតាង គឺជាការសន្មតរបស់ច្បាប់ដែលបានបញ្ញត្តមុន ដើម្បីការពារផលប្រយោជន៍ស្របច្បាប់ទៅលើបុគ្គលណាម្នាក់ ដែលអាចត្រូវទទួលបានផលប្រយោជន៍ពីសច្ចធារណ៍នៃភស្តុតាងនោះ។

ច្បាប់ដែលបានបញ្ញត្តឡើង គឺមានចក្ខុវិស័យវែងក្នុងការកំណត់ទុកមុនអំពីព្រឹត្តិហេតុណាមួយដែលមិនទាន់កើតឡើង ឬរៀបនឹងកើតឡើង ដើម្បីការពារផលប្រយោជន៍បុគ្គលដែលបាត់សិទ្ធិរបស់ខ្លួនក្នុងករណីមានវិវាទរវាងសហាព័ទ្ធ ក៏ដូចជាការពាក់ព័ន្ធទៅនឹងទ្រព្យជាដើម។

ឧទាហរណ៍៖ ក្នុងករណីដែលទារកនៅក្នុងផ្ទៃដែលមានអាយុ៥ខែ ប៉ុន្តែគាត់ទទួលរងនូវព្យសនកម្ម ឬក៏គាត់នឹងក្លាយទៅជាមតកជននៅថ្ងៃអនាគត នៅក្នុងចំណុចនេះគាត់អាច

ធ្វើការទាមទារតាមច្បាប់បាន ពីព្រោះសិទ្ធិរបស់គាត់ត្រូវបានកំណត់ទុកជាមុនរួចស្រាចទៅហើយ នេះបើយោងតាម(មាត្រា៩នៃក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ២០០៧)។

ការបញ្ញត្តអំពីសច្ចធារណ៍នៃភស្តុតាង គឺវាអាចនាំឱ្យមានភាពងាយស្រួលនៅក្នុងនីតិវិធីបណ្តឹងសម្រាប់បុគ្គលដែលទទួលបានប្រយោជន៍ពីសច្ចធារណ៍នៃភស្តុតាងនេះ។

ឧទាហរណ៍៖ ក្នុងករណីច្បាប់បានកំណត់សិទ្ធិរួច នេះបើយោងតាមមាត្រា៩នៃក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ២០០៧ និងក្នុងក្រមរដ្ឋប្បវេណីបារាំងឆ្នាំ១៩៩៣ក្នុងកថាខណ្ឌទី១ យ៉ាងហោចណាស់ នាំឱ្យភាគីម្ខាងនៃបណ្តឹងមិនអាចមានលេសក្នុងការដោះសាមិនទទួលស្គាល់បាន ប៉ុន្តែភាគីនោះអាចស្វែងរកភស្តុតាងផ្ទុយមកបញ្ជាក់ ហើយភស្តុតាងនោះត្រូវហួសពីការសង្ស័យទើបអាចមានអានុភាព ឬបំបាត់ចោលនូវសច្ចធារណ៍នៃភស្តុតាងបាន។

## កថាភាគទី៣: ភស្តុតាងតាមសេចក្តីសន្និដ្ឋានរបស់ចៅក្រម

នៅក្នុងនីតិវិធីរដ្ឋប្បវេណីសម្ភារៈសច្ចភាពនៃភស្តុតាង គឺជាការសន្និដ្ឋានដ៏ច្បាស់មួយរបស់ចៅក្រមទៅលើភស្តុតាងទាំងឡាយ ក្រោយពីបានសិក្សាទៅលើភស្តុតាងរួមទាំសេចក្តីសម្រេចយ៉ាងចំៗ និងភាពច្បាស់លាស់បំផុតលើអង្គហេតុនោះ ហេតុដូច្នេះនៅក្នុងដំណាក់កាលនៃដំណើការសក្ខីកម្ម គឺតម្រូវឱ្យចៅក្រមមានចំណេះដឹងស៊ីជម្រៅលើវិស័យច្បាប់នឹងមានភាពលម្អិតក្នុងការពិនិត្យភស្តុតាងរួមនាំឱ្យភស្តុតាងនោះមានភាពរឹងមាំបំផុត ពីព្រោះថាភស្តុតាងខ្លះវាអាចនាំឱ្យការសម្រេចរបស់ចៅក្រមមានភាពភានច្រឡំ ការដែលសម្រេចដោយការភាន់ច្រឡំ នាំឱ្យប្រជាពលរដ្ឋបាត់ការទុកចិត្តនឹងទទួលបានការរិះគន់ពីសំណាក់ពលរដ្ឋ ដើម្បីស្វែងរកការសម្រេចមួយឱ្យមានភាពយុត្តិធម៌ ចៅក្រមត្រូវធ្វើការផ្ទៀងផ្ទាត់ភ-ស្តុតាង ហើយនឹងស្វែងរកភាពត្រឹមត្រូវរបស់ភស្តុតាងដែលអាចឈានរកការសម្រេចមួយដ៏ត្រឹមត្រូវពិតប្រាកដ។

សច្ចភាពជាសម្ភារៈ គឺជាគោលដៅពិតប្រាកដមួយ ហើយនឹងច្បាស់លាស់នៅក្នុងនីតិវិធីរដ្ឋប្បវេណីដែលសំដៅលើការសិក្សាពីភស្តុតាងទាំងឡាយ ដែលតុលាការត្រូវកំណត់ឱ្យបានច្បាស់ពីភាពស៊ីសង្វាក់គ្នាជាមួយអង្គហេតុនីមួយៗ។

ចំពោះចៅក្រមជានិច្ចជាកាល មិនមែនជាអ្នកអង្កេតការណ៍ ឬក៏តាមឃ្លាំមើលទៅលើអង្គហេតុនោះទេ ក៏ប៉ុន្តែចៅក្រមជាអ្នកកំណត់ និងសម្រេចលើភាពខុស និងត្រូវ គឺត្រូវបាន

ផ្អែកលើភស្តុតាងទាំងនោះ ហើយនឹងជាភស្តុតាងដែលមានភាពស៊ីចង្វាក់គ្នាជាមួយនឹងអង្គហេតុ និងអាចនាំឱ្យថៅក្រមធ្វើការសម្រេចសេចក្តីដោយយុត្តិធម៌បាន។

ហេតុដូច្នេះហើយនៅក្នុងនីតិវិធីរដ្ឋប្បវេណី ចំពោះសច្ចភាពនៃភស្តុតាងវាបានដើរតួ-រយ៉ាងសំខាន់បំផុតនៅក្នុងចំណោមភស្តុតាងនានា។ ដោយសារតែមានគោលការណ៍នេះ វាបានប្រកាន់ខ្ជាប់នូវខ្លឹមសារ ឬខណៈនានានៃអង្គហេតុ និងសម្ភារៈនានាដែលមានការពាក់ព័ន្ធហើយនឹងជាពន្លឺក្នុងការសម្រេចសេចក្តីមួយឱ្យច្បាស់លាស់។ ម្យ៉ាងវិញទៀតសេចក្តីសន្និដ្ឋាននេះបានសម្រេចយ៉ាងចំៗហើយច្បាស់លាស់បំផុតអំពីសកម្មភាពនានា ហើយនិងអំពើណាមួយតាមរយៈអង្គហេតុទាំងនោះ។

## សេចក្តីសន្និដ្ឋាន

យោងតាមការបកស្រាយខាងលើ គឺឆ្លុះបញ្ចាំងឱ្យឃើញអំពីភាពច្បាស់លាស់នៃនីតិវិធីនៅក្នុងការសម្រេចសេចក្តីរបស់ចៅក្រមដោយផ្អែកទៅលើភស្តុតាង ហើយការសម្រេចសេចក្តីនោះមានភាពច្បាស់លាស់។

យើងដែលជាអ្នកសិក្សានៅក្នុងវិស័យច្បាប់ ត្រូវតែយល់ពីការបែងចែកភស្តុតាងជាចំណាត់ថ្នាក់នីមួយៗ ការយល់ដឹងច្បាស់លាស់ គឺធ្វើឱ្យយើងអាចយល់ពីភាពលម្អិតក្នុងកា-រវិនិច្ឆ័យរបស់ចៅក្រម។

ចៅក្រម គឺជាកញ្ចក់ឆ្លុះបញ្ចាំងមួយដែលឈរលើគោលការណ៍យុត្តិធម៌ ហើយការសម្រេចសេចក្តីរបស់ចៅក្រមគឺផ្អែកទៅសមត្ថភាពច្បាប់ច្បាស់លាស់ និងការគោរពនៅវិជ្ជាជីវៈរបស់ខ្លួនដែលមាន ហើយការវិនិច្ឆ័យរបស់ចៅក្រមវិញ គឺត្រូវពឹងផ្អែកទៅលើភស្តុតាងនិងយល់ឱ្យច្បាស់ពីភស្តុតាង។

ការយល់ដឹងស៊ីជម្រៅពីភស្តុតាងរបស់ចៅក្រម និងការប៉ិនប្រសព្វរបស់ចៅក្រមលើការបែងចែក ក៏ដូចជាការញែកឱ្យបានច្បាស់ រួមទាំងការចាត់ចំណាក់ថ្នាក់នៃភស្តុតាង វានាំឱ្យការវិនិច្ឆ័យនោះទទួលបាននៅភាពយុត្តិធម៌។

យុត្តិធម៌នេះហើយ វាជាការចង់បានរបស់ភាគីដែលត្រូវបានគេរំលោភទៅសិទ្ធិរបស់ខ្លួន តាមរយៈឧបាយនានារបស់ចៅក្រម។ ការផ្តល់យុត្តិធម៌តាមរយៈទាមទារនេះដែរ គឺត្រូវធ្វើនៅចំពោះមុខតុលាការ ហើយមានតែប្រព័ន្ធតុលាការទេដែលមានសមត្ថកិច្ចនៅក្នុងការសម្រេចពីភាពយុត្តិធម៌ជូនដល់ជនរងគ្រោះបាន។

# ឯកសារយោង


1. រដ្ឋធម្មនុញ្ញខ្មែរឆ្នាំ១៩៩៣
2. ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
3. ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
4. វចនានុក្រម សម្ដេចព្រះសង្ឃរាជ ជោតញ្ញាណោ ជួន ណាត ថ្ងៃ១០ ខែធ្នូ ឆ្នាំ១៩៦៧(ព.ស២៥១១)
5. នីតិភស្តុតាង របស់អនុបណ្ឌិតនីតិសាស្ត្រ អ៊ុន បូផា ឆ្នាំ២០១៦
6. ជីវិតចុងរបស់សូក្រាត រៀបរៀងដោយលោក សុខសូផាត ឆ្នាំ២០១០
7. Law of evidence prepare by Kahasay Debesu and Andualem Eshetu ឆ្នាំ២០០៩
8. មេរៀននីតិសិទ្ធិមនុស្ស របស់សាស្ត្រាចារ្យឆឹង ស៊ីនៀង
9. មេរៀនប្រវត្តិគំនិតនយោបាយ របស់បណ្ឌិត អ៊ុន សកក្កដា ឆ្នាំ២០១៥
10. សទ្ទានុក្រមច្បាប់ខ្មែរ និងអង់គ្លេស អ្នករៀបរៀងដោយ វ៉ាន់ ច័ន្ទតារា ឆ្នាំ២០១០

**ច្បាប់រដ្ឋធម្មនុញ្ញ ជំពូកទី៣ សិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ**

**មាត្រា៣១**

ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឲ្យប៉ះពាល់ដល់សិទ្ធិ សេរីភាពអ្នកដទៃឡើយ។ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំណត់ក្នុងច្បាប់។

**មាត្រា៣២**

ជនគ្រប់រូប មានសិទ្ធិរស់រានមានជីវិត មានសេរីភាពនិងមានសន្តិសុខផ្ទាល់ខ្លួន។

ទោសប្រហារជីវិតមិនត្រូវឲ្យមានឡើយ។

**មាត្រា៣៨**

ច្បាប់ហាមឃាត់មិនឲ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។

ច្បាប់ការពារជីវិត កិត្តិយស និង សេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើតលុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឲ្យធ្វើឡើយ។ អ្នកដៃដល់ អ្នករួមប្រព្រឹត្តិ និងអ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់។

ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ។

វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។

**ក្រមនីតិវិធីរដ្ឋប្បវេណី**

**មាត្រា៤ ការទទួលខុសត្រូវរបស់តុលាការ និង ភាគី**

តុលាការត្រូវប្រឹងប្រែង ដើម្បីរ៉ាប់រងបណ្តឹងរដ្ឋប្បវេណីឲ្យប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌និងឆាប់រហ័ស ឯភាគីត្រូវអនុវត្តបណ្តឹងរដ្ឋប្បវេណីដោយសុចរិតនិងស្មោះត្រង់។

**មាត្រា១០១ ឯកសារត្រៀម**

១. នៅពេលធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចបង្គាប់ឲ្យភាគីដាក់ឯកសារត្រៀមបាន។

២. នៅក្នុងឯកសារត្រៀម ត្រូវមានសរសេរអំពីមធ្យោបាយតទល់ ឬការពារខ្លួន និងសេចក្តីថ្លែងការណ៍ ចំពោះមធ្យោយតទល់ ឬការពារខ្លួនរបស់ភាគីម្ខាងឡើយ។

៣.នៅក្នុងឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការលើកដំបូង ត្រូវមានសរសេរអំពីការឆ្លើយតប ចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរទាមទារនៅក្នុងពាក្យបណ្តឹង និងការទទួលស្គាល់ ឬមិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង និង អង្គហេតុដើម្បីតវ៉ាចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹងជាអាទិ៍។

**មាត្រា១០៣ គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុហេតុផល តុលាការត្រូវរៀបចំនូវសេចក្តីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលគូភាគីយល់មិនស្របគ្នា និង រៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តីនោះដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឲ្យបានល្អិតល្អន់។

**មាត្រា១១៣ ការកំណត់កាលបរិច្ឆេទដើម្បីធ្វើការទាញហេតុដោយផ្ទាល់មាត់**

នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានចប់សព្វគ្រប់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទ ដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅគូភាគីមកចូលរួម។

**មាត្រា ១១៤ ភាពចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់**

១. ដើម្បីចេញសាលក្រមទៅលើបណ្តឹង តុលាការចាំបាច់ត្រូវតែឆ្លងកាត់នូវការទាញហេតុផលផ្ទាល់។ ប៉ុន្តែ ចំពោះរឿងក្តី ឬ ចំណុចណាដែលត្រូវសម្រេចដោយដីកាសម្រេច តុលាការត្រូវកំណត់ថា ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬមិនត្រូវធ្វើ។

២. ក្នុងករណីដែលមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដោយអនុលោមទៅតាមវាក្យខណ្ឌទី២ នៃកថាខណ្ឌទី១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់។

**មាត្រា ១១៥ ការទាញហេតុផលដោយផ្ទាល់មាត់**

១. ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីសងខាងអាចមានវត្តមានបាន។

២. ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវធ្វើឡើងនៅសាលសវនការជាសាធារណៈ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាពជាសាធារ

ណៈនេះ បណ្ដាលឲ្យខូចសណ្ដាប់ធ្នាប់សារណៈ ឬ ករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់។

**មាត្រា ១២៣ គោលលការណ៍សម្រេចសេចក្ដីដោយភស្ដុតាង**

១. តុលាការត្រូវទទួលស្គាល់អង្គហេតុដោយផ្អែកលើភស្ដុតាងជាមូលដ្ឋាន។ ប៉ុន្តែតុលាការអាចពិចារណាអំពីស្ថានភាពទាំងមូល ដែលបានលេចឡើងនៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់បាន។

២. អង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការ និង អង្គហេតុដែលតុលាការយល់ឃើញថា មានភាពជាក់ស្ដែង តុលាការពុំចាំបាច់ទទួលស្គាល់អង្គហេតុនោះដោយផ្អែកលើភស្ដុតាងទេ។

៣.ភាគីអាចដកសេចក្ដីសារភាពបាន ក្នុងករណីដូចខាងក្រោមនេះ ៖

ក. ភាគីម្ខាងទៀតពុំតវ៉ា។

ខ.ការសារភាពនោះ ផ្ទុយនឹងការពិត ដោយភាន់ច្រឡំ។

គ. ការសារភាពនេះបណ្ដាលមកពីសកម្មភាពបទល្មើសរបស់អ្នកដទៃ។

**មាត្រា ១២៥ ការស្នើសុំឲ្យពិនិត្យភស្ដុតាង**

១. ភាគីដែលស្នើសុំឲ្យពិនិត្យភស្ដុតាង ត្រូវតែកំណត់ឲ្យបានជាក់លាក់អំពីអង្គហេតុដែលត្រូវបញ្ជាក់។

២. ភាគីដែលស្នើសុំឲ្យពិនិត្យភស្ដុតាង គប្បីបំភ្លឺឲ្យច្បាស់លាស់អំពីអង្គហេតុដែលត្រូវបញ្ជាក់ និង ទំនាក់ទំនងរវាងអង្គហេតុនោះនិងភស្ដុតាង។

៣. ការស្នើសុំឲ្យពិនិត្យភស្ដុតាង ក៏អាចធ្វើមុនកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ មុនកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់បានដែរ។

៤. ការស្នើសុំឲ្យសាកសួរសាក្សី និង សាមីភាគី បើអាចធ្វើបាន ត្រូវធ្វើជាមួយគ្នាឲ្យស្រេចតែម្ដង។

**មាត្រា១២៦ ការទទួលយកភស្តុតាង**

តុលាការត្រូវពិនិត្យភស្តុតាងដែលភាគីបានស្នើសុំឲ្យពិនិត្យ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកអនុវត្តចំពោះភស្តុតាងដែលគ្មានទំនាក់ទំនងជាមួយនឹងអង្គហេតុដែលនឹងត្រូវបញ្ជាក់ និងភស្តុតាងឯទៀតដែលតុលាការយល់ឃើញថាមិនចាំបាច់ឡើយ។

**មាត្រា១២៧ ការពិនិត្យភស្តុតាងដោយសមូហវិធី**

១. តុលាការត្រូវធ្វើឲ្យការពិនិត្យភស្តុតាងអាចប្រព្រឹត្តទៅជាបន្ទាន់ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ដំបូង បន្ទាប់ពីបានបញ្ចប់ការរៀបចំចំណុចវិវាទ និងភស្តុតាងរួចហើយ។

២. ការសាកសួរទៅលើសាក្សី ឬ សាមីភាគី បើអាចធ្វើបាន ត្រូវតែធ្វើដោយសមូហវិធី។

៣. ឯកសារដែលបម្រុងនឹងប្រើនៅក្នុងការសាកសួរសាក្សី ជាអាទិ៍ ត្រូវដាក់ជូននៅក្នុងអំឡុងពេលដែលសមរម្យ មុនពេលចាប់ផ្តើមធ្វើការសាកសួរទៅលើសាក្សី ជាអាទិ៍ នោះលើកលែងតែឯកសារដែលនឹងប្រើជាភស្តុតាង ដើម្បីប្រជែងលើភាពជំនឿនៃសេចក្តីថ្លែងការណ៍របស់សាក្សីជាអាទិ៍។

**មាត្រា ១៣១ ការប្រគល់កិច្ចការស្រាវជ្រាវ**

សេចក្តីបញ្ជាក់ដំបូង ត្រូវធ្វើឡើងដោយភស្តុតាងដែលអាចពិនិត្យភ្លាមៗបាន។

**មាត្រា១៣២ ករណីយកិច្ចរបស់សាក្សី**

១. លើកលែងតែក្នុងករណីដែលមានការកំណត់ពិសេសនៅក្នុងក្រមនេះ ឬច្បាប់ផ្សេងតុលាការអាចសាកសួរជនណាមួយជាសាក្សីក៏បាន។

២. តុលាការអាចបង្គាប់ឲ្យនាំខ្លួនសាក្សីដែលមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ ដោយដីការសម្រេចបាន។

៣. ប្រសិនបើសាក្សីមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវអាចពិន័យជាប្រាក់ចំនួនមិនលើសពី១.០០០.០០០(មួយលាន)រៀលបាន ដោយដីការសម្រេច។

៤. ចំពោះដីការសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ ឬទី៣ ខាងលើនេះ អាចប្តឹងជំទាស់បាន។

**មាត្រា១៣៦ ការសាកសួរសាក្សីនៅក្រៅតុលាការ**

១. តុលាការអាចសាកសួរសាក្សីនៅក្រៅតុលាការបានក្នុងករណីដូចខាងក្រោមនេះ ៖

ក. សាក្សីគ្មានករណីកិច្ចចូលខ្លួនទៅតុលាការដែលទទួលបណ្តឹង ឬ មានមូលហេតុត្រឹមត្រូវដែលមិនអាចចូលខ្លួនទៅតុលាការបាន។

ខ. ការចូលខ្លួនរបស់សាក្សីទៅតុលាការដែលទទួលបណ្តឹង បណ្តាលឲ្យមានការចំណាយទៅលើពេលវេលា ឬ សោហ៊ុយមិនសមរម្យ។

គ. គូភាគីពុំមានការតវ៉ា។

២. ចំពោះបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះតុលាការអាចឲ្យចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ ទៅធ្វើការសាកសួរសាក្សីនៅក្រៅតុលាការបាន។

៣. ក្នុងករណីចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ ធ្វើការសាកសួរសាក្សី ចៅក្រមនោះត្រូវបំពេញមុខនាទីរបស់តុលាការ ឬ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

**មាត្រា១៣៧ សម្បថ**

១. តុលាការត្រូវឲ្យសាក្សីធ្វើសម្បថលើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេស។

២. ក្នុងករណីសាក្សីដែលនឹងត្រូវ ជាជនដែលមានអាយុក្រោម១៦(ដប់ប្រាំមួយ)ឆ្នាំ ឬជនដែលមិនយល់អំពីអត្ថន័យនៃសម្បថ តុលាការមិនអាចឲ្យសាក្សីនោះធ្វើសំបុត្របានឡើយ។

៣. នៅពេលសាកសួរសាក្សីដែលត្រូវនឹងល័ក្ខខ័ណ្ឌដែលបាកំណត់នៅក្នុងបញ្ញត្តិនៃមាត្រា១៣៤ (សិទ្ធិបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សី តុលាការអាចមិនឲ្យធ្វើសម្បថបាន។

៤. សម្បថរបស់សាក្សីត្រូវធ្វើនៅមុនពេលសាកសួរ។ ប៉ុន្តែបើមានមូលហេតុពិសេសអាចធ្វើនៅក្រោយពេលសាកសួរបាន។

៥. ទម្រង់នៃការធ្វើសម្បថ ត្រូវធ្វើតាមការកំណត់ក្នុងឧបសម្ព័ន្ធនៃក្រមនេះ។

៦ មុនពេលធ្វើសម្បថ ប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវពន្យល់អំពីគោលបំណងនៃសម្បថ ហើយប្រាប់ឲ្យដឹងជាមុនអំពីការផ្តន្ទាទោសចំពោះការផ្តល់សក្ខីភាពក្លែងក្លាយ។

**មាត្រា១៣៨ វិធីសាកសួរសាក្សី**

១. ការស្នើសុំសាក្សីសួរសាក្សី ត្រូវធ្វើឡើងដោយកំណត់ឲ្យបានច្បាស់លាស់ទៅសាក្សីណាមួយ។

២. អ្នកដែលស្នើសុំសាកសួរសាក្សី ត្រូវភ្ជាប់ជាមួយនូវឯកសារដែលកំណត់អំពីចំណុចត្រូវសាកសួរ។

៣.សាក្សីត្រូវទទួលការកោះហៅយ៉ាងតិច២(ពីរ )សប្តាហ៍មុនថ្ងៃសាកសួរ។

៤. ដីកាកោះហៅសាក្សីត្រូវសរសេរនូវកំណត់សំគាល់ដូចខាងក្រោម ហើយភ្ជាប់មកជាមួយនូវឯកសារដែលកំណត់អំពីចំណុចសាកសួរៈ

ក. ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី។

ខ. ពេលវេលា និងទីកន្លែងដែលត្រូវចូលខ្លួន។

គ. ទណ្ឌកម្មដែលកំណត់ដោយច្បាប់នឹងកើតមានបើមិនចូលខ្លួន។

៥. ការសាកសួរសាក្សីត្រូវធ្វើតាមលំដាប់: ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ភាគីដែលស្នើសុំឲ្យសាកសួរសាកនោះ និងភាគីម្ខាងទៀត។ ចៅក្រមប្រឹក្សាអាចសាកសួរទៅសាក្សីបាននៅក្រោយពេលបានជម្រាបទៅប្រធានក្រុមប្រឹក្សាជំនុំជម្រះឲ្យបានដឹងហើយ។

៦.ប្រសិនបើយល់ឃើញថាត្រឹមត្រូវ តុលាការអាចកែសម្រួលលំដាប់ដែលត្រូវសាកសួរសាក្សីដែលបានកំណត់នៅក្នុងកថាខណ្ឌទី៥ខាងលើនេះបាន។

៧. សាក្សីមិនអាចឆ្លើយដោយយកឯកសារមកអានធ្វើជាមូលដ្ឋានបានឡើយ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការអនុញ្ញាតពីតុលាការ។

៨. ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការអាចអនុញ្ញាតឲ្យសាក្សីដែលត្រូវបានសាកសួរហើយ ឬសាក្សីដែលបម្រុងនឹងត្រូវសាកសួរឲ្យនៅក្នុងសាលសវនការបាន។

៩. នៅពេលដែលតុលាការទទួលស្គាល់ថា សាក្សីពុំអាចឆ្លើយឲ្យគ្រប់គ្រាន់បាននៅចំពោះមុខអ្នកសង្កេតការណ៍ណាម្នាក់ ដោយសារតែអ្នកនោះជាហេតុនាំឲ្យមានការភ័យព្រួយតុលាការអាចបង្គាប់ឲ្យអ្នកសង្កេតការណ៍នោះចេញក្រៅសាលសវនការ នៅពេលដែលសាក្សីនោះឆ្លើយ។

១០. នៅពេលដែលយល់ឃើញថាចាំបាច់ តុលាការអាចបង្គាប់ឲ្យធ្វើការសាកសួរសាក្សី និង សាក្សីផ្សេងទៀតនៅពេលជាមួយគ្នាបាន។

**មាត្រា ១៣៩ ការកម្រិតទៅលើសំណួរ**

១. ចំពោះសំណួរបើអាចធ្វើបាន ត្រូវធ្វើដាច់ដោយឡែក និងច្បាស់លាស់។

២.លើកលែងតែករណីដែលមានមូលហេតុត្រឹមត្រូវ មិនអាចសាកសួរបានឡើយនូវសំណួរខាងក្រោម៖

ក. សំណួរដែលប្រមាថមើលងាយ ឬ ធ្វើឲ្យច្របូកច្របល់ដល់សាក្សី។

ខ. សំណួរនាំមុខ។

គ. សំណួរច្រំដែល។

ឃ. សំណួរដែលគ្មានទំនាក់ទំនងនឹងចំណុចវិវាទ។

ង. សំណួរដែលទាមទារឲ្យថ្លែងការណ៍យោបល់របស់សាក្សីផ្ទាល់ខ្លួន។

ច. សំណួរដែលទាមទារឲ្យថ្លែងយោបល់អំពីអង្គហេតុដែលសាក្សីពុំបានជួបប្រទះផ្ទាល់។

៣. តុលាការអាចកម្រិតនូវសំណួរ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិបាន នៅពេលដែលយល់ឃើញថា សំណួរនោះផ្ទុយនឹងបញ្ញត្តិដែលមានចែងនៅក្នុងកថាខណ្ឌទី២ខាងលើនេះ។

៤. ភាគីអាចតតាំ ចំពោះការកម្រិតដែលធ្វើទៅតាមបញ្ញត្តិនៃកថាខណ្ឌទី៣ខាងលើនេះបាន។

**មាត្រា១៤៣ ការស្នើសុំឲ្យធ្វើកោសលវិច័យចំណុចធ្វើកោសលវិច័យ**

១. តុលាការអាចបង្គាប់ឲ្យធ្វើកោសល តាមពាក្យសុំរបស់ភាគីបាន។

២. ពេលស្នើសុំឲ្យធ្វើកោសលវិច័យ ភាគីដែលស្នើសុំត្រូវភ្ជាប់ជាមួយនូវឯកសារដែលកំណត់អំពីចំណុចដែលសុំឲ្យធ្វើកោសលវិច័យ។ ប៉ុន្តែ ប្រសិនបើមានមូលហេតុដែលពុំអាចជៀសវាងបាន ឯកសារនោះអាចដាក់នៅក្នុងអំឡុងពេលដែលតុលាការបានកំណត់។

៣. តុលាការត្រូវសួរយោបល់របស់ភាគីម្ខាងទៀត អំពីការស្នើសុំដែលមានចែងនៅក្នុងកថាខណ្ឌទី២ ខាងលើនេះ។

៤. តុលាការត្រូវកំណត់នូវចំណុចដែលត្រូវធ្វើកោសលវិច័យ ដោយយោងទៅតាមឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ ហើយពិចារណាអំពីយោបល់ដែលបាន

កំណត់នៅក្នុងកថាខណ្ឌទី៣ ខាងលើនេះ។ ក្នុងករណីនេះ តុលាការត្រូវផ្ញើឯកសារអំពីចំណុចដែលត្រូវធ្វើកោសលវិច័យនោះ ទៅអ្នកជំនាញ។

**មាត្រា១៤៤ ការចាត់តាំងអ្នកជំនាញខាងកោសលវិច័យ ករណីកិច្ចធ្វើកោសលវិច័យ**

១. អ្នកជំនាញខាងកោសលវិច័យត្រូវបានចាត់តាំងដោយតុលាការ។

២. ជនដែលមានចំណេះដឹងវិជ្ជា និង បទពិសោធន៍ចាំបាច់ក្នុងការធ្វើកោសលវិច័យ មានករណីកិច្ចធ្វើកោសលវិច័យ។

៣. ជនទាំងឡាយពុំអាចធ្វើជាអ្នកជំនាញខាងកោសលវិច័យបាន ក្នុងករណីដូចខាងក្រោមនេះ៖

ក. ការធ្វើកោសលវិច័យនោះ បណ្តាលឲ្យអ្នកជំនាញផ្ទាល់ខ្លួន ឬ សហព័ន្ធ ឬ ញាតិឯទៀតរបស់ខ្លួន អាចទទួលរងនូវការចោទប្រកាន់អំពីបទអាជ្ញា ឬ ទទួលការផ្តន្ទាទោស។ បញ្ញត្តិនេះត្រូវយកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការធ្វើកោសលវិច័យនោះ អាចធ្វើឲ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលដែលបានរៀបរាប់ខាងលើនេះបណ្តាលឲ្យមានការបែកបាក់ធ្ងន់ធ្ងរដល់ទំនាក់ទំនងគ្រួសារ។

ខ. ចំណុចដែលត្រូវធ្វើកោសលវិច័យនោះមានការពាក់ព័ន្ធទៅនឹងកិច្ចការសម្ងាត់ក្នុងមុខនាទីរបស់ខ្លួន ជាមន្ត្រីរាជការ ឬ អតីតមន្ត្រីរាជការ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលជនទាំងនេះ បានទទួលនូវការយល់ព្រមពីសំណាក់ក្រសួង ឬ ស្ថាប័នគ្រប់គ្រង។ ក្រសួង ឬ ស្ថាប័នគ្រប់គ្រង មិនអាចបដិសេធមិនផ្តល់ការយល់ព្រមបានឡើយ លើកលែងតែក្នុងករណីដែលអាចធ្វើឲ្យខូចផលប្រយោជន៍សាធារណៈ ឬ បណ្តាលឲ្យមានឧបសគ្គធ្ងន់ធ្ងរក្នុងការបំពេញការងាររដ្ឋ។

គ. ចំណុចដែលត្រូវធ្វើកោសលវិច័យនោះ មានការពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានដឹងដោយវេជ្ជបណ្ឌិត ទន្តបណ្ឌិត ឆ្មប គិលានុបដ្ឋាយិកា គិលានុបដ្ឋាក ឱសថការី មេធាវី អ្នកមានមុខងារក្នុងសាសនា ឬ អ្នកដែលធ្លាប់មានមុខងារខាងលើនេះ ក្នុងការបំពេញតួនាទីរបស់ខ្លួន ហើយដែលត្រូវលាក់ការសម្ងាត់។

ឃ. ចំណុចដែលត្រូវធ្វើកោសលវិច័យនោះ មានការពាក់ព័ន្ធនឹងការសង្ងាត់ក្នុងបច្ចេកទេស ឬ វិជ្ជាជីវៈ។

៤. ស្ថាប័នគ្រប់គ្រងដែលបានកំណត់ក្នុងកថាខណ្ឌទី៣ ចំណុច ខ គឺព្រឹទ្ធសភា ចំពោះសមាជិកព្រឹទ្ធសភា ឬ អតីតសមាជិកព្រឹទ្ធសភា រដ្ឋសភា ចំពោះសមាជិករដ្ឋសភា ឬ អតីតសមាជិករដ្ឋសភា រីឯចំពោះសមាជិករាជរដ្ឋាភិបាល ឬ អតីតសមាជិករាជរដ្ឋាភិបាល វិញគឺគណៈរដ្ឋមន្ត្រី។

៥. បញ្ញត្តិនៃចំណុច ខ គ និង ឃ នៃកថាខណ្ឌទី ៣ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកជំនាញខាងកោសលវិច័យនោះ ទទួលការលើកលែងពីកិច្ចលាក់ការសម្ងាត់។

**មាត្រា ១៤៥ បណ្ដឹងផាត់ចោលអ្នកជំនាញខាងកោសលវិច័យ**

១. ក្នុងករណីមានហេតុដែលរារាំងសច្ចភាពនៃការធ្វើកោសលវិច័យរបស់អ្នកជំនាញ ភាគីអាចប្ដឹងផាត់ចោលអ្នកជំនាញខាងកោសលវិច័យនោះបាន នៅមុនពេលដែលអ្នកជំនាញនោះធ្វើសេចក្ដីសន្និដ្ឋានអំពីចំណុចដែលត្រូវកោសលវិច័យ។ ទោះជាក្នុងករណីដែលអ្នកជំនាញខាងកោសលវិច័យបានធ្វើសេចក្ដីសន្និដ្ឋានរួចហើយក៏ដោយ ក៏បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមូលហេតុនៃបណ្ដឹងផាត់ចោលនោះបានកើតឡើងនៅពេលក្រោយ ឬ ភាគីបានដឹងអំពីមូលហេតុនោះ ក្រោយពេលដែលអ្នកជំនាញនោះបានធ្វើសេចក្ដីសន្និដ្ឋានរួច។

២. ពាក្យសុំផាត់ចោលត្រូវតែធ្វើជាលាយល័ក្ខណ៍អក្សរ លើកលែងតែក្នុងករណីដែលពាក្យសុំនោះត្រូវបានធ្វើឡើងនៅក្នុងកាលបរិច្ឆេទនៃនីតិវិធិត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុដោយផ្ទាល់មាត់។

៣. ភាគីដែលដាក់ពាក្យសុំផាត់ចោល ត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីមូលហេតុនៃបណ្ដឹងផាត់ចោលនោះ។

៤. ចំពោះដីកាសម្រេចដែលសម្រេចថា បណ្ដឹងផាត់ចោលមានមូលហេតុត្រឹមត្រូវ មិនអាចធ្វើបណ្ដឹងឧបាស្រ័យបានទេ។

៥. ចំពោះដីកាសម្រេចដែលសម្រេចថា បណ្តឹងផាត់ចោលគ្មានមូលហេតុត្រឹមត្រូវ អាចប្តឹងជំទាស់បាន។

**មាត្រា១៤៨ ការស្នើសុំឲ្យពិនិត្យភស្តុតាងជាឯកសារ ជាអាទិ៍**

១. ការស្នើសុំឲ្យពិនិត្យភស្តុតាងជាឯកសារ ត្រូវធ្វើឡើងដោយផ្តល់នូវឯកសារដែលសាមីភាគីមាន ឬដោយដាក់ពាក្យសុំទៅតុលាការឲ្យបង្គាប់ឲ្យម្ចាស់ឯកសារផ្តល់ឯកសារនោះមក។

២. ទោះបីជាមានបញ្ញត្តិក្នុងកថាខណ្ឌទី១ ខាងលើនេះក៏ដោយ ក៏ការស្នើសុំឲ្យពិនិត្យភស្តុតាងជាឯកសារនេះអាចធ្វើបាន ដោយដាក់ពាក្យសុំទៅតុលាការឲ្យស្នើសុំឲ្យម្ចាស់ឯកសារផ្ញើឯកសារនោះមក។

៣. ក្នុងករណីដែលយល់ឃើញថាចាំបាច់ តុលាការអាចឃាត់ទុកនូវឯកសារដែលបានផ្តល់មក ឬដែលបានផ្ញើមកបាន។

**មាត្រា១៥១ ពាក្យសុំដីការសម្រេចបង្គាប់ឲ្យផ្តល់ឯកសារ**

១. ពាក្យសុំដីការសម្រេចបង្គាប់ឲ្យផ្តល់ឯកសារ ត្រូវធ្វើឡើងដោយបញ្ជាក់ឲ្យបានច្បាស់លាស់នូវចំណុចខាងក្រោមនេះ៖

ក. ចំណងជើង និងខ្លឹមសារនៃឯកសារ។

ខ. ម្ចាស់ឯកសារ។

គ. អង្គហេតុដែលត្រូវបញ្ជាក់បំភ្លឺ។

២. ពាក្យសុំដីកាសម្រេចបង្គាប់ឲ្យផ្តល់ឯកសារ ត្រូវធ្វើជាលាយល័ក្ខអក្សរ។

៣. បើភាគីម្ខាងទៀតមានយោបល់ស្តីពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ ខាងលើភាគីនោះត្រូវដាក់ជូនទៅតុលាការនូវយោបល់របស់ខ្លួនជាលាយល័ក្ខអក្សរ។

**មាត្រា ១៥២ ដីកាសម្រេចបង្គាប់ឲ្យផ្តល់ឯកសារជាអាទិ៍**

១. ក្នុងករណីដែលតុលាការយល់ឃើញថា ពាក្យសុំដីកាសម្រេចបង្គាប់ឲ្យផ្តល់ឯកសារមានមូលហេតុត្រឹមត្រូវ តុលាការត្រូវបង្គាប់ដោយដីកាសម្រេចឲ្យម្ចាស់ឯកសារផ្តល់ឯកសារនោះ។ ក្នុងករណីនេះ បើមានផ្នែកខ្លះនៃឯកសារដែលយល់ឃើញថា មិនចាំពិនិត្យ ឬមានផ្នែកខ្លះដែលពុំអាចទទួលស្គាល់ថា មានករណីយកិច្ចក្នុងការផ្តល់ជូននោះតុលាការអាចបង្គាប់ឲ្យផ្តល់ដោយលើកលែកចោលនូវផ្នែកនោះបាន។

២. ក្នុងករណីដែលតុលាការមានបំណងនឹងបង្គាប់ឲ្យតតិយជនផ្តល់ឯកសារ តុលាការត្រូវសួរតតិយជន។

៣. ចំពោះដីកាសម្រេចអំពីពាក្យសុំដីកាសម្រេចបង្គាប់ឲ្យផ្តល់ឯកសារ អាចប្តឹងជំទាស់បាន។

**មាត្រា១៦១ ការស្នើសុំឲ្យត្រួតពិនិត្យ**

ការស្នើសុំឲ្យត្រួតពិនិត្យត្រូវធ្វើឡើង ដោយចង្អុលបង្ហាញនូវកម្មវត្ថុដែលត្រូវត្រួតពិនិត្យ។

**មាត្រា១៣៩ ការកម្រិតទៅលើសំណួរ**

១. ចំពោះសំណួរ បើអាចធ្វើបានត្រូវធ្វើដាច់ដោយឡែក និង ច្បាស់លាស់។

២. លើកលែងតែករណីដែលមានមូលហេតុត្រឹមត្រូវ មិនអាចសាកសួរបានឡើយនូវសំណួរខាងក្រោមនេះ៖

ក. សំណួរដែលប្រមាថមើលងាយ ឬ ធ្វើឲ្យច្របូកច្របល់ដល់សាក្សី។

ខ. សំណួរនាំមុខ។

គ. សំណួរច្រំដែល។

ឃ. សំណួរដែលគ្មានទំនាក់ទំនងនឹងចំណុចវិវាទ។

ង. សំណួរដែលទាមទារឲ្យថ្លែងយោបល់របស់សាក្សីផ្ទាល់ខ្លួន។

ច. សំណួរដែលទាមទារឲ្យថ្លែងនូវយោបល់អំពីអង្គហេតុដែលសាក្សីពុំបានជួបប្រទះផ្ទាល់។

៣. តុលាការអាចកម្រិតនូវសំណួរ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិបាន នៅពេលដែលយល់ឃើញថា សំណួរនោះផ្ទុយនឹងបញ្ញត្តិដែលមានចែងនៅកថាខណ្ឌទី២ ខាងលើនេះ។

៤. ភាគីអាចតវ៉ា ចំពោះការកម្រិតដែលធ្វើទៅតាមបញ្ញត្តិនៃកថាខណ្ឌទី៣ ខាងលើនេះបាន។